សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
ROYAL UNIVERSITY OF LAW AND ECONOMICS

# សារណាបញ្ចប់ការសិក្សា

# ចរាចរណ៍ផ្លូវគោក និងបញ្ហាប្រឈម នៅកម្ពុជាបច្ចុប្បន្ន

ស្រាវជ្រាវពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ចៅ លងម៉ាន់**

សាស្ត្រាចារ្យណែនាំ
លោក **ហៀង សាង**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១១

ឆ្នាំចូលរៀន ២០១៤
ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ ចៅ លងម៉ាន់ ជានិស្សិតបរិញ្ញាបត្រ ផ្នែករដ្ឋបាលសាធារណៈ ឆ្នាំទី៤ ជំនាន់ទី ១១ ក្រុម $P_4C_1$ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវការគោរពក៏ជ្រាលជ្រៅ និងដឹងគុណជាទីបំផុតចំពោះ៖

**សូមគោរពដឹងគុណ អ្នកមានគុណទាំងពីរ** ដែលបានផ្តល់កំណើតដល់រូបខ្ញុំ និងចិញ្ចឹមបីបាច់ថែរក្សា ទូន្មានប្រៀនប្រដៅខ្ញុំបាទតាំងពីតូច ថែមទាំងផ្គត់ផ្គង់បរិច្ចាគថវិកា កម្លាំងកាយ និងកម្លាំងចិត្តឲ្យខ្ញុំបានសិក្សាតាំងពីមិនទាន់ដឹងក្តី រហូតដល់ បញ្ចប់ថ្នាក់បរិញ្ញាបត្រ ដោយលោកពុំដែលគិតគូរពីការនឿយហត់ ដើម្បីផ្តល់ឱកាសរូបខ្ញុំបានទទួលនូវចំណេះដឹងដ៏ថ្លៃថ្លា ព្រមទាំងបទពិសោធន៍នៃជីវិតដ៏មានតម្លៃបំផុត។ មិនត្រឹមតែអ្នកមានគុណទាំងពីរជាបង្អែកប៉ុណ្ណោះ គឺថែមទាំងក្រុមគ្រួសារទាំងមូល ក៏ជាអ្នកលើកទឹកចិត្ត និងជួយជំរុញឲ្យ ខ្ញុំបាទទទួលបាននូវភាពជោគជ័យក្នុងថ្ងៃនេះ។

**ឯកឧត្តមសាកលវិទ្យាធិការ** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ហើយជាពិសេសនោះគឺលោកសាស្ត្រាចារ្យ **ហៀង សាង** ដែលបានខិតខំចេញពីកម្លាំងកាយចិត្ត ដើម្បីពន្យល់ណែនាំខ្ញុំបាទរហូតបានសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះដោយជោគជ័យ។

**លោកគ្រូ អ្នកគ្រូ** ទាំងអស់ដែលជាសាស្ត្រចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ថែមទាំងលោកគ្រូ អ្នកគ្រូ តាំងពីថ្នាក់បឋម ដែលបានអប់រំ បង្ហាត់បង្រៀនដល់ខ្ញុំ ក្នុងការទទួលបាននូវចំណេះដឹង និងបទពិសោធន៍ជាច្រើន។

ជាថ្មីម្តងទៀត ខ្ញុំបាទ សូមបួងសួងជូនពរ ដល់អ្នកមានគុណទាំងពីរ ក្រុមគ្រួសារ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ ដែលបម្រើការគ្រប់ជំនាញបុគ្គលិកទាំងអស់ មិត្តរួមថ្នាក់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកបដោយសេចក្តីសុខ សុភមង្គល និងជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

ក្នុងការសិក្សាស្រាវជ្រាវទៅលើកត្តាចាំបាច់ ក្នុងការរស់នៅរបស់ប្រជាពលរដ្ឋខ្មែរយើង ដែលតែងតែប្រើប្រាស់មធ្យោបាយធ្វើដំណើរ និងធ្វើការប្រាស្រ័យទាក់ទងពីទីកន្លែងមួយទៅកន្លែងមួយ។ ក្នុងនោះផងដែលខ្ញុំបាទ បានសិក្សាស្រាវជ្រាវទៅលើ ប្រធានបទមួយដែលទាក់ទងទៅនឹងចរាចរណ៍ផ្លូវគោក ក្រោមប្រធានបទ ចរាចរណ៍ផ្លូវគោក និងបញ្ហាប្រឈមនៅកម្ពុជាបច្ចុប្បន្ន។

ស្របពេលដែលសេដ្ឋកិច្ចកំពុងតែរីកចម្រើន ដែលធ្វើឲ្យកំណើននៃការប្រើប្រាស់យានជំនិះ និងការគោរពនៃច្បាប់ចរាចរណ៍នៅតាមដងផ្លូវមានភាពមមាញឹក ជារៀងរាល់ថ្ងៃ។ មិនត្រឹមតែប៉ុណ្ណោះ ក្នុងការធ្វើដំណើរនៅលើផ្លូវគោកនេះផងដែរ ក៏តែងតែមានជានិច្ចនូវ គ្រោះថ្នាក់ចរាចរណ៍ដែលធ្វើឲ្យប៉ះពាល់ដល់ ទ្រព្យសម្បត្តិ អាយុជីវិត ប្រជាពលរដ្ឋខ្មែរ និងគ្រោះថ្នាក់របួសស្នាមជាច្រើន។ បញ្ហាជាច្រើនទាំងអស់នេះហើយ ផ្តល់ផលវិបាកដល់ រាជរដ្ឋាភិបាល ស្ថាប័ន្តពាក់ព័ន្ធ នឹងអង្គការមិនមែន រដ្ឋាភិបាល ជាពិសេសប្រជាពលរដ្ឋ ដែលតែងតែជួបការលំបាកក្នុងធ្វើដំណើរ និងមានភាពភ័យខ្លាច ទៅលើសុវត្ថិភាពរបស់ពួកគាត់ក្នុងធ្វើដំណើរ។

ទាក់ទងនឹងចរាចរណ៍ផ្លូវគោកនេះផងដែរ រាជរដ្ឋាភិបាល ស្ថាប័ន្តពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល និងប្រជាពលរដ្ឋ បានព្យាយាមរៀបចំឲ្យមានវិធីសាស្រ្តជាច្រើន ក្នុងការដោះស្រាយផ្សព្វផ្សាយ ពីវិធីសាស្រ្តក្នុងការកាត់បន្ថយ គ្រោះថ្នាក់ចរាចរណ៍ និងរៀបចំឲ្យមានសណ្តាប់ធ្នាប់ក្នុងសង្គមជាតិផងដែរ។

ដូច្នេះហើយទើបគោលបំណងនៃការស្រាវជ្រាវនេះ គឺចង់ផ្តោតទៅលើលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល អង្គការដៃគូ ក៏ដូចជាប្រជាពលរដ្ឋ តាមរយៈការបង្កើតឡើងជាវេទិកា ឬសិក្ខាសាលាជជែកពិភាក្សាគ្នាអំពីដំណោះស្រាយជារួមក្នុងការ កាត់បន្ថយនូវអត្រានៃការគ្រោះថ្នាក់ចរាចរណ៍ និងសណ្តាប់ធ្នាប់សុវត្ថិភាពដល់ប្រជាពលរដ្ឋទាំងមូល។ យ៉ាងណាមិញ ក្នុងការស្រាវជ្រាវកិច្ចការនេះផងដែរ ខ្ញុំបាទបានសិក្សាពីកត្តាមួយចំនួន ដែលជាបញ្ហាចោទ និងវិធីសាស្រ្តដើម្បីចូលរួមចំណែកដោះស្រាយ ដោយស្របទៅតាមច្បាប់ គោលនយោបាយ និងវិធីសាស្រ្តផ្សេងៗ របស់ រាជរដ្ឋាភិបាលកម្ពុជា។

ចំពោះការរៀបចំឯកសារនេះ ខ្ញុំបាទជឿជាក់ថាអាចនៅមានចំណុចខ្វះខាត និងកំហុសឆ្គងមួយចំនួន ដែលកើតមានដោយអចេតនា ទាំងអក្ខរាវិរុទ្ធ ទាំងពាក្យពេចន៍ អត្ថន័យ និងទស្សនៈមួយចំនួនជាក់ជាមិនខាន។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ............................................................ ១
ក. លំនាំបញ្ហា ............................................................ ១
ខ. ចំណោទបញ្ហា ............................................................ ១
គ. គោលបំណងនៃការស្រាវជ្រាវ ............................................................ ២
ឃ. វិសាលភាពនិងដែនកំណត់ ............................................................ ៣
ង. សារៈសំខាន់នៃការស្រាវជ្រាវ ............................................................ ៣
ច. វិធីសាស្ត្រស្រាវជ្រាវ ............................................................ ៣
ឆ. រចនាសម្ពន្ធនៃការស្រាវជ្រាវ ............................................................ ៤

**ជំពូកទី១**

**លក្ខណៈទូទៅ និងស្ថានភាពនៅលើការប្រើប្រាស់លើដងផ្លូវ**

**១.១ និយមន័យ** ............................................................ ៥
**១.២ សញ្ញាណទូទៅនៃចរាចរណ៍ផ្លូវគោក** ............................................................ ៥
១.២.១ សណ្ឋានផ្លូវ ............................................................ ៥
**១.៣ លក្ខណៈទូទៅនៃការប្រើប្រាស់នៃយានជំនិះនៅលើផ្លូវ** ............................................................ ៦
១.៣.១ ឡាន ............................................................ ៦
១.៣.២ ម៉ូតូ ............................................................ ៧
១.៣.៣ កង់ ............................................................ ៨
១.៣.៤ ថ្មើរជើង ............................................................ ៨
**១.៤.ប្រភពទិន្នន័យ និងអ្នករងគ្រោះនៃគ្រោះថ្នាក់ចរាចរណ៍** ............................................................ ៩
**១.៥ ទិដ្ឋភាពផ្លូវច្បាប់** ............................................................ ១០

**ជំពូកទី២**

**មូលហេតុ និងផលប៉ះពាល់នៃគ្រោះថ្នាក់ចរាចរណ៍**

**២.១ មូលហេតុនៃគ្រោះថ្នាក់ចរាចរណ៍** ............................................................ ១៩
២.១.១ កត្តាមនុស្ស ............................................................ ១៩
២.១.១.១ ការបើកបរហួសល្បឿនកំណត់ ............................................................ ២០

២.១.១.២ ការបើកបរក្រោមឥទ្ធិពលនៃគ្រឿងស្រវឹងឬគ្រឿងញៀន ........................................ ២០
២.១.១.៣ ការមិនគោរពសិទ្ធអាទិភាពនៅកន្លែងផ្លូវប្រសព្វ ........................................ ២១
២.១.១.៤ ការជែងដោយខ្វះការប្រុងប្រយ័ត្ន ........................................ ២១
២.១.១.៥ ការមិនគោរពភ្លើងសញ្ញាចរាចរណ៍ ........................................ ២១
២.១.១.៦ ការបត់ឆ្វេង បត់ស្តាំ ឬត្រឡប់ក្រោយដោយគ្មានការប្រុងប្រយ័ត្ន ........................................ ២១
២.១.១.៧ ការបើកបរពេលងងុយគេងឬមានជំងឺ ........................................ ២២
២.១.២ ការប្រើប្រាស់យានជំនិះខុសស្តង់ដារបច្ចេកទេស ........................................ ២២
២.១.៣ ការដឹកទំនិញលើសចំនួនកំណត់ និងស្ថានភាពផ្លូវ ........................................ ២៣
២.១.៤ ការបើកបរក្រោមអាកាសធាតុភ្លៀងធ្លាក់ ........................................ ២៤
២.១.៥ ការគ្មានការប្រុងប្រយ័ត្ន និងកាពារ ........................................ ២៤
២.១.៥.១ មួកសុវត្ថិភាព ........................................ ២៥
២.១.៥.២ កញ្ចក់សងខាង ........................................ ២៦
២.១.៥.៣ ខ្សែក្រវ៉ាត់សុវត្ថិភាព ........................................ ២៦
២.១.៥.៤ ប្រើប្រាស់ទូរស័ព្ទ ពេលកំពុងបើកបរ ........................................ ២៧
២.១.៦ សុជីវធម៌ និងអធ្យាស្រ័យក្នុងពេលបើកបរ ........................................ ២៧
២.១.៧សណ្តាប់ធ្នាប់សាធារណៈ........................................ ២៧
២.១.៧.១ ចំណត់រថយន្ត ........................................ ២៨
២.១.៧.២ ទូលកាត់ទទឹងផ្លូវ ........................................ ២៨
២.១.៧.៣ ការជះទឹកលើដងផ្លូវ ឬសំរាមលើដងផ្លូវ ........................................ ២៩
**២.២ ស្ថានភាពនៃគ្រោះថ្នាក់ចរាចរណ៍** ........................................ ៣០
២.២.១ ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍ទូទាំងប្រទេស ........................................ ៣០
២.២.២ ប្រភេទរបួស និងអ្នកស្លាប់ ........................................ ៣១
២.២.៣ ប្រភេទនៃការប៉ះទង្គិច និងទីតាំងជើងកប ........................................ ៣១
២.២.៤ ពេលវេលានៃគ្រោះថ្នាក់ ........................................ ៣៣
**២.៣ ផលប៉ះពាល់នៃគ្រោះថ្នាក់ចរាចរណ៍** ........................................ ៣៣
២.៣.១ សង្គម ........................................ ៣៣
២.៣.២ សេដ្ឋកិច្ច ........................................ ៣៤
២.៣.៣ សុខភាព រូបរាងកាយ និងពេលវេលា ........................................ ៣៥

## ជំពូកទី៣

## ដំណោះស្រាយ និងទិសដៅអនាគត

**៣.១ វិធានការទប់ស្កាត់ និងដំណោះស្រាយ** ........ ៣៧

៣.១.១ គោលនយោបាយ ........ ៣៧

៣.១.២ កត្តាច្បាប់ ........ ៣៩

៣.១.៣ រាជរដ្ឋាភិបាល ........ ៤០

៣.១.៤ ការចូលរួមពីសង្គមស៊ីវិល ........ ៤៣

៣.១.៥ ប្រជាជន ........ ៤៤

**៣.២ អនុវត្តន្ទូវសកម្មភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោក** ........ ៤៧

៣.២.១ ការជួញសង្គ្រោះជនរងគ្រោះ ........ ៤៧

៣.២.២ ការប្រើប្រាស់វិធានការកាពារ ........ ៤៨

**៣.៣ ទិសដៅអនាគត** ........ ៥១

**សេចក្ដីសន្និដ្ឋាន** ........ ៥៣

**អនុសាសន៍** ........ ៥៥

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ក.លំនាំបញ្ហា

បច្ចុប្បន្ននៅក្នុងប្រទេសខ្មែរ ក៏ដូចជាប្រទេសជាតិដទៃនៅជុំវិញពិភពលោកទាំងមូល បាន និងកំពុងតែរងឥទ្ធិពល និងជួបបញ្ហាជាច្រើនទាក់ទងនឹងចរាចរណ៍ផ្លូវគោកដែលធ្វើឲ្យមានការគ្រោះថ្នាក់ របួសស្នាម បាត់បង់ជីវិត អសន្តិសុខសង្គម ខូចខាតសណ្តាប់ធ្នាប់សាធារណៈ ប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ ព្រមទាំងសេដ្ឋកិច្ចក្នុងក្រុមគ្រួសារ និងបង្កភាពស្មុគស្មាញជាច្រើនដល់ប្រទេសជាតិទាំងមូល ។

គ្រោះថ្នាក់ចរាចរណ៍នេះផងដែរបានឆក់យកអាយុជីវិតប្រជាពលរដ្ឋខ្មែរជាច្រើន ថែមទាំងឆក់យកអាយុជីវិតមនុស្សយ៉ាងតិចម្នាក់ក្នុងមួយថ្ងៃ និងគ្រោះថ្នាក់របួសស្នាមជាច្រើនករណីជារៀងរាល់ថ្ងៃនៅលើដងផ្លូវក្នុងប្រទេសកម្ពុជា។ គ្រោះថ្នាក់ចរាចរណ៍នេះផងដែលបាន កើតឡើងជាច្រើនករណី ដែលក្នុងនោះមានដូចជា ការសេពគ្រឿងស្រវឹង ការមិនគោរពច្បាប់ចរាចរណ៍ ការមិនចេះអត់ឱនឲ្យគ្នាទៅវិញទៅមក និងមានកត្តាគួបផ្សំជាច្រើនទៀត ។ល។

នៅក្នុងបរិបទសង្គមនាពេលបច្ចុប្បន្ន ប្រទេសជាតិមួយដែលអាចមានការអភិវឌ្ឍរីកចម្រើនទៅបាន លុះត្រាតែមានធនធានមនុស្សច្រើន សង្គម មានសណ្តាប់ធ្នាប់សាធារណៈល្អ គ្មានការគ្រោះថ្នាក់ ឬ ខាតបង់ទៅតាមប្រការណាមួយ ដែលធ្វើឲ្យសង្គមជាតិមានការវិវត្ត។ ការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ជាគន្លឹះដ៏សំខាន់ និងដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួម កាត់បន្ថយការខាតបាត់បង់ ទាំងធនធានមនុស្ស និងធនធានសេដ្ឋកិច្ច ព្រមទាំងកត្តាជាច្រើនទៀត។

រាជរដ្ឋាភិបាលកម្ពុជា ក្រសួងស្ថាប័នពាក់ព័ន្ធ និងអង្គការក្រៅរាជរដ្ឋាភិបាល បានព្យាយាមគិតគូទៅលើ ចរាចរណ៍ផ្លូវគោកនេះ និងរកវិធីសាស្ត្រ ឬដំណោះស្រាយផ្សេងៗដើម្បីចូលរួមជាផ្សព្វផ្សាយ ច្បាប់ និងយុទ្ធសាស្ត្រផ្សេងៗ ជាពិសេសការប្រើប្រាស់ និងការបើកបរប្រចាំថ្ងៃឲ្យមានសុខសុវត្ថិភាព។ មិនត្រឹមតែប៉ុណ្ណោះប្រជាពលរដ្ឋខ្លួនផ្ទាល់មានតួនាទីសំខាន់ក្នុងការចូលរួម និងផ្សព្វផ្សាយពីចរាចរណ៍ផ្លូវគោកនេះតាមគ្រប់រូបភាពដែលអាចធ្វើទៅបាន។

## ខ. ចំណោទបញ្ហា

ប្រសិនបើយើងក្រឡេកមើលទៅលើចរារចណ៍ផ្លូវគោកនាពេលបច្ចុប្បន្ន ពិតជាមានភាពមមាញឹក និងមានលក្ខណៈស្មុគស្មាញ និងមានបញ្ហាជាច្រើនដែលពិបាកដោះស្រាយ។ រាល់កិច្ចការទាំងអស់នេះប្រាកដណាស់ គឺវាតម្រូវឲ្យមានការចូលរួមសហការពីភាគីដែលពាក់ព័ន្ធធ្វើការរួមគ្នាហើយស្វែងរកនូវជម្រើស ឬគន្លឹះល្អមួយចំនួនសម្រាប់ជាត្រីវិស័យឆ្ពោះទៅរកការគ្រប់គ្រងទៅលើការបើកបរ និងប្រើប្រាស់ចរាចរណ៍ផ្លូវគោក ឲ្យមានលក្ខណៈកាន់តែល្អប្រសើរឡើង។ ដោយហេតុ

នេះហើយទើបឥទ្ធិពលនៃការប្រើប្រាស់យានជំនិះនៅលើដងផ្លូវនេះ បានក្លាយជាបញ្ហាដ៏ធំដែលចោទទៅនឹងសង្គមខ្មែរ និងពិភពលោកធ្វើការដោះស្រាយជុំវិញបញ្ហានេះ។ មកទល់នឹងពេលនេះមានមតិព្រមទាំងសំណួរមួយចំនួនដែលបានលើកឡើងយ៉ាងដូច្នេះថា៖

- តើមូលហេតុអ្វីបានជាគ្រោះថ្នាក់ចរាចរណ៍ កើតឡើងជារៀងរាល់ថ្ងៃ? និងមានមនុស្សរបួសនិងស្លាប់ច្រើនបែបនេះ?
- តើដំណោះស្រាយ ទៅលើបញ្ហានេះមានដែលឬទេ?
- តើរាជរដ្ឋាភិបាលកម្ពុជា បានគិតគូពីបញ្ហានេះដែលឬទេ?
- ចំពោះដំណោះស្រាយ និងអនាគតថាតើយើងគួរមានវិធានការបែបណាខ្លះក្នុងការគ្រប់គ្រង លើឥទ្ធិពល និងការប្រើប្រាស់ដងផ្លូវ និងយានជំនិះអោយមានប្រសិទ្ធភាពខ្ពស់បំផុត?

ដើម្បីឆ្លើយតបទៅនឹងសំណួរខាងលើ ដែលបានចោទសួរឡើងនេះ ខ្ញុំបាទសូមធ្វើការសិក្សា និងបកស្រាយនូវអត្ថន័យ សញ្ញាណ លក្ខណៈទូទៅ ក៏ដូចជាមូលហេតុ និងដំណោះស្រាយ វិធានការ និងយុទ្ធសាស្ត្រសម្រាប់ទិសដៅអនាគត នៅក្រោម ដូចដែលមានបកស្រាយក្នុងជំពូកទី១ រហូតដល់ជំពូកទី៣ សម្រាប់ធ្វើការសិក្សា និងបកស្រាយ។

## គ. គោលបំណងនៃការស្រាវជ្រាវ

យើងដូចដែលយើងបានដឹងហើយថា ចរាចរណ៍ផ្លូវគោក នៅប្រទេសកម្ពុជាយើងសព្វថ្ងៃកំពុងតែមានភាពស្មុគស្មាញ និងមានជាបញ្ហាជាច្រើនដែល ក្នុងនាមជាប្រជាពលរដ្ឋគ្រប់រូបត្រូវគិតគូ និងជួយដោះស្រាយ។ ក្នុងបញ្ហានេះផងដែលមិនថានៅក្នុងប្រទេស ឬពិភពលោក វាបានបង្កជាបញ្ហាឲ្យមានការបាត់បង់ទ្រព្យសម្បត្តិ ពេលវេលា សណ្តាប់ធ្នាប់ និងអាយុជីវិតថែមទៀត។ ប៉ុន្តែទោះបីជាសង្គមរបស់យើងកំពុងស្ថិតក្នុងស្ថានភាពបច្ចុប្បន្ន ដែលត្រូវការនូវដំណោះស្រាយ ដែលទាមទារឲ្យមានការចូលរួមពី ប្រជាពលរដ្ឋគ្រប់រូប គ្រប់ស្រទាប់វណ្ណៈ ដើម្បីគាំទ្រ និងអនុវត្តនូវគោលការ ឬច្បាប់របស់ប្រទេសអោយមានប្រសិទ្ធភាព និងជៀសផុតពីបញ្ហាផ្សេងៗនូវលើដងផ្លូវ។

ដោយបានឃើញការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល ជាពិសេសក្រសួងស្ថាប័ន ពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល បានកំពុងព្យាយាមដាក់ចេញនូវ គោលនយោបាយ ច្បាប់ វិធីសាស្ត្រ និងយុទ្ធសាស្ត្រ ក្នុងការដោះស្រាយ តាមរយៈការផ្សព្វផ្សាយ ការចុះអនុវត្តផ្ទាល់តាមបណ្តារាជធានីខេត្ត និងជនបទ ស្រុកស្រែចំការ ឲ្យប្រជាពលរដ្ឋបានយល់ដឹងពីវិធីបង្កា និងវិធីសាស្ត្រការពារនូវការគ្រោះថ្នាក់នៅលើដងផ្លូវដែលយើងគ្រប់គ្នាមិនអាចមើលនឹងភ្នែកឃើញ។ កិច្ចការស្រាវនេះក្នុងគោលបំណងគាំទ្រទៅតាមគោលការណ៍ និងជួយផ្សព្វផ្សាយទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន

និងដើម្បីសង្គមជាតិរបស់យើងជៀសផុតពីការបញ្ហាផ្សេងៗ និងកាត់បន្ថយអត្រានៃការបាត់បង់ជីវិត ការខាតបង់ ទ្រព្យសម្បត្តិផ្សេងៗ ពិសេសការអភិវឌ្ឍប្រទេសដែលចាំបាច់នូវធនធានមនុស្ស។

**ឃ. វិសាលភាពនិងដែនកំណត់**

ការសិក្សាស្រាវជ្រាវប្រធានបទស្ដីពី '' **ចរាចរណ៍ផ្លូវគោក និងបញ្ហាប្រឈមនៅកម្ពុជាបច្ចុប្បន្ន** ''នេះមានដែនកំណត់ និងវិសាលភាពត្រឹមតែការសិក្សាស្វែងយល់ពីស្ថានភាព និងបញ្ហាប្រឈម ព្រមជាមួយផលប៉ះពាល់នៅលើប្រជាពលរដ្ឋ និងសង្គមរបស់យើងនាពេលបច្ចុប្បន្ននេះ ក៏ដូចជាដំណោះស្រាយល្អៗសម្រាប់ ចូលរួមដល់សង្គមតែប៉ុណ្ណោះ។ លើសពីនេះទៅទៀត ការសិក្សាទៅលើប្រធានបទនេះពុំមានបំណងក្នុងការរិះគន់ និងប្រកាន់គំនិតតែម្ខាង ឬក៏បៀតបៀនទៅលើបុគ្គលណាម្នាក់ឡើយ ថែមទាំងមិនមានចក្ខុវិស័យប្រឆាំងតាមរូបភាព ឬខ្លឹមសារណាមួយរបស់ក្រសួងស្ថាប័ន ពាក់ព័ន្ធឡើយ។ ប៉ុន្តែខ្ញុំគ្រាម់តែចង់ចូលរួម ក្នុងវិធីសាស្ត្ររបស់ខ្ញុំក្នុងការសិក្សាស្រាវជ្រាវដើម្បីជាចូលរួមផ្សព្វផ្សាយនូវចំណេះបន្តិចបន្តួច ដើម្បីចូលរួមកាត់បន្ថយ បញ្ហាផ្សេងៗនូវលើចរាចរណ៍ផ្លូវគោក និងបង្កឲ្យមានសណ្តាប់ធ្នាប់ល្អក្នុងសង្គម។ ម្យ៉ាងវិញទៀតប្រធានបទខាងលើនេះក៏ពុំមានបំណងបង្ខិតបង្ខំដល់បុគ្គលណាម្នាក់ឲ្យចូលរួម ឬត្រូវតែអនុវត្តតាមនោះឡើយ គឺអាស្រ័យលើឆន្ទៈបុគ្គលផ្ទាល់ខ្លួនជាអ្នកគិតពិចារណា។

**ង. សារៈសំខាន់នៃការស្រាវជ្រាវ**

នៅក្នុងការសិក្សាស្រាវជ្រាវចំពោះចរាចរណ៍ផ្លូវគោក និងបញ្ហាប្រឈមនៅកម្ពុជាបច្ចុប្បន្ននេះ យើងខ្ញុំបានខិតខំសម្រិតសម្រាំងយ៉ាងម៉ត់ចត់ជាទីបំផុតជូនលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ ក៏ដូចជាទៅដល់មិត្តៗនិស្សិតឲ្យបានជ្រាបថា តើចរាចរណ៍ផ្លូវគោកនៅកម្ពុជាបច្ចុប្បន្នមានស្ថានភាពដូចម្តេចដែរ ហើយក្នុងនាមជាប្រជាពលរដ្ឋម្នាក់ តើមានវិធានការបង្ការក្នុងចូលរួមទប់ស្កាត់ឬក៏ ចូលរួមដោយរបៀបណាដែល ក្នុងការកាត់បន្ថយបញ្ហាផ្សេងៗ ជាពិសេសចូលរួមទប់ស្កាត់ និងបង្ការដោយរបៀបណាជាពិសេសគ្រោះថ្នាក់នៅលើដងផ្លូវ។

**ច. វិធីសាស្ត្រស្រាវជ្រាវ**

ដើម្បីឲ្យកិច្ចការស្រាវជ្រាវរបស់ខ្ញុំនេះ ចេញជារូបរាងខ្ញុំបាទបានសិក្សាស្រាវជ្រាវ និងប្រើវិធីសាស្ត្រដូចជាគឺៈ

**ទិន្នន័យចម្បងៈ** តាមរយៈទិន្នន័យចម្បងនេះ ត្រូវបានរៀបចំ និងបង្កើតឡើងក្រោមរូបភាពនៃការសាកសួរព័ត៌មានផ្ទាល់តាមរយៈសម្ភាស របាយការណ៍របស់ក្រសួងស្ថាប័នផ្សេងៗដែលពាក់ព័ន្ធ ជាពិសេសតួរលេខច្បាស់លាស់ពីមន្ត្រីជំនាញ។ សូមបញ្ជាក់ផងដែលថាទិន្នន័យចម្បងនេះត្រូវ

បានប្រើប្រាស់ភាគច្រើននៅក្នុងឆ្នាំ២០១៦ និង៥ឆ្នាំមុន។ ដោយហេតុថា របាយការណ៍ទិន្នន័យមួយចំនួនក្នុងឆ្នាំ២០១៧ មិនទាន់បានរៀបចំចប់សព្វគ្រប់នៅឡើយ។

**ទិន្នន័យបន្ទាប់បន្សំ៖** ចំណែកឯទិន្នន័យបន្ទាប់បន្សំនេះវិញ គឺត្រូវទទួលបានតាមរយៈការប្រមូលឯកសារ សៀវភៅ និងទិន្នន័យតាមមធ្យោបាយផ្សេងៗ ព្រមទាំងដកស្រង់ចេញពីគំនិតយោបល់ពីប្រជាពលរដ្ឋទូទៅ ដោយដកស្រង់ចំណុចដូចៗគ្នាពីមតិទូទៅនូវទស្សនវិស័យ និងពន្យល់ណែនាំពីសាស្ត្រាចារ្យណែនាំសារណាបញ្ចប់ការសិក្សា។

## ឆ. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះរចនាសម្ព័ន្ធនៃប្រធានបទស្តីពី **ចរាចរណ៍ផ្លូវគោក និងបញ្ហាប្រឈមនៅកម្ពុជាបច្ចុប្បន្ន** ត្រូវបានចែកចេញជា៣ ជំពូក គឺជំពូកទី១ ទី២ និងទី៣ ដែលក្នុងនោះរួមមាន ជំពូកទី១ មាន និយមន័យ សញ្ញាណនៃចរាចរណ៍ផ្លូវគោក លក្ខណៈទូទៅនៃការប្រើប្រាស់យានជំនិះ អត្រាចំនួនអ្នករងគ្រោះនៃគ្រោះថ្នាក់ចរាចរណ៍ ទិដ្ឋភាពច្បាប់, ជំពូកទី២ រួមមានមូលហេតុនៃគ្រោះថ្នាក់ចរាចរណ៍ ស្ថានភាពនៃគ្រោះថ្នាក់ចរាចរណ៍ និងផលប៉ះពាល់នៃគ្រោះថ្នាក់ចរាចរណ៍ និងជាចុងក្រោយគឺ ជំពូកទី៣ និងបកស្រាយពី វិធានទប់ស្កាត់ និងដំណោះស្រាយ, អនុវត្តសកម្មភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោក ទិសដៅអនាគត និងគំនិតបំពេញបន្ថែម ព្រមទាំងមានសេចក្តីសន្និដ្ឋានអនុសាសន៍ នឹងឧបសម្ពន្ធ។

# ជំពូកទី១

# លក្ខណៈទូទៅ និងស្ថានភាពនៅលើការប្រើប្រាស់លើដងផ្លូវ

## ១.១ និយមន័យ

បើយើងនិយាយអំពីពាក្យ **ចរាចរណ៍** គឺសំដៅទៅលើ ប្រភេទនៃចរាចរណ៍ ដែលក្នុងនោះមាន ៣ ប្រភេទគឺ ចរាចរណ៍ផ្លូវគោក, ចរាចរណ៍ផ្លូវទឹក និងចរាចរណ៍ផ្លូវអាកាស។

នៅក្នុងកិច្ចការស្រាវជ្រាវនេះផងដែរគឺ សំដៅទៅលើ **ចរាចរណ៍ផ្លូវគោក។**

ដោយយោងទៅតាមវចនានុក្រម **សម្តេចព្រះសង្ឃរាជ ជួន ណាត** បានឲ្យនិយមន័យទៅលើពាក្យថា ចរាចរណ៍ ថា ការដើរទៅមក ដំណើរខ្វាត់ខ្វែងចុះឡើង, ដំណើរតាមផ្លូវសាធារណៈតាមតែផ្លូវណាក៏ដោយ។[1] រីឯ ចំពោះច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក វិញបានឲ្យវិសាលភាពទៅលើចរាចរណ៍លើផ្លូវថ្នល់ ក្នុងន័យនេះ យោងទៅតាមសន្ទានុក្រម ក៏បញ្ជាក់ពី ពាក្យថាផ្លូវថ្នល់ ដែលហៅកាត់ គឺទំហំទាំងមូលនៃទ្រូងផ្លូវ រួមជាមួយជាយផ្លូវ ឬចិញ្ចើមផ្លូវ។[2]

ដូច្នេះជារួម ក្នុងនិយមន័យនៃ **ចរាចរណ៍ផ្លូវគោក** គឺសំដៅទៅលើ ការធ្វើដំណើរខ្វាត់ខ្វែងតាមផ្លូវថ្នល់ ឬផ្លូវសាធារណៈ។

## ១.២ សញ្ញាណទូទៅនៃចរាចរណ៍ផ្លូវគោក

### ១.២.១ សណ្ឋានផ្លូវ

នៅក្នុងប្រទេសកម្ពុជាមានផ្លូវជាច្រើនប្រភេទ ដែលបានតភ្ជាប់ពីផ្លូវមួយទៅផ្លូវមួយទៀត ហើយបានឲ្យនិយមន័យ និងឈ្មោះផ្លូវទៅតាមស្ថានភាព និងបរិមាណនៃផ្លូវនោះ។ មិនត្រឹមតែប៉ុណ្ណោះ នៅក្នុងប្រទេសកម្ពុជា មានប្រភេទផ្លូវជាច្រើនដូចជាៈផ្លូវថ្នល់ ផ្លូវជាតិ ផ្លូវជនបទ ផ្លូវល្បឿនលឿន បរិក្ខារផ្លូវថ្នល់ ទ្រូងផ្លូវ ជាយផ្លូវ ចិញ្ចើមផ្លូវ គន្លងផ្លូវ។ល។[3]

នៅក្នុងចរាចរណ៍ផ្លូវគោកក៏មាន ការបែកចែកនូវគំនូសសញ្ញាទៅតាមប្រភេទផ្លូវគួបផ្សំនិងស្លាកសញ្ញាចរាចរណ៍ និងមានការបែកចែកសម្រាប់អ្នកធ្វើដំណើរដោយមាន ថ្មើរជើង កង់ ម៉ូតូ ឡាន ឬយានជំនិះផ្សេងៗទៀត ដើម្បីធ្វើការកត់សម្គាល់ទៅលើស្ថានភាពនៃចរាចរណ៍ផ្លូវគោក។

នៅក្នុងប្រទេសកម្ពុជាកំណត់សម្គាល់ផងដែរនៃ ឈ្មោះផ្លូវជាច្រើនប្រភេទ និងលេខសម្គាល់ផ្លូវ មិនត្រឹមតែប៉ុណ្ណោះ ក៏មាន អនុក្រឹត្យ ស្តីពី បែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវឬ

[1] វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ដែលបោះពុម្ពផ្សាយនៅក្នុងឆ្នាំ ១៩៦៧

[2] ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក, ជំពូកទី១បទប្បញ្ញត្តិទូទៅ មាត្រា៤ (ភ្នំពេញៈ ២៦ ខែមករា ឆ្នាំ២០១៧)

[3] ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក, ជំពូកទី១បទប្បញ្ញត្តិទូទៅ មាត្រា៤ (ភ្នំពេញៈ ២៦ ខែមករា ឆ្នាំ២០១៧)

កែប្រែឈ្មោះផ្លូវឬលេខផ្លូវ[4] ដែលបានបង្ហាញយ៉ាងច្បាស់ពី បទប្បញ្ញត្តិទូទៅ សមត្ថកិច្ចគ្រប់គ្រង ការកំណត់ភូមិសាស្ត្រផ្លូវថ្នល់ និងមានច្រើនទៀត។ល។

## ១.៣ លក្ខណៈទូទៅនៃការប្រើប្រាស់នៃយានជំនិះនៅលើផ្លូវ

### ១.៣.១ ឡាន

នៅបច្ចុប្បន្នការប្រើប្រាស់យានជំនិះក្នុងការធ្វើដំណើរនៅលើដងផ្លូវ យើងសង្កេតឃើញថាមានការកើនឡើងខ្លាំងគួរឲ្យកត់សម្គាល់។ មិនត្រឹមតែប៉ុណ្ណោះ ជាពិសេសនៅក្នុងរាជធានីភ្នំពេញ គឺអ្នកប្រើប្រាស់រថយន្តក្នុងមធ្យោបាយធ្វើដំណើរ គឺមានអត្រាខ្ពស់។ នៅក្នុងនោះផងដែល ប្រទេសកម្ពុជា ត្រូវបានសង្កេតឃើញថាមានរថយន្តជាច្រើនពិសេស ប្រភេទឡានគឺមានច្រើនប្រភេទ ដែលនៅក្នុងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកនៅព្រះរាជាណាចក្រកម្ពុជាបាន រាប់បញ្ចូលនូវប្រភេទឡានដូចជា រថយន្តដឹកជញ្ជូនអ្នកដំណើរធុនតូច, រថយន្តដឹកអ្នកដំណើរធុនធំ, យានយន្ត, រថយន្តគ្រួសារ, រថយន្តធុនស្រាល, រថយន្តធុនធ្ងន់,រថយន្តក្រុង,រថយន្តកសិកម្មកែច្នៃ, យានយន្តបករណ៍ និងរថយន្តធ្វើអាជីវកម្មដឹកជញ្ជូនទំនិញនិងអ្នកដំណើរ។[5] មិនត្រឹមតែប៉ុណ្ណោះក៏មានរថយន្តជាច្រើនប្រភេទផងដែរត្រូវបានយក កែច្នៃសម្រាប់ប្រើប្រាស់ ក្នុងនោះមានរថយន្តមួយចំនួនមានការកែច្នៃ ខុសស្តង់ដារបច្ចេកទេស។

ប្រភេទរថយន្តទាំងអស់នេះកំពុងតែមានសកម្មភាព និងមានការនាំចូលនៅក្នុងប្រទេសកម្ពុជាជាច្រើន។ ក្នុងនោះផងដែរជាពិសេសយានយន្ត មានជាបញ្ហាមួយចំនួន លើការប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ ខូចខាតទ្រព្យសម្បត្តិសាធារណៈ និងបង្កនូវគ្រោះថ្នាក់ចរាចរណ៍ដែលមានចំនួនអ្នកស្លាប់ និងរបួសជាច្រើន។

នៅក្នុងរបាយការណ៍របស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក បានបង្ហាញទិន្នន័យយ៉ាងច្បាស់ពី ការកើនឡើងនូវប្រជាជនធៀប នឹងចំនួនយានយាន្តចុះបញ្ជី គឺមាន ចំនួនប្រជាជនកើនឡើង ១៨% និងយានយន្តចុះបញ្ជី ៥៣% ក្នុងឆ្នាំ២០១៦។[6] មិនត្រឹមតែប៉ុណ្ណោះ របាយការណ៍ពីក្រសួងសាធារណការ និងដឹកជញ្ជូន បានផ្តល់ជាទិន្នន័យជាលេខ នៅចុងឆ្នាំ

[4] អនុក្រឹត្យលេខ ២៩, អនក្រ, បក,ស្តីពីការកែប្រែឧបសម្ពន្ធអនុក្រឹត្យលេខ១០៩ អនក្រ,បក ចុះថ្ងៃទី ១៨ មីនា ឆ្នាំ២០១៣ ស្តីពីបែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវ និងលេខផ្លូវនិងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦

[5] ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក, ជំពូកទី១បទប្បញ្ញត្តិទូទៅ មាត្រា៤ *(ភ្នំពេញ៖ ២៦ ខែមករា ឆ្នាំ២០១៧)*

[6] របាយការណ៍ស្តីពីជនរងគ្រោះ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៦, ៣.១ ចំនុចសំខាន់នៃការវិវត្តទិន្នន័យ

២០១៧ មានចំនួនយានយន្តជាង ៤លានគ្រឿង បានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ និងរថយន្តមានជិត ១លានគ្រឿង។[7]

### ១.៣.២ ម៉ូតូ

ការប្រើប្រាស់មធ្យោបាយធ្វើដំណើរនៅប្រទេសកម្ពុជា គឺត្រូវបានប្រជាពលរដ្ឋជ្រើសរើស និងទិញយកមកប្រើប្រាស់ទៅតាមលទ្ធភាពនៃថវិការបស់ពួកគាត់។ មិនថានៅតាមជនបទស្រុកស្រែចម្ការ ឬទីរួមខេត្តក្រុង យើងសង្កេតឃើញថាប្រជាពលរដ្ឋមានការប្រើប្រាស់ម៉ូតូ ក្នុងមធ្យោបាយធ្វើដំណើរយ៉ាងច្រើន និងមានគ្រប់ប្រភេទគ្រប់សេរី។

នៅក្នុងនោះផងដែរ គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកបានឲ្យនិយមន័យទៅលើម៉ូតូថា ជាយានកង់ពីរដែលមានម៉ាស៊ីន។[8] នៅក្នុងប្រភេទនៃម៉ូតូនេះផងដែលយើងសង្កេតឃើញថាប្រជាពលរដ្ឋកម្ពុជាជាច្រើនបានប្រើប្រាស់ម៉ូតូដែលមានទំហំស៊ីឡាំង ចាប់ពី ១១០ ឡើងទៅ និងមានជាច្រើនប្រភេទម៉ាក និងសេរី។[9] ថែមទាំងមានការកែច្នៃម៉ូតូមួយចំនួនយកទៅធ្វើដំណើរដែលមាន លក្ខណៈខុសស្តង់ដាបច្ចេកទេស ដែលជាហេតុបង្កឲ្យមានផលប៉ះពាល់ជាច្រើនក្នុងសង្គមខ្មែរបច្ចុប្បន្នផងដែរ។

ថ្មីលើសពីនេះទៀតសោត នៅលើដងផ្លូវបច្ចុប្បន្ន គឺមានប្រភេទរថយន្តដែលមានកង់ចំនួន៣ និងបានប្រើប្រាស់ទំហំស៊ីឡាំង ខុសៗគ្នា និងកំពុងមានចរាចរណ៍នៅលើដងផ្លូវ ក្នុងប្រទេសកម្ពុជា។ នៅបច្ចុប្បន្នចំនួននៃការប្រើប្រាស់ យានយន្តជាពិសេសម៉ូតូមានចំនួនកើនឡើងខ្លាំង ដែលជាកត្តាមួយចំនួនធ្វើឲ្យប៉ះពាល់ដល់ បរិស្ថាន សុវត្ថិភាពសាធារណៈ និងមានការកកស្ទះយ៉ាងខ្លាំងនៅលើដង ផ្លូវ។ ការស្វែងរក និងការប្រើប្រាស់របស់ប្រជាពលរដ្ឋគឺមានលក្ខណៈខុសគ្នាៗ ខ្លះជ្រើសរើសម៉ូតូ ដោយប្រើ ចង្កឹះលេខ ខ្លះប្រើដោយចង្កឹះលេខអូតូ និងចង្កឹះលេខអង់រីយ៉ា និងទៅតាមសេរី នៃជំនាន់ បច្ចេកវិទ្យាថ្មី។ ដោយយោងទៅតាមប្រសាសន៍ របស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន បានឲ្យដឹងថា ចំនួនម៉ូតូសរុបនៅកម្ពុជាមានចំនួន ៣លាន ២សែនគ្រឿងដែល ជាតួលេខខ្ពស់នៅ កម្ពុជា និងមានការកើនឡើង ៣០ម៉ឺនគ្រឿង រៀងរាល់ឆ្នាំ។[10]

---

[7] ទស្សនាវត្តីខ្លីៗ, កម្ពុជាមានយានយន្តជាង៤លានគ្រឿងបានចុះបញ្ជីត្រឹមត្រូវ (ភ្នំពេញ៖ ទស្សនាវត្តីខ្លី ថ្ងៃច័ន្ទ,១៨ធ្នូ ឆ្នាំ ២០១៧, ១៦៖៤២) អាចរកបាន http://kleykley.sabay.com.kh/article/999231

[8] របាយការណ៍ស្តីពីជនរងគ្រោះ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៦, សន្ទានុក្រម

[9] ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក, ជំពូកទី៣ អ្នកបើកបរយានជំនិះ មាត្រា៨ថ្មី *(ភ្នំពេញ៖ ២៦ ខែមករា ឆ្នាំ២០១៧)*

[10] ទស្សនាវត្តីថ្មីៗ, កម្ពុជាមានកំណើនម៉ូតូចំនួន៣០មឺនគ្រឿងក្នុងមួយឆ្នាំ (ថ្ងៃទី២ ខែមករា ឆ្នាំ២០១៧, ១១៖៣៩) អាចរកបាន https://thmeythmey.com/?page=detail&id=48140

### ១.៣.៣ កង់

នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ជាពិសេសតាមដងផ្លូវយើងសង្កេតឃើញថា មិនសូវមានភាពមមារញឹក ដែលបង្កឲ្យមានផលវិបាកអ្វីឡើយ។ ជាទូទៅប្រជាពលរដ្ឋខ្មែរមួយចំនួននៅទីក្រុងបានជ្រើសរើសការប្រើប្រាស់ កង់ក្នុងការហាត់កីឡា នៅតាមសួនច្បារ និងដងផ្លូវ។ នៅតាមជនបទស្រុកស្រែចម្ការ ប្រជាជនបានប្រើប្រាស់មធ្យោបាយធ្វើដំណើរដោយ កង់ ជាពិសេសសម្រាប់ប្រជាជនដែលមានចំនូលទាប ឬមធ្យម។ យើងសង្កេតឃើញថា មានកុមារជាច្រើនបានជ្រើសរើសកង់ក្នុងការ ប្រើប្រាស់សម្រាប់ធ្វើមធ្យោបាយក្នុងការធ្វើដំណើរទៅសាលារៀន ស្រែ ចម្ការ។ល។

កង់ ត្រូវបានចាត់ចូលជាយាន្តជំនិះមួយប្រភេទដែលមានការយកចិត្តទុកដាក់ និងមានច្បាប់ការពារ ថែមទាំងមានការយកចិត្តទុកពីសំណាក់រាជរដ្ឋាភិបាល ព្រមទាំងមានការគិតគូរលើជ្រុងជ្រោយពីក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំឲ្យមានសួនច្បារ ផ្លូវ គំនូសសញ្ញា និងការការពារ បង្ការគ្រោះថ្នាក់ណាមួយ។ មិនត្រឹមតែប៉ុណ្ណោះ ការប្រើប្រាស់កង់ជាមធ្យោបាយមួយដ៏ល្អក្នុងការ ដោះស្រាយបញ្ហាកកស្ទះនៅលើដងផ្លូវ ព្រមទាំងមានការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ថែមទាំងមានសុខភាពល្អផងដែរលើការហាត់ប្រាណ។

នៅសព្វថ្ងៃក្នុងព្រះរាជាណាចក្រកម្ពុជា កង់ត្រូវបានកំពុងពេញនិយមចំពោះរាល់ស្រទាប់យុវ័យ មិនថាក្មេង មិនថាចាស់បានជ្រើសរើសកង់ ក្នុងការធ្វើដំណើរប្រកបការងារ រកស៊ី និងហាត់ប្រាណ។ ដោយឃើញជាក់ស្តែង មានម៉ាកល្បីៗនៅក្រៅប្រទេសបាននាំចូលកង់ទំនើបៗ និងមានបច្ចេកវិទ្យា ទំនើបៗ ដោយបំពាក់អាគុយ និងសូឡាអគ្គិសនី ដែលមានតម្លៃសមរម្យ។

### ១.៣.៤ ថ្មើរជើង

ក្នុងការធ្វើដំណើរដោយការប្រើប្រាស់ជើងទាំងពីររបស់យើងម្នាក់ៗ ដើម្បីឆ្ពោះទៅទីតាំងណាមួយគឺត្រូវបាន ប្រជាពលរដ្ឋខ្មែរមានការចូលចិត្ត និងពេញចិត្ត ដោយពួកគាត់គិតថាជាការហាត់ប្រាណ។ ការថ្មើរជើងគឺត្រូវបានសង្កេតឃើញថា មានភាពមមាញឹក ជាពិសេសពេលព្រឹកព្រលឹម និងពេលល្ងាច។ ក្នុងមធ្យោបាយថ្មើរជើងនេះផងដែល ប្រជាពលរដ្ឋខ្មែរជ្រើសរើស ដោយគិតទៅលើទីតាំងដែលមានរយៈចម្ងាយជិត និងចង់ធ្វើលំហាត់ប្រាណ។

ក្នុងទិដ្ឋភាពសព្វថ្ងៃលើដងផ្លូវ ការថ្មើរជើងនេះត្រូវបានរាជរដ្ឋាភិបាល បានគិតគូរដល់សុវត្ថិភាពរបស់ប្រជាពលរដ្ឋ ដោយដូចជាស្ពានអាកាសថ្មើរជើង គំនូសសញ្ញា ភ្លើងស្តុប និងមានរបបចំណីផ្លូវក្នុងការផ្តល់ភាពងាយស្រួលដល់អ្នកថ្មើរជើង។ មិនត្រឹមតែប៉ុណ្ណោះយើងសង្កេតឃើញថា ការធ្វើដំណើរដោយថ្មើរជើងនេះ មិនសូវមាននូវបញ្ហា ឬគ្រោះថ្នាក់ដល់អាយុជីវិតច្រើននោះទេ។

## ១.៤.ប្រភពទិន្នន័យ និងអ្នករងគ្រោះនៃគ្រោះថ្នាក់ចរាចរណ៍

គ្រោះថ្នាក់ចរាចរណ៍បានកើតឡើងជារៀងរាល់ថ្ងៃ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបានឆក់យកអាយុជីវិតប្រជាពលរដ្ឋខ្មែរជារៀងរាល់ថ្ងៃ។ គ្រោះថ្នាក់ចរាចរណ៍នេះផងដែលបានបង្កឲ្យមាន ចំនួនអ្នកស្លាប់ និងអ្នករងរបួសនៅតាមបណ្តោយផ្លូវសាធារណៈ។ នៅក្នុងការប្រមូលទិន្នន័យព័ត៌មានបង្ហាញពីភាពជាក់លាក់ ជាប់បន្ត និងទូលំទូលាយ ដល់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានាក្នុងការរៀបចំងក្រងច្បាប់ គោលនយោបាយ ផែនការ សកម្មភាព និងការវាយតម្លៃ នូវផលប៉ះពាល់ស្តីពីគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកនាពេលកន្លងមក រហូតមកដល់បច្ចុប្បន្ន និងទៅអនាគត។

នៅក្នុងរបាយការណ៍ស្តីពីគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកឆ្នាំ២០១៦ បានកំណត់និយមន័យថា គ្រោះថ្នាក់ដែលមានយានជំនិះ យ៉ាងតិចមួយគ្រឿង (កំពុងធ្វើចរាចរលើផ្លូវថ្នល់) និងបង្កឲ្យមានមនុស្សរងរបួស ស្លាប់ យ៉ាងតិចមួយនាក់។ លំហូរនៃការប្រមូលទិន្នន័យនៃប្រព័ន្ធព័ត៌មានជនរងគ្រោះ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក២០១០-២០១៦៖

រូបខាងក្រោមនៃការប្រមូលទិន្នន័យប្រព័ន្ធព័ត៌មានជនរងគ្រោះ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ២០១០-២០១៦[11]




[11] ដកស្រង់ពី របាយការណ៍ស្តីជនរងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៦

គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកគឺ ត្រូវបានច្របាច់ចូលគ្នារវាងទិន្នន័យពីរប្រភព (នគរបាលចរាចរណ៍ និងមន្ទីរពេទ្យ មណ្ឌលសុខភាព)។ដើម្បីជៀសវាង ការបញ្ចូលស្ទួនគ្នារវាងទិន្នន័យរបស់មន្ទីរពេទ្យ ឬមណ្ឌលសុខភាព និងនគរបាលចរាចរណ៍ ពេលដែលជនរងគ្រោះម្នាក់បានរាយការណ៍ទាំងមន្ទីរពេទ្យ មណ្ឌលសុខភាព និងនគរបាលចរាចរណ៍ផ្លូវគោក ទិន្នន័យនោះត្រូវរក្សាទុកតែមួយគត់។

## ១.៥ ទិដ្ឋភាពផ្លូវច្បាប់

បើយើងសង្កេតមើលទិដ្ឋភាពច្បាប់ដែលពាក់ព័ន្ធ និងចរាចរណ៍ផ្លូវគោកក្នុងសង្គមខ្មែរយើងគឺមាន ច្បាប់ សេចក្តីណែនាំ សារាចរ សេចក្តីណែនាំ សេចក្តីជូនដំណឹង និងយុទ្ធនាការផ្សេងៗដែលស្របទៅតាមបរិបទនៃស្ថានភាពចរាចរណ៍ និងដំណោះស្រាយ សកម្មភាពផ្សេងៗដែលមាននៅក្នុងប្រទេសកម្ពុជាយើង។

ជាក់ស្តែងនៅព្រះរាជាណាចក្រកម្ពុជាគឺមានច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែលត្រូវបានធ្វើវិសោធនកម្ម កែប្រែបំពេញបន្ថែមជាច្រើន ដោយប្រើប្រាស់ជាចុងក្រោយនៅក្នុងនៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧។ ថែមទាំងមានគោលនយោបាយថ្នាក់ជាតិ និងតាមក្រសួងស្ថាប័ន អង្គការផ្សេងៗទាំងក្នុងជួររាជរដ្ឋាភិបាល និងក្រៅរាជរដ្ឋាភិបាល ព្រមទាំងដៃគូអន្តរជាតិបានគិតគូរ និងមានយុទ្ធនាការ ផ្សេងៗ ដែលមានស្រាប់ និងកំពុងសិក្សាបំពេញបន្ថែមទាក់ទងនឹងចរាចរណ៍ផ្លូវគោកនេះ។ កាន់តែពិសេសជាងនេះទៅទៀត ក៏មានពាក្យស្លោកជាច្រើន ដែលក្នុងនោះពាក្យស្លោកសំខាន់បំផុត របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អនុសាសន៍នូវពាក្យស្លោកពាក់ព័ន្ធនឹងចរាចរណ៍ផ្លូវគោកថា “ **ថ្ងៃនេះ ថ្ងៃស្អែកគ្មានគ្រោះថ្នាក់ចរាចរណ៍** ”។[12]

### ច្បាប់ស្តីចរាចរណ៍ផ្លូវគោកនៃ ព្រះរាជាណាចក្រកម្ពុជា

នៅក្នុងទិដ្ឋភាពច្បាប់នេះផងដែរ ចំនុចសំខាន់ៗមួយចំនួននៃច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោកនៃ ព្រះរាជាណាចក្រកម្ពុជាដែលមានសារៈសំខាន់ និងជាពិសេសទណ្ឌកម្មនៃច្បាប់ដែលបានចែង។

[12] ទស្សនាវត្តីកោះសន្តិភាព, ថ្ងៃនេះ ថ្ងៃស្អែកគ្មានគ្រោះថ្នាក់ចរាចរណ៍អនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាលបិទនូវគ្រប់ទីតាំងនៅក្នុងក្រុងប៉ោយប៉ែត (ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៣ ម៉ោង ២៖៥០) អាចចូលមើលបាន https://kohsantepheapdaily.com.kh/article/66738.html

យោងទៅតាមព្រះរាជក្រម ប្រកាសឲ្យប្រើ ច្បាប់ស្តីពីវិសោធនកម្ម មាត្រាមួយចំនួន និង ពិនិត្យចប់សព្វគ្រប់កាលពីថ្ងៃទី៩ ខែមករា ឆ្នាំ២០១៧ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក បានចែង យ៉ាងច្បាស់ពីមាត្រានីមួយៗ ដែលក្នុងនោះរួមមាន៖

មាត្រា១៖ ច្បាប់នេះមានគោលបំណងធានាសុវត្ថិភាព សណ្តាប់ធ្នាប់ចរាចរណ៍ផ្លូវគោក និង ធានាការពារសុខភាពនិងអាយុជីវិតមនុស្ស សត្វ ទ្រព្យសម្បត្តិ និងបរិស្ថាន។[13]

មាត្រា២៖ ច្បាប់នេះមានគោលដៅដូចតទៅ៖

-ផ្តល់ការយល់ដឹងអំពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក

-គ្រប់គ្រងសុវត្ថិភាពចរាចរណ៍ផ្លូវគោក

-រក្សាសណ្តាប់ធ្នាប់ចរាចរណ៍ផ្លូវគោក

-ទប់ស្កាត់ការប្រព្រឹត្តបទល្មើសដែលបណ្តាលមកពីការប្រើប្រាស់ផ្លូវថ្នល់។[14]

លើសពីនេះទៀតសោតត្រង់ចំនុចនៃការប្រើប្រាស់ផ្លូវថ្នល់ក៏មានការកំណត់ទោស ទណ្ឌផង ដែរ។ នៅក្នុងការប្រើប្រាស់ផ្លូវថ្នល់មានមាត្រាជាច្រើនបានកំណត់ទោសទណ្ឌជាពិសេសអ្នកដែល ប្រព្រឹត្តបទល្មើសក្នុងច្បាប់ខាងលើ ដែលក្នុងនោះមានដូចជា ក្នុងជំពូកទី១០ អំពីទោសប្បញ្ញត្តិ មាត្រា៨៣ បានចែងថា ជនណាបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរព កាតព្វកិច្ចដែលបទប្បញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកតម្រូវ បណ្តាលឲ្យមានរបួសដល់អ្នកដទៃ ហើយ បណ្តាលឲ្យអ្នករងគ្រោះអសមត្ថភាពការងារក្នុងរយៈពេលស្មើ ឬលើពី៨(ប្រាំបី)ថ្ងៃ គិតពីថ្ងៃកើត ហេតុ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ ២ ០០០ ០០០ (ពីរលាន)រៀល ទៅ ១០ ០០០ ០០០(ដប់លាន)រៀល និងអាចត្រូវផ្តន្ទាទោសដោយទោសបន្ថែម មួយឬច្រើន ដូចមានចែងក្នុងមាត្រា ៥៣ (ប្រភេទនៃទោសបន្ថែម)នៃក្រមព្រហ្មទណ្ឌ។ អំពើល្មើស ខាងលើនេះត្រូវ ផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ ៤ ០០០ ០០០(បួនលាន)រៀល ទៅ ១៥ ០០០ ០០០ (ដប់ប្រាំលាន)រៀល កាលបើអំពើនេះបាន ប្រព្រឹត្ត ក្នុងករណីណាមួយដូចខាងក្រោម៖

ក- បើកបរដោយគ្មានប័ណ្ណបើកបរឬមានប័ណ្ណបើកបរតែមិនត្រឹមត្រូវតាមប្រភេទ យានយន្ត។

ខ- ស្ថិតក្នុងស្ថានភាពស្រវឹងដោយមានអត្រាមានជាតិអាលកុលចាប់ពី ០,៤០ (សូន្យក្បៀស សែសិប) មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៨០ (សូន្យក្បៀសប៉ែតសិប)ក្រាមក្នុងមួយលីត្រ ឈាមឡើងទៅ។

---

[13] ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក, ជំពូកទី១ បទប្បញ្ញត្តិទូទៅ *(ភ្នំពេញ៖ ២៦ ខែមករា ឆ្នាំ២០១៧)*

[14] ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក, ជំពូកទី១ បទប្បញ្ញត្តិទូទៅ (ភ្នំពេញ៖ ២៦ ខែមករា ឆ្នាំ២០១៧)

គ-បណ្តាលឲ្យមានរបួសច្រើននាក់។

ឃ- រត់គេចខ្លួនពីកន្លែងកើតហេតុក្នុងគោលបំណងគេចវេសពីការទទួលខុសត្រូវ។

ចំពោះបទល្មើសនេះដែលមានក្នុងមាត្រាទោសបន្ថែម ដូចតទៅនេះអាចត្រូវបានប្រកាសៈ

១- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះត្រូវបានប្រព្រឹត្តនៅក្នុង ការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសក្នុងការប្រកបវិជ្ជាជីវៈ ជាស្ថាពរ ឬសម្រាប់ក្នុងរយៈពេល ៥(ប្រាំ)ឆ្នាំយ៉ាងច្រើន។

២- ការហាមឃាត់ចំពោះការបើកបរយានយន្ត ទោះបីជាប្រភេទណាក៏ដោយសម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំយ៉ាងច្រើន។

៣- ការព្យួរលិខិតបើកបរ សម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំយ៉ាងច្រើន។

៤- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសសម្រាប់រយៈពេល២(ពីរ)ខែយ៉ាងច្រើន។

៦- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល៨(ប្រាំបី)ឆ្នាំយ៉ាងច្រើន។[15]

នៅក្នុងការប្រព្រឹត្តទៅលើក៏មានផងដែលនូវទោសទណ្ឌក្នុងច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោកនៃព្រះរាជាណាចក្រកម្ពុជា ដូច មាត្រា៨៥ ជនណាបើកបរធ្វេសប្រហែស ខ្ជីខ្ជារ មិនប្រុងប្រយ័ត្នឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកតម្រូវបណ្តាលឲ្យស្លាប់អ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ ៣ (បី)ឆ្នាំ និងពិន័យជាប្រាក់ ៤ ០០០ ០០០ (បួនលាន)រៀល ទៅ ១៥ ០០០ ០០០ (ដប់ប្រាំលាន)រៀល និងអាចផ្តន្ទាទោសពន្ធនាគារពី ២(ឆ្នាំ)ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាប់ ១០ ០០០ ០០០ (ដប់លាន)រៀល ទៅ ២៥ ០០០ ០០០(ម្ភៃប្រាំលាន)រៀល កាលបើអំពើនេះបានប្រព្រឹត្តក្នុង ករណីណាមួយខាងក្រោមៈ

ក- បើកបរដោយគ្មានប័ណ្ណបើកបរឬ មានប័ណ្ណបើកបរតែមិនត្រឹមត្រូវ តាមប្រភេទយានយន្ត

ខ-ស្ថិតក្នុងស្ថានភាពស្រវឹងដោយមានអត្រាជាតិអាល់កុល ០,៤០ (សូន្យក្បៀសសែសិប) មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៨០ (សូន្យក្បៀសប៉ែតសិប)ក្រាមក្នុងមួយលីត្រឈាមឡើងទៅ។

គ- បណ្តាលឲ្យមានអ្នកស្លាប់មនុស្សច្រើននាក់។

ឃ- រត់គេញខ្លួនពីកន្លែងកើតហេតុក្នុងគោលបំណងគេចវេសពីការទទួលខុសត្រូវ។

---

[15] ច្បាប់ស្តីចរាចរណ៍ផ្លូវគោក, ជំពូកទី១០ ទោសប្បញ្ញត្តិ មាត្រា៨៣ (ភ្នំពេញៈ ២៦ ខែមករា ឆ្នាំ២០១៧)

ចំពោះបទល្មើសដែលមានចែងក្នុងមាត្រានេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស៖

១- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះជាស្ថាពរ ឬសម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំយ៉ាងច្រើន។

២- ការហាមឃាត់ចំពោះការបើកបរយានយន្ត ទោះបីជាប្រភេទណាក៏ដោយសម្រាប់រយៈពេល៥ (ប្រាំ)ឆ្នាំយ៉ាងច្រើន។

៣- ការព្យួរលិខិតបើកបរ សម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំយ៉ាងច្រើន។

៤- ការបិទសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល២(ពីរ)ខែយ៉ាងច្រើន។

៥- ការផ្សព្វផ្សាយសេចក្តីផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

៦- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគនិ សោតទស្សន៍ សម្រាប់រយៈពេល ៨(ថ្ងៃ)យ៉ាងច្រើន។[16]

មាត្រា៣៖ ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាពពាក់ព័ន្ធ នឹងចរាចរណ៍ផ្លូវគោកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[17] ក្នុងន័យនេះផងដែលក៏មានមាត្រាមួយចំនួនដែលប្រហាក់ប្រហែល និងកំណត់ដាក់ទណ្ឌកម្ម ចំពោះការមិនគោរពច្បាប់ ឬធ្វើឲ្យប៉ះពាល់ដល់អ្នកអនុវត្តច្បាប់ដូចជា មន្ត្រីមានសមត្ថកិច្ច ដែលក្នុងនោះមានដូចជា មាត្រា៧១ បទល្មើសដែលត្រូវផ្តន្ទាទោសពិន័យ អន្តរការ ត្រូវកំណត់ដោយអនុក្រឹត។[18] មាត្រា ៧២ អ្នកបើកបរ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសដែលខ្លួនប្រព្រឹត្តក្នុងការបើកបរយានជំនិះ។ អ្នកគ្រប់គ្រងឬ កម្មសិទ្ធិករត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ក្នុងករណីយានជំនិះរបស់ខ្លួនបានបង្កឲ្យគ្រោះថ្នាក់ដល់អ្នកដទៃ។[19] នៅក្នុងទិន្នភាពច្បាប់បានបញ្ជាក់ពីគំនូសសញ្ញាចរាចរណ៍ ផ្លាកសញ្ញាចរាចរណ៍ និងបំរាមមួយចំនួនដូចមានក្នុង មាត្រា៥ សញ្ញាចរាចរណ៍ផ្លូវគោករួមមានផ្លាកសញ្ញាចរាចរណ៍នៅតាមដងផ្លូវ ភ្លើងសញ្ញាចរាចរណ៍គំនូសសញ្ញាចរាចរណ៍នៅលើដងផ្លូវ សញ្ញាបញ្ជាក់របស់ភ្នាក់ងារចរាចរណ៍ និងសញ្ញាផ្សេង២ទៀត។

[16] ច្បាប់ស្តីចរាចរណ៍ផ្លូវគោក, ជំពូកទី១០ ទោសប្បញ្ញត្តិ មាត្រា៨៥ (ភ្នំពេញ៖ ២៦ ខែមករា ឆ្នាំ២០១៧)

[17] ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក, ជំពូកទី១ បទប្បញ្ញត្តិទូទៅ មាត្រា៣ (ភ្នំពេញ៖ ២៦ ខែមករា ឆ្នាំ២០១៧)

[18] ច្បាប់ស្តីចរាចរណ៍ផ្លូវគោក, ជំពូកទី១០ ទោសប្បញ្ញត្តិ មាត្រា៧១ (ភ្នំពេញ៖ ២៦ ខែមករា ឆ្នាំ២០១៧)

[19] ច្បាប់ស្តីចរាចរណ៍ផ្លូវគោក, ជំពូកទី១០ ទោសប្បញ្ញត្តិ មាត្រា៧២ (ភ្នំពេញ៖ ២៦ ខែមករា ឆ្នាំ២០១៧)

ផ្លាកសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ និងគំនូសសញ្ញាចរាចរណ៍នៅលើដងផ្លូវ ត្រូវរៀបចំដោយប្រព័ន្ធទាក់ទងស៊ីចង្វាក់គ្នាជាច្រើននៅតាមកន្លែងមានសារប្រយោជន៍ ដែលធ្វើឲ្យអ្នកប្រើប្រាស់ផ្លូវងាយស្រួលមើលផ្លូវ ងាយស្រួលមើលឃើញ។

សញ្ញាគ្រោះថ្នាក់នៅតាមដងផ្លូវដែលមានលក្ខណៈមិនអចិន្ត្រៃយ៍ ត្រូវដាក់ក្នុងចម្ងាយសមស្រប ល្មមគ្រប់គ្រាន់តាមប្រភេទផ្លូវ ចំណាត់ថ្នាក់ផ្លូវ និងស្ថានភាពផ្លូវ ដែលអាចធ្វើឲ្យអ្នកបើកបរមានស្មារតីប្រុងប្រយ័ត្នជាមុនបាន។

ហាមបិទក្រដាសឬ របស់ផ្សេងៗទៀត ឬគូសវាសលើស្លាកសញ្ញា ឬប្រើប្រាស់ទម្រផ្លាកសញ្ញា ឬនៅលើសម្ភារៈអ្វីផ្សេងៗទៀតដែលប្រើប្រាស់សម្រាប់សញ្ញាចរាចរណ៍ ដែលជាហេតុធ្វើឲ្យអ្នកបើកបរ មិនអាចមើលឃើញសញ្ញាចរាចរណ៍ច្បាស់បានល្អ ឬយល់ខ្លឹមសារសញ្ញាចរាចរណ៍មិនបានត្រឹមត្រូវ ឬធ្វើ ឲ្យអ្នកបើកបរចាំងភ្នែក។

រូបភាពនិងខ្លឹមសារស្តីពីចរាចរណ៍មានសិទ្ធិអាទិភាពលើភ្លើងសញ្ញាចរាចរណ៍ផ្លូវគោក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណៈការនិងដឹកជញ្ជូន។[20]

នៅក្នុងច្បាប់ស្តីចរាចរណ៍ផ្លូវគោកក្នុងប្រទេសកម្ពុជាដដែល ក៏មានមាត្រាមួយដែលបានបង្ហាញច្បាស់ពី មន្ត្រីអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក ដែលក្នុងនោះរួមមាន នៅក្នុង មាត្រា ៦០ មន្ត្រីអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោករួមមាន៖

១- មន្ត្រីមកពីក្រសួងសាធារណការនឹងដឹកជញ្ជូន

២-អង្គភាពនគរបាលឬកងរាជអាវុធហត្ថដែលទទួលបន្ទុក រៀបចំសណ្តាប់ធ្នាប់ សុវត្ថិភាពចរាចរណ៍ មានភារកិច្ច៖

- ចាត់ចែងចរាចរណ៍ឲ្យមានសណ្តាប់ធ្នាប់ល្អ
- តាមដាន ល្បាត និងពិនិត្យអំពើល្មើសនឹងបទប្បញ្ញត្តិចរាចរណ៍ដោយផ្ទាល់ឬដោយឧបករណ៍បច្ចេកទេស
- ធ្វើរបាយការណ៍ស្តីពីសភាការណ៍សណ្តាប់ធ្នាប់ចរាចរណ៍បទល្មើសចរាចរចណ៍ និងគ្រោះថ្នាក់ចរាចរណ៍ដែលកើតមានឡើង។

ដោយឡែក អង្គភាពនគរបាលដែលទទួលបន្ទុករៀបចំសណ្តាប់ធ្នាប់សុវត្ថិភាពចរាចរណ៍មានភារកិច្ចបន្ថែម៖

- ពិន័យជាប្រាក់ចំពោះបទល្មើសដែលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍
- សម្រុះសម្រួលក្នុងករណីគ្រោះថ្នាក់ចរាចរណ៍ដូចមានចែងក្នុងមាត្រា៦៥ នៃច្បាប់នេះ

[20] ច្បាប់ស្តីចរាចរណ៍ផ្លូវគោក, ជំពូកទី២ សញ្ញាចរាចរណ៍ មាត្រា៥ (ភ្នំពេញ៖ ២៦ ខែមករា ឆ្នាំ២០១៧)

-ត្រួតពិនិត្យនិងកត់ត្រាដំណើរហេតុនៅពេលមានគ្រោះថ្នាក់ចរាចរណ៍ ក្នុងករណីចាំបាច់ ធ្វើការដកហូតបណ្ដោះអាសន្នក្នុងការបើកបរ និងឃាត់យានជំនិះតាមមាត្រា៦២ មាត្រា៦៦ និងមាត្រា៦៧នៃច្បាប់នេះ។

- រៀបចំនិងបញ្ជូនកំណត់ហេតុព្រមទាំងវត្ថុតាងទៅអយ្យការអមសាលាដំបូងក្នុងករណីកំណត់ដោយច្បាប់នេះ។[21]

**គោលនយោបាយជាតិស្ដីពីចរាចរណ៍ផ្លូវគោក**

គោលនយោបាយជាតិស្ដីពីចរាចរណ៍ផ្លូវគោកមានគោលបំណង ធានាឲ្យមានសុវត្ថិភាពសណ្ដាប់ធ្នាប់សុវត្ថិភាពចរាចរណ៍ផ្លូវគោក និងទប់ស្កាត់ការប៉ះពាល់សុខភាព អាយុជីវិតមនុស្សសត្វ ទ្រព្យសម្បត្តិ និងបរិស្ថាន។ នៅក្នុងគោលនយោបាយនេះក៏មានគោលដៅជាច្រើនដើម្បីឲ្យមានប្រសិទ្ធភាព ដែលមានដូចជា បង្កើនប្រសិទ្ធភាណសេវាសង្គ្រោះ សុវត្ថិភាពយានយន្ត ហេដ្ឋារចនាសម្ពន្ធផ្លូវថ្នល់ ប្រសិទ្ធភាពច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក និងបង្កើនការយល់ដឹងពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក។[22]

នៅក្នុងគោលនយោបាយស្ដីសុវត្ថិភាពចរាចរណ៍ផ្លូវគោក នេះផងដែលបានដាក់ផែនការសកម្មភាពយ៉ាងច្បាស់សម្រាប់ឆ្នាំ ២០១១-២០២០ ក្នុងនោះមាន៖

- គ្រប់គ្រងសុវត្ថិភាពចរាចរណ៍
- សុវត្ថិភាពហេដ្ឋារចនាសម្ពន្ធផ្លូវថ្នល់
- សុវត្ថិភាពយានយន្ត
- អាកប្បកិរិយាប្រកបដោយសុវត្ថិភាពរបស់អ្នកប្រើប្រាស់ផ្លូវថ្នល់
- ប្រព័ន្ធសង្គ្រោះបន្ទាន់វេជ្ជសាស្ត្រ
- វិសោធនកម្មច្បាប់ និងការពង្រឹកការអនុវត្តច្បាប់
- ប័ណ្ណបើកបរ
- ការគ្រប់គ្រង និងវាយតម្លៃទៅលើសុវត្ថិភាពដឹកជញ្ជូនអ្នកដំណើរ និងទំនិញ។[23]

[21] ច្បាប់ស្ដីចរាចរណ៍ផ្លូវគោក, ជំពូកទី៩ សមត្ថកិច្ចនិងសិទ្ធអំណាចរបស់មន្ត្រីអនុវត្តច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក មាត្រា៦០ (ភ្នំពេញ៖ ២៦ ខែមករា ឆ្នាំ២០១៧)

[22] គោលនយោបាយជាតិស្ដីសុវត្ថិភាពចរាចរណ៍ផ្លូវគោក (ឯកភាពគណៈរដ្ឋមន្ត្រី ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩)

[23] គោលនយោបាយជាតិស្ដីសុវត្ថិភាពចរាចរណ៍ផ្លូវគោក, ផែនការសកម្មភាព (ឯកភាពគណៈរដ្ឋមន្ត្រី ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩)

គោលនយោបាយនេះពិតជាចូលរួមចំណែកយ៉ាងខ្លាំងក្លា ក្នុងការធានាឲ្យមានសុវត្ថិភាពចរាចរណ៍ផ្លូវគោកនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងផ្តល់ឲ្យមានភាពងាយស្រួលដល់ការចូលរួម និងការអនុវត្តផ្ទាល់។

**យុទ្ធនាការដែលបានដាក់ចេញរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា**

ជាក់ស្តែងយុទ្ធនាការពេលថ្មីៗនេះបានឆ្លុះបញ្ចាំងពីសកម្មភាពមួយចំនួនៗរបស់ រាជរដ្ឋាភិបាលដែលបានដាក់ចេញនូវការរឹតបន្តឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដោយមានប្រសិទ្ធភាពក្នុងនោះរួមមាន៖

-យុទ្ធនាការការរឹតបន្តឹងច្បាប់ចរាចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា៖ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៨ កម្លាំងនគរបាលចរាចរណ៍បានត្រួតពិនិត្យយានយន្ត ចំនួន២,៩១១គ្រឿង រកឃើញល្មើសច្បាប់ ៣៣១គ្រឿង( ម៉ូតូ ៦៧ភាគរយ) អប់រំ១៧៦ គ្រឿង និងផាកពិន័យ១៥៥គ្រឿង បើតាមរបាយការណ៍ផ្លូវការរបស់នាយកដ្ឋាននគរបាលចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។ លើសពីនេះ ចំពោះការត្រួតពិនិត្យមួក និងកញ្ចក់ នៅថ្ងៃទី២៨ ខែមេសានេះ ត្រួត ពិនិត្យរួមបាន ចំនួន១,៣១២ គ្រឿង អប់រំ ៨២គ្រឿង និងផាកពិន័យចំនួន១២៨គ្រឿង។ ដោយឡែកសម្រាប់រាជធានីភ្នំពេញវិញ សមត្ថកិច្ចបានឃាត់យានយន្តចំនួន ៧៩៨គ្រឿង ដែលជិះបញ្រ្ចាស់ មិនពាក់មួកសុវត្ថិភាព មិនដាក់កញ្ចក់ មិនមានស្លាកលេខ។ សរុបរយៈពេល ២៨ ថ្ងៃ ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី២៨ ចាប់បានយានយន្តចំនួន ៨៣,៧០២គ្រឿង រកឃើញយានយន្តល្មើស ១២,១១៩ (ម៉ូតូ៦៧ ភាគរយ) ក្នុងនោះអប់រំ៥,៣០៩ គ្រឿងនិងផាកពិន័យ ៦,៨១០គ្រឿង។[24]

-យុទ្ធនាការអប់រំផ្សព្វផ្សាយស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកមុនឱកាស ចូលឆ្នាំប្រពៃណីខ្មែរ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកសហការជាមួយ សុវត្ថិភាពចរាចរណ៍ផ្លូវគោក នៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ក្រសួងសាធារណការ និងដឹកជញ្ជូន សហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា វិស័យសាធារណការនិងដឹកជញ្ជូន និងយុវជនមកពីមូលនិធិ បង្ការរបួសអាស៊ី AIP Foundation បានចុះធ្វើចុះយុទ្ធនាការសុវត្ថិភាពចរាចរណ៍ពញ្ញាក់

[24] ទស្សនាវដ្តីគេហទំព័រ FRESHNEWS, យុទ្ធនាការរឹតបន្តឹងច្បាប់ចរាចរណ៍ទូទាំង ប្រទេសថ្ងៃទី២៨ខែមេសា៖ ការរកឃើញយានយន្តល្មើសច្បាប់ (ថ្ងៃទី២៨ ខែមេសាឆ្នាំ២០១៨)។

ស្មារតីដល់អ្នកប្រើប្រាស់ផ្លូវឲ្យមានការប្រុងប្រយ័ត្ន នៅក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិ នៅតាមបណ្តាផ្លូវជាតិលេខ ៦ ផ្លូវជាតិលេខ៥ និងផ្លូវជាតិលេខ៦។[25]

អ្វីដែលពិសេសជាងនេះទៅទៀត ដែរព្រះរាជាណាចក្រកម្ពុជាតែងតែប្រារព្ធធ្វើជារៀងរាល់ឆ្នាំ គឺទិវាសប្តាហ៍ជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដែលនៅពេលថ្មីៗនេះ គឺនៅថ្ងៃទី០៦ មេសា ឆ្នាំ ២០១៨ បានប្រារព្ធធ្វើទិវាសប្តាហ៍ជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកលើកទី១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក។[26]

នៅក្នុងចរាចរណ៍ផ្លូវគោកនេះផងដែល ក្រសួងសាធារណការ និងដឹកជញ្ជូន ក៏មានផែនការសកម្មភាពផ្សេងៗដើម្បីឲ្យមានប្រសិទ្ធភាព ក្នុងការសិក្សាស្វែងយល់ពីស្ថានភាពចរាចរណ៍ផ្លូវគោកក្នុង រយៈពេល ៦ឆ្នាំដែលក្នុងនោះមាន ចំណងជើងថា ផែនការសកម្មភាពជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ២០១៤ ក្នុងគោលបំណងជំរុញ និងអនុវត្តនូវសកម្មភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោក ស្របតាមគោលនយោបាយជាតិស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក។[27] នៅក្នុងផែនការសកម្មភាពផងដែល បានសង្កេតឃើញថា មានការធ្វើបណ្តុះបណ្តាលអប់រំ ពីចរាចរណ៍ផងដែលជាពិសេសឃើញមានស្ថាប័នពាក់ព័ន្ធ មន្ត្រីពាក់ព័ន្ធ សហការជាមួយអង្គការក្រៅរាជរដ្ឋាភិបាល បានឲ្យមានការបណ្តុះបណ្តាលពីហានិភ័យ ការបើកបរល្បឿនកំណត់ ដល់យុវជន និងជនបង្គោល ដើម្បីស្របទៅតាមផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលដាក់ចេញ។[28]

នៅក្នុងការបជ្រាបការយល់ដឹងពីទិដ្ឋភាពច្បាប់ របៀបរបរនៃការបើកបរដើម្បីបង្ការការពារទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ដែលកើតឡើងដោយមិនបានដឹងទុកជាមុន ដូចមានជាក់ស្តែងថ្មីៗនេះ នៅចុងឆ្នាំ២០១៧ ក្រសួងសាធារណការ និងដឹកជញ្ជូនបានបោះពុម្ពផ្សព្វផ្សាយការយល់ដឹងពី

[25] ទំព័រដើមគេហទំព័រគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក, យុទ្ធនាការអប់រំផ្សព្វផ្សាយស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក មុនឱកាសពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ឆ្នាំ២០១៨, អាចរកបាន http://www.nrsc.gov.kh/?page=detail&ctype=article&id=1425&lg=kh

[26] ទំព័រដើមគេហទំព័រគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក, ទិវាសប្តាហ៍ជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកលើកទី១១, អាចរកបាន http://www.nrsc.gov.kh/?page=detail&ctype=article&id=1424&lg=kh

[27] ដកស្រង់ចេញពី សៀវភៅរាជរដ្ឋាភិបាលកម្ពុជា ផែនការសកម្មភាពជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក២០១៤, ចំនុច បុព្វកថា

[28] ទំព័រដើមគេហទំព័រគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក, បណ្តុះបណ្តាលអំពីសុវត្ថិភាពចរាចរណ៍ ទាក់ទងនឹងស្ថានភាពទូទៅនៃគ្រោះថ្នាក់ចរាចរណ៍, អាចរកបាន http://www.nrsc.gov.kh/?page=detail&ctype=article&id=1410&lg=kh,

ចរាចរណ៍តាំងពីការពារ វិធិសាស្ត្រនៃការបើកបរ ការពន្យល់ខ្លឹមសារ ស្លាកសញ្ញាដែលងាយយល់ នឹងងាយស្រួល ព្រមទាំងសារអប់រំជាច្រើនផងដែរ។[29]

សរុបមកយើងសង្កេតឃើញថា ចរាចរណ៍ផ្លូវគោកបានកំពុងតែជាកត្តាមួយដ៏សំខាន់បំផុតក្នុងការគិតគូរពិចារណាយ៉ាងខ្ពស់ ដោយមានការចូលរួមចំណែកពីរាជរដ្ឋាភិបាល ជាពិសេសប្រជាពលរដ្ឋដែលអនុវត្តផ្ទាល់។ ប្រទេសមានច្បាប់ និងមានគោលនយោបាយច្បាស់លាស់ត្រឹមត្រូវក្នុងការគិតគូរដល់សុខទុក្ខប្រជាពលរដ្ឋ មិនត្រឹមតែប៉ុណ្ណោះព្យាយាមដោះស្រាយនូវបញ្ហាដែលមានជារៀងរាល់ថ្ងៃនៅលើដងផ្លូវជាពិសេស បញ្ហាចរាចរណ៍ផ្លូវគោក។ ទោះបីយ៉ាងណាក៏ដោយការផាកពិន័យ ការអនុវត្តច្បាប់ គ្រោះថ្នាក់ចរាចរណ៍ នៅតែមានការកើតឡើងនៅក្នុងសង្គមខ្មែរបច្ចុប្បន្ន។ បើក្រឡេកមើល ទិដ្ឋភាពច្បាប់ និងការចូលរួម ការយល់ដឹងពីប្រជាពលរដ្ឋ នៅមានដែនកំណត់នៅឡើយ។

ជាពិសេសនៅតាមខេត្ត ជនបទ ស្រុកស្រែចម្ការ ការយល់ដឹង ការផ្សព្វផ្សាយ ពីច្បាប់ចរាចរណ៍ ការអនុវត្ត គឺមិនទាន់មានប្រសិទ្ធភាពខ្ពស់គួរឲ្យកត់សម្គាល់នោះទេ។ បើក្រឡេកមើលបញ្ហា ការគ្រោះថ្នាក់ចរាចរណ៍ វិញគឺនៅតែមានការកើតឡើងជារៀងរាល់ថ្ងៃដដែល ដែលវាជាការព្រួយបារម្ភបំផុតរបស់រាជរដ្ឋាភិបាល ក៏ដូចជាប្រជាពលរដ្ឋផងដែរ។

[29] សៀវភៅ អ្វីដែលអ្នកបើកបរទោចក្រយានត្រូវយល់ដឹង, រៀបចំដោយក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្នុងឆ្នាំ ២០១៧

# ជំពូកទី២
# មូលហេតុ និងផលប៉ះពាល់នៃគ្រោះថ្នាក់ចរាចរណ៍

## ២.១ មូលហេតុនៃគ្រោះថ្នាក់ចរាចរណ៍

គ្រោះថ្នាក់ចរាចរណ៍បាននឹងកំពុងក្លាយជាបញ្ហាដ៏ធំចំពោះសុខភាពសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ តាមរបាយការណ៍ និងការស្រាវជ្រាវបានឲ្យដឹងថាមូលហេតុចម្បងដែលនាំឲ្យមានគ្រោះថ្នាក់ចរាចរណ៍ គឺបណ្តាលមកពីកត្តាយានយន្ត ព្រមទាំងកត្តាមនុស្ស កត្តាអាកាសធាតុ និង កត្តាផ្លូវ។

នៅក្នុងនេះផងដែលក៏មានទិន្នន័យជាភាគរយនៃ មូលហេតុគ្រោះថ្នាក់ចរាចរណ៍ដែលក្នុងនោះមានទិន្នន័យរួមមាន ការបើកបរហួសល្បឿនកំណត់ ៤៣%, ស្រវឹង ៩%, ប្រជែង ១១%, មិនគោរពសិទ្ធអាទិភាព ១២%, មិនប្រកាន់ស្តាំ ៩%, បត់មិនប្រយ័ត្ន ១០%, កត្តាយានយន្ត ២%, ងងុយគេង ១%, កត្តាផ្លូវ ០,៣% និងកត្តាផ្សេងៗ ២%។[30]

### ២.១.១ កត្តាមនុស្ស

រាល់សកម្មភាព មិនថាគ្រោះថ្នាក់ចរាចរណ៍ ការចូលរួមដោះស្រាយបញ្ហា និងអ្នកបង្កើតបញ្ហា គឺត្រូវបានកើតឡើងចេញពីកត្តាមនុស្ស ជាក់ស្តែងរាល់មូលហេតុនៃគ្រោះថ្នាក់ចរាចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើង ដោយសារការធ្វេសប្រហែស ការមិនយកចិត្តទុកដាក់ផ្សេងៗ និងមនុស្សនេះផងដែលក៏ជាអ្នករងនូវឥទ្ធិពលនៃផលប៉ះពាល់ផ្សេងៗពីកត្តាមនុស្ស នេះដូចគ្នា។

នៅលើសាកលលោកប្រទេសណាក៏ដោយ ទោះបីមាន ច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រល្អយ៉ាងណាក៏ដោយ បើគ្មានកត្តាចូលរួមពីប្រជាពលរដ្ឋខ្លួនទេ គឺមិនអាចដោះស្រាយបានឡើងពីបញ្ហាផ្សេងៗនៅក្នុងប្រទេសនោះ។

នៅក្នុងបរិបទសង្គមខ្មែរសព្វថ្ងៃ ជាពិសេសប្រជាពលរដ្ឋនៅតាមបណ្តាខេត្ត ស្រុកស្រែចម្ការនៅពេលដែលពួកគាត់ផ្លាស់មករស់នៅ ឬបើកបរនៅក្នុងរាជធានីក្រុង គឺសង្កេតឃើញថា ពួកគាត់មិនសូវបានយល់ដឹងពីតថភាពចរាចរណ៍នៅក្នុងទីក្រុង និងមិនសូវបានយល់ដឹងច្បាស់ពីច្បាប់ចរាចរណ៍ផ្លូវគោក ដែលជាកត្តាបង្កើតឲ្យមានបញ្ហាផ្សេងៗ នៅលើដងផ្លូវ។ លើសពីនេះទៀតសោតចំពោះមន្ត្រី រាជការមានសមត្ថកិច្ចលើចរាចរណ៍ផ្លូវគោក ក៏មានបុគ្គលមួយចំនួនក៏មិនសូវបានយល់ដឹងច្បាស់ពីច្បាប់ចរាចរណ៍របស់ខ្លួន ថែមទាំងប្រព្រឹត្តអំពើខុសច្បាប់ផ្សេងៗលើដងផ្លូវទៀតផង ដូច

[30] ទិន្នន័យគ្រោះថ្នាក់ចរាចរណ៍របស់ក្រសួងមហាផ្ទៃនៅចុងឆ្នាំ២០១៦ ពីមូលហេតុគ្រោះថ្នាក់ចរាចរណ៍

ជាការផាកពិន័យមិនត្រឹមត្រូវស្របទៅតាមច្បាប់ ការមិនគោរពច្បាប់ចរាចរណ៍ ការមិនទទួលបានការបណ្តុះបណ្តាល វិជ្ជាជីវៈត្រឹមត្រូវជាដើម។ល។

**២.១.១.១ ការបើកបរហួសល្បឿនកំណត់**

ការបើកបរហួសល្បឿនកំណត់ធ្វើឲ្យ យើងបាត់បង់ម្ចាស់កាលនៅពេលដែលមានឧបសគ្គដោយចៃដន្យ ជាពិសេសនៅត្រង់ផ្លូវខ្វែង ឬផ្លូវកោងដែលមើលមិនឃើញច្បាស់គ្រប់គ្រាន់។ ពោលគឺយើងមិនអាចម្ចាស់កាល លើយានយន្តរបស់យើងបាននៅពេលដែលមានឧបសគ្គកើតឡើងភ្លាមៗ។

__ករណីសិក្សា៖__

ដូចមានជាករណីជាក់ស្តែងអំពីគ្រោះថ្នាក់ចរាចរណ៍ថ្មីៗនេះ ដែលកើតឡើងចេញពីការបើកបរហួសល្បឿនកំណត់ ដូចមានករណី គ្រោះថ្នាក់ចរាចរណ៍មួយនៅឯ ភូមិដំរីឆ្លង ឃុំស្អាងភ្នំ ស្រុកស្អាងខេត្តកណ្តាល ដែលបណ្តាលឲ្យរបួសធ្ងន់២នាក់ មូលហេតុដោយសារជិះម៉ូតូល្បឿនលឿនគេចមិនទាន់ជ្រុលទៅបុករថយន្តច្នៃបើកច្រាស់ទិសគ្នាបណ្តាលឲ្យរបួសធ្ងន់។[31]

**២.១.១.២ ការបើកបរក្រោមឥទ្ធិពលនៃគ្រឿងស្រវឹងឬគ្រឿងញៀន**

នៅពេលអត់ងងុយខ្លាំងហេវហត់ខ្លាំង និងក្រេវក្រោធខ្លាំង។ តាមការសិក្សារបស់អ្នកវិទ្យាសាស្ត្របានឲ្យដឹងថានៅពេលស្រវឹង ងងុយគេងខ្លាំង និងខឹងក្រេវក្រោធខ្លាំង ខួរក្បាលរបស់មនុស្សមានភាពស្ពឹកស្រពន់ សម្រេចអ្វីមិនបានឆាប់រហ័ស និងមិនទាន់ពេលវេលាឡើយ។[32] ដូច្នេះនៅពេលមានឧបសគ្គកើតឡើងភ្លាមៗ នោះយើងមានការពិបាក នឹងគេចផុតពីគ្រោះថ្នាក់ដោយសារអ្នកបើកបរធ្វើការសម្រេចចិត្តយឺតយ៉ាវ រីឯសកម្មភាពធ្វើចលនាបញ្ជាយានយន្តក៏មានភាពយឺតយ៉ាវផងដែរ។ កត្តាទាំងអស់នេះដែលធ្វើឲ្យករណីជាច្រើនគឺត្រូវបានកើតឡើងក្រោមឥទ្ធិពលបែបនេះ។

នៅក្នុងការផ្សព្វផ្សាយតាមទីសាធារណៈ ក៏បានផ្តល់អត្ថន័យខ្លឹមសារ ឬក៏សារអប់រំមួយចំនួនសម្រាប់ប្រជាពលរដ្ឋ ដែលនិយាយបកស្រាយអំពីផលវិបាកនៃការបើកបរក្រោមឥទ្ធិពល គ្រឿងស្រវឹង ក្នុងនោះមានដូចជា៖

- ស្រវាំងភ្នែក ហឹងត្រចៀក និងប្រតិកម្មយឺត

[31] ដកស្រង់ពីគេហទំព័ររបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ពត័មានសណ្តាប់ធ្នាប់-ចរាចរណ៍, ជិះម៉ូតូល្បឿនលឿនគេចមិនទាន់ជ្រុលទៅបុករថយន្តច្នៃបើកច្រាស់ទិសគ្នាបណ្តាលឲ្យរបួសធ្ងន់២នាក់ (៨ ឧសភា ២០១៨, ១០៖៣១ព្រឹក) អាចរកបានhttp://cambodiapolice.com/policekh/90210

[32] ដកស្រង់ពីសៀវភៅ អ្វីដែលអ្នកបើកបរទោចក្រយានយន្តត្រូវយល់ដឹង ទំព័រទី២ សេចក្តីផ្តើម បោះពុម្ភផ្សាយឆ្នាំ២០១៧

- ការប្រុងប្រយ័ត្ន និងការវាងវៃនៃខួរក្បាលធ្លាក់ចុះ
- មិនអាចគ្រប់គ្រងយានជំនិះរបស់ខ្លួនបានពិបាកក្នុងការសម្រេចចិត្ត មិនអាចវិនិច្ឆ័យហេតុការណ៍ ឬឧបសគ្គនានាទាន់ពេលវេលា
- ជំរុញឲ្យបង្កើនល្បឿនបើកបរ មិនពាក់មួកសុវត្ថិភាព ឬខ្សែក្រវ៉ាត់សុវត្ថិភាព
- ប្រឈមនឹងការផាកពិន័យ ជាប់ពន្ធនាគារ និងការផាកពិន័យរហូតដល់ ៤ ០០០ ០០០រៀល (៤លានរៀល)[33]

### ២.១.១.៣ ការមិនគោរពសិទ្ធអាទិភាពនៅកន្លែងផ្លូវប្រសព្វ

ការមិនគោរពសិទ្ធអាទិភាពនៅកន្លែងផ្លូវប្រសព្វ ឬនៅលើផ្លូវដែលមានសិទ្ធិអាទិភាពគ្រោះថ្នាក់កើតជាញឹកញាប់ដោយអ្នកបើកបរ ដែលមកពីផ្លូវផ្សេងគ្នាមិនគោរពសិទ្ធិគ្នាទៅវិញទៅមក។ ពោលគឺអ្នកបើកបរដែលនៅលើដងផ្លូវបាត់សិទ្ធិមិនបានឈប់ទុកឲ្យអ្នកបើកបរនៅលើ ផ្លូវមានសិទ្ធិទៅមុន។

### ២.១.១.៤ ការជែងដោយខ្វះការប្រុងប្រយ័ត្ន

គ្រោះថ្នាក់តែងកើតជារឿយៗហើយធ្ងន់ធ្ងរព្រោះតែការបើកបរជែងគ្នា ដោយគ្មានការប្រុងប្រយ័ត្ន ជាពិសេសក្នុងពេលដែលស្ថានភាពមិនសមស្របអាចធ្វើការជែងបាន។ មុននឹងសម្រេចចិត្តជែងអ្នកបើកបរគ្រប់រូបត្រូវតែប្រាកដក្នុងចិត្តថា ការជែងរបស់ខ្លួននឹងមិននាំឲ្យមានការរំខានឬគ្រោះថ្នាក់ដល់ខ្លួននិងអ្នកដទៃឡើយ។

### ២.១.១.៥ ការមិនគោរពភ្លើងសញ្ញាចរាចរណ៍

ការគោរពស្លាកសញ្ញាចរាចរណ៍មានសារៈសំខាន់ណាស់ ដូចជាភ្លើងសញ្ញាចរាចរណ៍ ឬផ្លាកសញ្ញាចរាចរណ៍ ឬផ្លាកសញ្ញាហាមឃាត់ ឬស្លាកសញ្ញាបញ្ជារជាដើម។បើយើងមិនគោរពវានោះទេយើងនឹងប្រឈមនឹងគ្រោះថ្នាក់ និងប្រឈមនឹងការផាកពិន័យផងដែរ។

### ២.១.១.៦ ការបត់ឆ្វេង បត់ស្តាំ ឬត្រឡប់ក្រោយដោយគ្មានការប្រុងប្រយ័ត្ន

អ្នកបើកបរខ្លះ ពេលនឹកឃើញចង់បត់ស្តាំ ឬបត់ឆ្វេង ឬបត់ត្រឡប់ក្រោយ ក៏ចាប់បត់ភ្លាមដោយគ្មានផ្តល់សញ្ញាឲ្យអ្នកបើកបរនៅក្រោយ ឬអ្នកនៅចំហៀងបានដឹងឡើយ។ការធ្វេសប្រហែសនេះហើយដែលតែងតែគ្រោះថ្នាក់ជារឿយៗ ដែលឃើញជាញឹកញាប់ ជាពិសេសនៅទីក្រុង។

[33] ដកស្រង់ចេញពីខ្លឹមសារខិតប័ណ្ណរបស់ផ្សព្វផ្សាយ ចំនុចការពារជីវិតអ្នកកុំបើកបរក្រោមឥទ្ធិពលគ្រឿងស្រវឹង

### ២.១.១.៧ ការបើកបរពេលខ្ទុយគេងឬមានជំងឺ

មនុស្សគ្រប់រូបតែងតែមានជំងឺទៅតាមប្រភេទផ្សេងៗគ្នា ដែលអាការៈទាំងអស់នេះ តែងតែធ្វើទុក្ខ ដោយមិនមានការដឹងទុកជាមុន ជាពិសេសអ្នកជំងឺរាំរ៉ៃត្រូវមានការប្រុងប្រយ័ត្នខ្ពស់ចំពោះសុខភាពខ្លួន។

នៅពេលបើកបរដែលអ្នកបើកបរតែងតែប្រើប្រាស់ថ្នាំដូចជាៈ

អ្នកបើកបរដែលបានប្រើថ្នាំ ដូចជា ថ្នាំរំងាប់អារម្មណ៍,ថ្នាំបំបាត់ការឈឺចាប់,ថ្នាំរំងាប់ផ្លូវចិត្ត,ថ្នាំសម្រាប់អ្នកលើសឈាម។ វាមានផលប៉ះពាល់នៃការប្រើប្រាស់ដូចជា ភាពរហ័សរហួន, ការផ្តោតអារម្មណ៍, រយៈពេលប្រតិកម្ម។

អ្នកបើកបរដែលប្រើប្រាស់ថ្នាំ ក្អក ថ្នាំផ្តាសសាយ ថ្នាំគ្រុនផ្តាសសាយ ថ្នាំក្អួតចង្អោរ មានផលប៉ះពាល់នៃការប្រើប្រាស់ថ្នាំដូចជា ងងុយគេង, ភាពមិនប្រុងស្មារតី ឬធ្វេសប្រហែស។

អ្នកបើកបរដែលប្រើប្រាស់គ្រឿងញៀន គឺមានផលប៉ះពាល់នៃការប្រើប្រាស់ថ្នាំដូចជាៈ សញ្ញាវិបល្លាស, ការដឹកដោយប្រហូកប្រហូច, មិនអាចម្ចាស់ការ ឬទប់អារម្មណ៍បាន, ខ្វះការវិនិច្ឆ័យត្រឹមត្រូវ។

អ្នកបើកបរដែលអស់កម្លាំងកាលណាអ្នកបើកបរធ្វើការច្រើន ឬធ្វើការលើសម៉ោង ឬក៏គិតច្រើនអាចបណ្តាលឲ្យអ្នកបើកបរអស់កម្លាំង។

នៅពេលអ្នកបើកបរអស់កម្លាំង នាំឲ្យមានផលប៉ះពាល់ដល់អ្នកបើកបរដូចជាៈ កាត់បន្ថយសមត្ថភាពក្នុងការមើល (មើលមិនច្បាស់), រយៈពេលប្រតិកម្មយឺត (ប្រហែល ២វិនាទី),អាចបើកបរភ្លឹកម្តងៗ ឬរលីវម្តងៗ។ ផលប៉ះពាល់ទាំង៣ ខាងលើនេះអាចបណ្តាលឲ្យអ្នកបើកបរប្រឈមនឹងគ្រោះថ្នាក់ចរាចរណ៍។[34]

### ២.១.២ ការប្រើប្រាស់យានជំនិះខុសស្តង់ដារបច្ចេកទេស

យានយន្តក៏ជាកត្តាមួយនាំឲ្យមានគ្រោះថ្នាក់ដែរ ដូចជាពេលកំពុងបើកបរហ្វ្រាំងមិនស៊ីបែកកង់ជាដើម។ ចំណុចសុវត្ថិភាពយានយន្តមានបួនសំខាន់ៗគឺៈ ហ្វ្រាំង ចង្កូត កង់ និងភ្លើងបំភ្លឺ។ ដូច្នេះត្រូវថែទាំចំណុចទាំងបួននេះឲ្យបានដំណើរការល្អជាប្រចាំ។ មិនត្រឹមតែប៉ុណ្ណោះទៀតសោតការកែច្នៃ ខុសពីស្តង់ដារបច្ចេកទេស ដូចជាផ្លាស់សំបកកង់ បំពង់ស៊ីម៉ាំង ស៊ីឡាំងម៉ាស៊ីន និងផ្សេងៗទៀតដែលខុសបច្ចេកទេសដែលបង្កឲ្យមានភាពរអករអួល ក្នុងពេលធ្វើដំណើរ និងងាយស្រួលនឹងជួបស្ថានភាពគ្រោះថ្នាក់។

[34] ដកស្រង់ចេញពីអត្ថបទរបស់ លោក ព្រាប ច័ន្ទវិបុល ក្នុងកិច្ចពិភាក្សាតុមូលនៃទូរទស្សន៍ជាតិ ស្តីពីការបើកបរយានយន្តនៅពេលអស់កំលាំង និងងងុយគេង

ការកែច្នៃទ្រុងឲ្យធំ និងការបន្ថែមភ្លៅដើម្បីផ្ទុកទំនិញឲ្យបានច្រើនលើសទម្ងន់ កំណត់បណ្ដាលឲ្យមានផលប៉ះពាល់ដូចការដឹកជញ្ជូនលើសទម្ងន់កំណត់ដែរធ្វើឲ្យប៉ះពាល់ដូចជាៈ

- បណ្ដាលឲ្យសឹក ឬខូចផ្លូវថ្នល់ និងស្ពាន
- ធ្វើឲ្យរថយន្តពិបាកក្នុងការកាច់ចង្កូត (ដោយទម្ងន់សង្កត់លើមុខកើនឡើង)
- ធ្វើឲ្យរថយន្តមិនមានលំនឹង ជាពិសេសនៅលើផ្លូវបត់
- ពិបាកឡើងទួល (រថយន្តអាចរមាលថយក្រោយ ដោយម៉ាស៊ីនពុំមានកម្លាំងគ្រប់គ្រាន់ ដូចមុនពេលមិនទាន់កែច្នៃឡើយ ហើយរថយន្តខ្លះប្រឹងឡើងញ័រក្បាល)។

បន្ថែមពីលើផលប៉ះពាល់ ដូចការដឹកជញ្ជូនលើសទម្ងន់កំណត់ ការកែច្នៃទ្រុងឲ្យធំ និងបន្ថែមភ្លៅមានផលប៉ះពាល់ដូចខាងក្រោមៈ

- ធ្វើឲ្យរំខាន និងស្ទះចរាចរណ៍នៅពេលបត់ម្ដងៗ ជាពិសេសនៅពេលបត់ចេញ ឬចូលឃ្លាំងជាប់នឹងផ្លូវថ្នល់។
- ការបន្ថែមភ្លៅធ្វើឲ្យការជាន់ហ្វ្រាំងមិនសូវមានប្រសិទ្ធភាព។[35]

## ២.១.៣ ការដឹកទំនិញលើសចំនួនកំណត់ និងស្ថានភាពផ្លូវ

នៅបណ្ដោយផ្លូវជាតិក្នុងព្រះរាជាណាចក្រកម្ពុជា យើងសង្កេតឃើញថាមានរថយន្តជាច្រើនដែលកំពុងធ្វើដំណើរដែលប្រកបមុខរបរ រកស៊ីដឹកជញ្ជូនពីខេត្តមួយទៅខេត្តមួយដែល ជាពិសេសរថយន្តមួយចំនួនតូច រថយន្តប្រភេទ ១តោនកន្លះ ៣តោន ឬក៏រថយន្តដែលធុនធំ ដែលពួកគាត់ព្យាយាមផ្ទុកទំនិញដែលលើសទង្ងន់ និងកែច្នៃ ដែលធ្វើឲ្យម៉ាស៊ីនរថយន្ត និងល្បឿនដែលពិបាកនឹងទ្រទ្រង់នូវបរិមាណនៃបន្ទុកដែលជាហេតុធ្វើឲ្យមានគ្រោះថ្នាក់ និងខូចខាតផ្លូវជាច្រើនកន្លែងផងដែរ ។

បើក្រឡេកមើលស្ថានភាពផ្លូវវិញក៏ជាកត្តានាំឲ្យមានគ្រោះថ្នាក់ផងដែល ដូចជាផ្លូវកោងខ្លាំង ផ្លូវធំរួមតូច ផ្លូវសំបុកមាន់ ផ្លូវដែលគ្មានបរិក្ខារសុវត្ថិភាពគ្រប់គ្រាន់ ដូចជាស្លាកសញ្ញា គំនូសសញ្ញា រនាំងសុវត្ថិភាព ឬរនាំងចែកទ្រូវផ្លូវ។ ដូច្នេះអ្នកបើកបរត្រូវប្រុងប្រយ័ត្ននៅចំណុចទាំងនោះ។ ផលប៉ះពាល់នៃ ការផ្ទុកទម្ងន់លើសកំណត់ៈ

- បណ្ដាលឲ្យសឹកឬខូចផ្លូវថ្នល់ និងស្ពាន
- ផ្លូវថ្នល់ខូចដោយសារការដឹកជញ្ជូនលើសទម្ងន់កំណត់
- ធ្វើឲ្យរថយន្តពិបាកក្នុងការកាច់ចង្កូត

[35] ដកស្រង់ចេញពី បទបង្ហាញពីស្តីពីការកែច្នៃរថយន្តខុសបច្ចេកទេស របស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក

- ធ្វើឲ្យរថយន្តមិនមានលំនឹង ជាពិសេសនៅលើផ្លូវបត់ ឬផ្លូវវង្វង់មូល
- ធ្វើឲ្យពិបាកក្នុងការបង្កើនល្បឿននៅពេលជែង
- ធ្វើឲ្យពិបាកក្នុងការបើកបរឡើងទួលខ្ពស់
- ធ្វើឲ្យហ្វ្រាំងកើនកំដៅនាំឲ្យការជាន់ហ្វ្រាំងមិនមានប្រសិទ្ធភាព
- អាចបណ្តាលឲ្យសំបកកៅស៊ូកង់កើនកំដៅ និងឆាប់សឹក (ដោយទម្ងន់ប្រមូលផ្តុំសង្កត់ទៅលើកង់ ) ហើយសំបកកៅស៊ូកង់ឆាប់ខូចមុនអាយុកាលអាចផ្ទុះ ឬបង្កឲ្យមានគ្រោះថ្នាក់។
- នាំឲ្យមានការប្រកួតប្រជែងក្នុងការដឹកជញ្ជូន រវាងក្រុមហ៊ុននីមួយៗមិនស្មើភាព
- នាំឲ្យមានការប្រឈមនឹងពិន័យអន្តរការណ៍។[36]

## ២.១.៤ ការបើកបរក្រោមអាកាសធាតុភ្លៀងធ្លាក់

នៅគ្រប់ស្ថានភាពដែលមានភ្លៀងធ្លាក់ គួបផ្សំជាមួយកម្លាំងខ្យល់ និងដំណក់ទឹកភ្លៀង ជាមូលហេតុធ្វើឲ្យអាកាសធាតុចុះអាប់ដោយសារគ្រាប់ភ្លៀង បានធ្វើឲ្យអ្នកបើកបរតាមដងផ្លូវមានភាពពិបាកក្នុងការបើកបរ ដែលត្រូវប្រឈមមុខនឹងការរអិល ពិបាកមើលបរិវេណជុំវិញផ្លូវជាពិសេសប្រឈមបញ្ហាគ្រោះថ្នាក់ខ្ពស់ ជាមួយនឹងទោចក្រយានយន្ត។ មិនត្រឹមតែប៉ុណ្ណោះក៏គួបផ្សំផងដែលនូវគុណភាពស្តង់ដា នៃគ្រឿងឧបករណ៍ដូចជាសំបកកង់ ហ្វ្រាំង ដូចដែលបានលើកឡើងខាងលើ គឺអ្នកបើកបរត្រូវពិនិត្យធ្វើការជួសជុលផ្លាស់ប្តូរ និងប្រុងប្រយ័ត្នខ្ពស់នៅពេលមាន ភ្លៀងធ្លាក់។

បញ្ហាទាំងនេះតែងតែឃើញកើតឡើងមួយចំនួនជាពិសេសនៅតាមបណ្តោយផ្លូវជាតិ ដោយអ្នកបើកបរ ទូទៅប្រើប្រាស់ល្បឿនលឿន។ នៅពេលមានភ្លៀងធ្លាក់ខ្លាំងម្តងៗ យើងក្រឡេកមើលឃើញមានការលិចទឹកនៅតាមដងផ្លូវ និងកក់ស្ទះខ្លាំង ស្របពេលដែលអ្នកធ្វើដំណើរមិនថា រថយន្ត ទោចក្រយានយន្ត ត្រូវបានខូចខាតដោយសារទឹកលិចនៅលើដងផ្លូវ។

## ២.១.៥ ការគ្មានការប្រុងប្រយ័ត្ន និងការពារ

ជាទូទៅគ្រោះថ្នាក់ជាច្រើនត្រូវបានកើតឡើងពីការធ្វេសប្រហែសមិនប្រុងប្រយ័ត្ន និងការពារបានត្រឹមត្រូវ ក្នុងន័យនេះគឺមានន័យថា ការបើកបរនៅលើដងផ្លូវសព្វថ្ងៃក្នុងប្រទេសកម្ពុជា ឃើញមានគ្រោះថ្នាក់ចរាចរណ៍ភាគច្រើនកើតឡើងចេញពី ការធ្វេសប្រហែស ដូចជា ការបើកបរដោយមិនបានពាក់ខ្សែក្រវ៉ាត់ ប្រើប្រាស់ទូរស័ព្ទពេលកំពុងបើកបរ ការមិនពាក់មួកសុវត្ថិភាព និង ការធ្វេសប្រហែស ផ្សេងៗទៀត។

[36] ដកស្រង់ចេញពីអត្ថបទ បទបង្ហាញស្តីពីផលប៉ះពាល់នៃការផ្ទុកទម្ងន់កំណត់ នៃគេហទំព័រគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក

### ២.១.៥.១ មួកសុវត្ថិភាព

យើងដឹកហើយថាមួកសុវត្ថិភាព ត្រូវបានប្រើប្រាស់នៅពេលធ្វើដំណើរដូចជា ទោចក្រយានយន្ត កង់ជាដើម។ មួកសុវត្ថិភាព មានច្រើនប្រភេទដែលកំពុងចរាចរណ៍លើទីផ្សា មិនត្រឹមតែប៉ុណ្ណោះក៏មានមួកដែលខុសស្តង់ដារធ្វើឲ្យគ្រោះថ្នាក់ផងដែរ។ គ្រោះថ្នាក់ចរាចរណ៍ជាច្រើនត្រូវបានកើតឡើងដោយ ជនរងគ្រោះមិនបានពាក់មួកសុវត្ថិភាពបានត្រឹមត្រូវ នឹងមិនពាក់មួកសុវត្ថិភាព។ របួសនៃគ្រោះថ្នាក់ដែលមិនបានពាក់មួកសុវត្ថិភាពគឺមានលក្ខណៈធន់ធ្ងរ និងអាចឈានទៅដល់ការស្លាប់។ ការផលិតមួកខុសស្តង់ដារបច្ចេកទេស បានធ្វើឲ្យអ្នកប្រើប្រាស់មានហានិភ័យនៅពេលជួបគ្រោះថ្នាក់ ដែលប្រើប្រាស់ផលិតផលមិនបានត្រឹមត្រូវ ខុសស្តង់ដារ គ្មានការកាពារគ្រប់ជ្រុងជ្រោយ។ នៅពេលរសៀល ការបើកបរបានជួបឧបសគ្គមួយចំនួននៅពេលអ្នកបើកបរមិនពាក់មួកសុវត្ថិភាព ធ្វើឲ្យអ្នកបើកបរមានពិបាកសំលឹង មើលទៅមុខ នឹងចំហៀងដោយមូលហេតុសត្វល្អិតចូលភ្នែក ដីធូលី កម្លាំងខ្យល់ ដែលធ្វើឲ្យអ្នកបើកបរពិបាកមើលផ្លូវ។

នៅក្នុងខ្លឹមសារខិតប័ណ្ណផ្សព្វផ្សាយបានឲ្យពន្យល់ពីផលវិបាកនៃការមិនពាក់ មួកសុវត្ថិភាព ដែលក្នុងនោះមានៈ

- នៅពេលមានគ្រោះថ្នាក់ចរាចរណ៍កើតឡើងអាចបណ្តាលឲ្យ ប៉ះពាល់ធ្ងន់ធ្ងរដល់ លលាដ៍ក្បាល និងខួរក្បាលពីការបោក ឬប៉ះទង្គិចដែលអាចឈានដល់ពិការ ឬស្លាប់
- ជាមូលហេតុចម្បងនៃអ្នកជិះម៉ូតូ ស្លាប់បណ្តាលមកពីការប៉ះទង្គិចក្បាល
- បណ្តាលឲ្យរលាកដល់កែវភ្នែក និងស្បែកមុខ។[37]

លើសពីនេះទៀតសោតទាក់ទង និងមួកសុវត្ថិភាពនេះផងដែរ គឺនៅក្នុងប្រទេសកម្ពុជាមានកត្តាប៉ះពាល់ នៃលំហូរនៃការនាំចូលនូវមួកសុវត្ថិភាពដែលខុសស្តង់ដារបច្ចេកទេស ដែលមានតម្លៃប្រហាក់ប្រហែលទៅនឹងតម្លៃទីផ្សារមួកសុវត្ថិភាពត្រឹមត្រូវតាមបច្ចេកទេស។ ជាពិសេសមួកសុវត្ថិភាពខុសស្តង់ដាបច្ចេកទេសនេះហើយបានផលប៉ះពាល់ជាច្រើន និងមិនបានកាពារអាយុជីវិតអ្នកបាន ត្រឹមត្រូវ ពេលមានគ្រោះថ្នាក់ តែវាអាចធ្វើឲ្យ អ្នកប្រើប្រាស់អាចគ្រោះថ្នាក់ ធ្ងន់ធ្ងរថែមទៀតផង។

**<u>ករណីសិក្សា</u>**

យោងទៅតាមសិក្សាស្រាវជ្រាវស្តង់មតិយោបល់ ទៅលើការសាកសួរ ប្រជាពលរដ្ឋដែលរស់នៅជនបទ និងប្រជាពលរដ្ឋដែលមានចំនូវតិចតួច ដែលប្រើប្រាស់ទោចក្រយានយន្ត ក្នុងការធ្វើ

[37] ដកស្រង់ពី ខិតប័ណ្ណមានចំណងជើង គោរពច្បាប់ចរាចរណ៍គឺដើម្បីការពារជីវិតអ្នកគ្រួសារអ្នក និងអ្នកដទៃ, ការពារជីវិតអ្នកពាក់មួកសុវត្ថិភាពឲ្យបានត្រឹមត្រូវ

ដំណើរ ទាក់ទង និងការទិញ និងការប្រើប្រាស់មួកសុវត្ថិភាព បានសង្កេតឃើញថាការប្រើប្រាស់មួកសុវត្ថិភាពនៅពេលបើកបររបស់ពួកគាត់គឺមិនត្រឹមត្រូវទៅតាមស្តង់ដា។ ប្រជាពលរដ្ឋមួយចំនួនបានប្រាប់ពីមូលហេតុដែលបង្កើតឲ្យមានការសម្រេចចិត្តឲ្យពួកគាត់ប្រើប្រាស់មួកសុវត្ថិភាព ដែលមិនត្រូវតាម ស្តង់ដារ

១- មួកទាំងនោះមានតម្លៃទាប

២- ពេលពាក់ទៅមិនហាប់ខ្យល់

៣- ពេលពាក់ទៅមិនធ្ងន់ក្បាល

៤- ងាយស្រួលក្នុងការទុកដាក់ ព្រោះវាមានទំហំតូច និងមិនភ័យខ្លាចក្នុងការលួច ឬបាត់

៥- ពាក់មួកសុវត្ថិភាពឲ្យតែបាន កុំឲ្យតែប៉ូលីសផាកពិន័យ ទៅជាការស្រេច។

ជាការពិតណាស់នៅក្នុងទិន្នភាពជាក់ស្តែងលើចរាចរណ៍ផ្លូវគោក គឺសង្កេតឃើញថាប្រជាពលរដ្ឋមួយចំនួនតូច ជាពិសេសប្រជាពលរដ្ឋដែលមានចំនូរតិច គឺពួកគាត់មិនសូវបានយល់ដឹងច្បាស់ពីអត្ថប្រយោជន៍ និងពិធីសាស្ត្រក្នុងការប្រើប្រាស់ មួកសុវត្ថិភាព ថែមទាំងមិនសូវបានយល់ដឹងពីច្បាប់ចរាចរណ៍ផ្លូវគោក និងសេចក្តីណែនាំពីរាជរដ្ឋាភិបាលអំពីមួកសុវត្ថិភាព។ នៅពេលដែល អ្នកបើកបរទោចក្រយានយន្តមិនបានពាក់មួកសុវត្ថិភាពត្រឹមត្រូវគឺពិតជាគ្រោះថ្នាក់ខ្លាំងណាស់ដល់អាយុជីវិត ជាពិសេសត្រង់ក្បាល និងប្រឈមនិងការផាកពិន័យពីមន្ត្រីមានសមត្ថកិច្ច ។

**២.១.៥.២ កញ្ចក់សងខាង**

គ្រប់យានយន្តគឺត្រូវបានបំពាក់ដោយកញ្ចក់ សងខាងនៃយានយន្ត ក្នុងគោលបំណងមួយដែលអាចឲ្យអ្នកបើកបរអាចមើល និងដឹងពីស្ថានភាពជុំវិញ។ គ្រោះថ្នាក់តែងតែកើតឡើង នៅពេលដែលអ្នកបើកបរមិនបានដឹងពីស្ថានភាពជុំវិញ ជាពិសេសនៅពេល កាច់បត់។ យើងដឹងហើយថានៅលើដងផ្លូវគឺមានអ្នកបើកបរជាច្រើន ដែលនៅជុំវិញ នៅពេលអ្នកមិនបានប្រើប្រាស់ កញ្ចក់សងខាងទេ គឺអ្នកបើកបរគឺមានភាពមិនច្បាស់លាស់ ដែលអាចគ្រប់គ្រងពីស្ថានភាពខ្លួនឯង ថាខ្លួនអាច កាច់បត់ ឬទៅមុខ ថយក្រោយបានដោយសុវត្ថិភាព។ បច្ចុប្បន្នគ្រោះថ្នាក់ជាច្រើនគេសង្កេតឃើញ កើតឡើងទៅលើទោចក្រយានយន្ត ដែលពួកគាត់មានការធ្វេសប្រហែស ទៅលើស្ថានភាពជុំវិញ ដែលជាមូលហេតុនាំឲ្យមានគ្រោះថ្នាក់ដល់អ្នកដទៃ និងខ្លួនឯង។

**២.១.៥.៣ ខ្សែក្រវ៉ាត់សុវត្ថិភាព**

ខ្សែក្រវ៉ាត់សុវត្ថិភាព គឺជាឧបករណ៍ដែលសម្រាប់កាពារ នឹងជួយទប់លំនឹងដល់អ្នកបើកបរ អ្នកធ្វើដំណើរ ពេលមានឧបសគ្គ។ គ្រោះថ្នាក់ចរាចរណ៍នៅប្រទេសកម្ពុជាបច្ចុប្បន្នដែលធ្វើឲ្យមានអ្នកស្លាប់ច្រើនគឺកើតឡើងចេញពីការធ្វេសប្រហែសរបស់ពួកគាត់ ដូចជាការមិនដាក់ខ្សែក្រវ៉ាត់ នៅ

ពេលអ្នកជួបឧបសគ្គ ឬស្ថានភាពចាប់ហ្វាំង ដែលអ្នកពិបាក នឹងទប់ចំហរ គឺពួកគេត្រូវបានបោក ឬប៉ះទង្គិច នឹងក្បាល ដែលជាហេតុធ្វើឲ្យជនរងគ្រោះ មានស្ថានភាពធ្ងន់ធ្ងរ។

### ២.១.៥.៤ ប្រើប្រាស់ទូរស័ព្ទ ពេលកំពុងបើកបរ

បច្ចេកវិទ្យាកាន់តែទំនើប បានធ្វើឲ្យប្រជាពលរដ្ឋជាច្រើនបានប្រើប្រាស់ទូរស័ព្ទខុសស្ថានភាពដែលខ្លួនកំពុងធ្វើ។ ជាក់ស្តែងតាមការអង្កេតមើលរបស់ខ្ញុំផ្ទាល់ នៅពេលខ្ញុំកំពុងធ្វើដំណើរផ្លូវ ក្នុងរាជធានីភ្នំពេញ គឺខ្ញុំតែងតែឃើញ អ្នកបើកបរប្រើប្រាស់ទូរស័ព្ទពេលកំពុងបើកបរ និងពេលឈប់ភ្លើងស្តុប។ នៅពេលដែលពួកគាត់ប្រើប្រាស់ទូរស័ព្ទពេលកំពុងបើកបរ ជាហេតុធ្វើឲ្យពួកគាត់បាត់បង់ការផ្តោតស្មារតីទៅលើការបើកបររបស់ខ្លួន លើសពីនេះទៅទៀត វាមានបញ្ហាជាច្រើនដែលកើតឡើងនៅពេលអ្នកបើកបរ ព្យាយាមប្រើប្រាស់ទូរស័ព្ទ និងបើកបរស្របគ្នានៅពេលតែមួយ។

### ២.១.៦ សុជីវធម៌ និងអធ្យាស្រ័យក្នុងពេលបើកបរ

អ្នកបើកបរម៉ូតូ ត្រូវមានមនសិការខ្ពស់ក្នុងការគោរពច្បាប់ចរាចរណ៍ផ្លូវគោក រក្សាសេចក្តីថ្លៃថ្នូរ ដឹងទុក្ខធុរៈ ដល់អ្នកបើកបរដូចគ្នា និងត្រូវអនុវត្តដូចខាងក្រោម៖

- ត្រូវបន្ថយល្បឿននៅពេលមានម៉ូតូ ឬយានផ្សេងទៀតធ្វើសញ្ញាសុំជែងត្រូវអែបស្តាំទុកលទ្ធភាពឲ្យយានដែលនៅក្រោយមានធុរៈប្រញាប់ទៅមុន
- នៅកន្លែងមានទឹកដក់ ឬភក់ជ្រាំ នៅកន្លែងដែលមានដីហុយ ឬជិតដល់ទីប្រជុំជនត្រូវបន្ថយល្បឿនដើម្បីកុំឲ្យភក់ជ្រាំ ខ្ទាយប្រឡាក់អ្នកដំណើរផ្សេងៗដែលនៅជិតនោះ
- មិនត្រូវខាកស្តោះ ឬបោះសម្ភារផ្សេងៗចេញពីយានយន្ត ជាហេតុនាំឲ្យរំខាន និងប៉ះពាល់ដល់អ្នកដំណើរពីក្រោយយើង។
- អ្នកបើកបរត្រូវចេះអាធ្យាស្រ័យ ចេះអត់ឱន ឬអនុគ្រោះចំពោះការខុសឆ្គងបន្តិចបន្តួចរបស់អ្នកបើកបរដូចគ្នា។ ទោះបីជាការបើកបរស្ថិតក្នុងសភាពត្រូវច្បាប់ក៏ដោយ ក៏យើងត្រូវមានការយោគយល់ ឬអាធ្យាស្រ័យចំពោះអ្នកបើកបរដែលបំពានច្បាប់។

### ២.១.៧ សណ្តាប់ធ្នាប់សាធារណៈ

សណ្តាប់ធ្នាប់សាធារណៈពិតជាសំខាន់ខ្លាំងណាស់ចំពោះ សោភ័ណភាពខេត្តក្រុង បង្ហាញពីហេដ្ឋារចនាសម្ពន្ធ ពីការអភិវឌ្ឍន៍ទៅតាមតម្រូវការដល់ប្រជាពលរដ្ឋដែលរស់នៅក្បែរ នឹងជាពិសេសផ្តល់អត្ថប្រយោជន៍ជូនពួកគាត់។ ក៏ប៉ុន្តែ សណ្តាប់ធ្នាប់សាធារណៈនៅកន្លែងមួយចំនួនកំពុងជួបបញ្ហាទៅលើការរៀបចំ ជាពិសេសទាក់ទង នឹងបញ្ហាគ្រោះថ្នាក់ចរាចរណ៍ និង

សណ្តាប់ធ្នាប់ចរាចរណ៍ សាធារណៈ។ ជាក់ស្តែងក្នុងរាជធានីភ្នំពេញ កត្តាកំណើនប្រជាជនមករស់នៅក្នុងមានកំណើនច្រើនពីមួយឆ្នាំទៅមួយឆ្នាំ ធ្វើឲ្យមានភាពមមារញឹក នឹងពិបាករកកន្លែងសម្រាប់បំពេញតម្រូវការជូនពួកគាត់។ បញ្ហាទាំងអស់នោះបានកើតឡើងដូចជា ការចតរថយន្តគ្មានសណ្តាប់ធ្នាប់ ការរំលោភដីចំណីផ្លូវ សាធារណៈ ការមិនចូលរួមថែរក្សាសម្អាតផ្លូវសាធារណៈ និងមានជាច្រើនទៀត។

**២.១.៧.១ ចំណត់រថយន្ត**

ការកើនឡើងនៃយានយន្តក្នុងប្រទេសកម្ពុជា អាចនិយាយបានក្នុងក្រុមគ្រួសារនីមួយៗនៅក្នុង ទីក្រុងតែសុទ្ធមានឡានក្នុងមួយគ្រួសារមួយ ដែលចោទជាបញ្ហាមួយចំនួនសម្រាប់ទុកដាក់ និងការចតរថយន្ត។ ការចតរថយន្តនៅទីសាធារណៈ បានបង្កឲ្យមានភាពគ្មានសណ្តាប់ធ្នាប់ សាធារណៈ និងមានការចតបញ្ច្រាស់ ដែលជាហេតុធ្វើឲ្យផ្លូវមានទំហំរួមតូចក្នុងការធ្វើដំណើរ មិនត្រឹមតែប៉ុណ្ណោះការខ្វះកន្លែងសម្រាប់ចតរថយន្តក៏ជាកត្តាសំខាន់សម្រាប់អ្នកប្រើប្រាស់យានយន្តផងដែរ។ បកមកវិញ គ្រោះថ្នាក់នៃការចតរថយន្តនៅតាមដងផ្លូវ បានចោទជាបញ្ហាមួយដ៏សំខាន់ ក្នុងការកក់ស្ទះ ពិបាកក្នុងការបំលាស់ទី មិនត្រឹមតែប៉ុណ្ណោះ នៅពេលយប់ គឺសង្កេតឃើញថាមានអ្នករបួសនឹងស្លាប់ដោយសារ ការបើកបរ បុកយានយន្តដែលចតនៅមុខផ្ទះ ឬតាមផ្លូវសាធារណៈ ដែលខុសច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកដែលហាមឃាត់មិនឲ្យមានចំណតនៅលើដីចំណីផ្លូវ។

**២.១.៧.២ ទួលកាត់ទទឹងផ្លូវ**

នៅក្នុងស្ថានភាពផ្លូវបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា គឺមានជាច្រើននូវ ទួលកាត់ទទឹងផ្លូវ មិនថានៅលើផ្លូវជាតិ ផ្លូវលំ ឬក្នុងទីកន្លែងសាធារណៈ ក្នុងគោលបំណង ឲ្យអ្នកបើកបរនៅលើដងផ្លូវមានការប្រុងប្រយ័ត្ន និងឲ្យមានការបន្ថយល្បឿននៃការបើកបរ។ ចំពោះទួលកាត់ទទឹងនេះផងដែលត្រូវបានប្រជាពលរដ្ឋមួយចំនួនតូចយល់ច្រលំ និងបានព្យាយាមសាងសង់នៅតាមទីកន្លែងសាធារណៈ ដែលខុសស្តង់ដាបច្ចេកទេសរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ ក្នុងគោលបំណងឲ្យអ្នកបើកបរឆ្លងកាត់ទីតាំងនោះឲ្យមានការបន្ថយល្បឿន និងប្រុងប្រយ័ត្ន តែគោលបំណងទាំងនោះបានផ្ទុយទៅវិញដោយសារការសាងសង់ខុសស្តង់ដាបែរជា បង្កឲ្យអ្នកឆ្លងកាត់ទីនោះមានគ្រោះថ្នាក់ជាច្រើនទៅវិញ។

**<u>ករណីសិក្សា</u>**

នៅក្នុងរាជធានីភ្នំពេញ អាជ្ញាធរខណ្ឌឫស្សីកែវ ចុះវាយកម្ទេចទួលកាត់ទទឹងផ្លូវ ដែលតែងតែបង្កឲ្យមានគ្រោះថ្នាក់ចរាចរណ៍នៅខាងជើងបុរីកាំកូស៊ីតធី ខណៈមានការរាំងពីថៅកែជាជនជាតិ

កូរ៉េ[38] ជាក់ស្តែងលោក អភិបាលរងខណ្ឌឬស្សីកែវបានដឹកនាំចម្រុះមានទាំងនគរបាលអាវុធហត្ថ និងកម្លាំងប្រជាការពារ ចុះវាយកម្ទេចទូលដែលតែងតែបង្កគ្រោះថ្នាក់នេះតែម្តង ប៉ុន្តែការវាយកម្ទេចទូលកាត់ ទទឹងផ្លូវមិនទទួលបានជោគជ័យនោះទេ ដោយជនជាតិកូរ៉េនោះបានអង្គុយកណ្តាលផ្លូវ នៅកណ្តាលផ្លូវលើទូលនោះ និងអង្គុយលើគ្រឿងចក្ររបស់អាជ្ញាធរដែលយកមកកម្ទេច។ លោកអភិបាលរងខណ្ឌឬស្សីកែវបានពន្យល់ថា ទោះបីផ្លូវនេះខាងបុរីជាអ្នកធ្វើក៏ដោយ ក៏មិនអាចធ្វើទូលបានតាមចិត្តនោះទេព្រោះវាបង្កគ្រោះថ្នាក់ ដល់ពលរដ្ឋដែលធ្វើដំណើរ ហើយប្រសិនបើចង់ធ្វើត្រូវមានការអនុញ្ញាតពីអាជ្ញាធរ មិនមែនធ្វើតាមចិត្តបែបនេះទេ។ នៅប្រមាណ ៥៖២០នាទីល្ងាចថ្ងៃដដែល អាជ្ញាធរនៅតែបន្តប្រតិបត្តិការវាយកម្ទេចនេះបានសម្រេចដោយជោគជ័យ ព្រោះក្រុមម្ចាស់បុរីមិនហ៊ានរារាំងបន្តទៀត ដោយសារខ្លាចត្រូវអេស្កាវ៉ាទ័រ។

នៅត្រង់ករណីនេះដែលគឺអ្នកដែលសាងសង់ទូលកាត់ទទឹងផ្លូវនោះគឺមិនត្រូវតាមស្តង់ដា និងមិនបានសុំការអនុញ្ញាតពីអាជ្ញាធរនៅទីនោះព្រមទាំងបង្កឲ្យមាន គ្រោះថ្នាក់ដល់ប្រជាពលរដ្ឋ ជារឿយៗ។ មួយវិញទៀតសោត បើយោងតាមប្រសាសន៍របស់ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញថា បញ្ហាបើនៅលើផ្លូវសាធារណៈវាជាភារកិច្ចរបស់សាធារណការ តែចំពោះនៅក្នុងបុរីវិញគឺជាភារកិច្ចរបស់ខណ្ឌត្រូវចុះណែនាំ។ លោកថាតាមពិតទៅគេអាចធ្វើទូលកាត់ទទឹងផ្លូវបាន តែកុំធ្វើខ្ពស់ពេក និងខុសស្តង់ដា ព្រមទាំងមានការអនុញ្ញាតមន្ត្រីនៅខណ្ឌនោះផង។

**២.១.៧.៣ ការដះទឹកលើដងផ្លូវ ឬសំរាមលើដងផ្លូវ**

ផ្លូវសាធារណៈពិតជាសំខាន់ក្នុងការទទួលបានការថែទាំ ថែរក្សា សំអាត ឲ្យបានស្អាតជុំវិញបរិវេណផ្លូវ។ នៅពេលដងផ្លូវសាធារណៈពោរពេញទៅដោយសម្រាម វាជាមូលហេតុធ្វើឲ្យមានវត្ថុធាតុរឹង ដូចជាកំប៉ុង ដប ដំថ្ម កាកសំណល់មានជាតិ រអិល មានពោរពេញផ្លូវសាធារណៈ។ ជាក់ស្តែងនៅពេលដែលអ្នកបើកបរជាពិសេសអ្នកបើកបរទោចក្រយានយន្ត គឺពួកគាត់ជួបហានិភ័យជាញឹកញាប់នៅពេលយប់ ដោយគួបផ្សំជាមួយល្បឿន នឹងសំបកកង់មានទំហំតូច ដែលជាហេតុបណ្តាលឲ្យអ្នកបើកបរ រអិលដួល និងខ្ទាយធូលីដល់អ្នកដំណើរជុំវិញ ធ្វើឲ្យប៉ះពាល់ដល់អ្នកដទៃ។

មិនត្រឹមតែប៉ុណ្ណោះទៀតសោត ការប្រកបមុខរបរតាមចិញ្ចើមផ្លូវ ជាពិសេសអ្នកប្រកបអាជីវកម្ម នៅពេលដែលពួកគាត់បញ្ចប់ការលក់ដូរនៅទីតាំងនោះ គឺមានអាជីវករជាច្រើនបានជះទឹក

[38] ដកស្រង់ចេញពី គេហទំព័រ FRESHNEW អាជ្ញាធរខណ្ឌឬស្សីកែវចុះវាយកម្ទេចទូលកាត់ទទឹងផ្លូវដែលតែងតែបង្កគ្រោះថ្នាក់ចរាចរណ៍នៅខាងជើងបុរីកាំកូស៊ីតធី ខណៈមានការរារាំងពីថៅកែជាជនជាតិកូរ៉េ ចុះនៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨ អាចរកបានhttp://m.freshnewsasia.com/index.php/en/localnews/80042-2018-03-02-10-15-57.html

ដោយលាយលំជាមួយកាកសំណល់ នឹងសាប៊ូ ដែលជាមូលហេតុធ្វើឲ្យអ្នកបើកបរក្នុងល្បឿនលឿន គួបផ្សំនឹងសំបកកង់មានភាពសឹករិចរិល ជួបគ្រោះថ្នាក់ដោយយថាហេតុផងដែរ។

## ២.២ ស្ថានភាពនៃគ្រោះថ្នាក់ចរាចរណ៍

### ២.២.១ ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍ទូទាំងប្រទេស

គ្រោះថ្នាក់ចរាចរណ៍បាននឹងកំពុងក្លាយជាបញ្ហាដ៏ធំចំពោះសុខភាពសាធារណៈ និង អភិវឌ្ឍ សេដ្ឋកិច្ចជាតិ។តាមប្រព័ន្ធព័ត៌មានជនរងគ្រោះ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកប្រចាំឆ្នាំ ២០១៦ បានឲ្យដឹងថាមានគ្រោះថ្នាក់ចរាចរណ៍ចំនួន ៣៩១០ករណី និងមានជនរងគ្រោះចំនួន ១១៨៩៩នាក់។ ក្នុងនោះស្លាប់ចំនួន ១៨៥២នាក់ និងរបួសធ្ងន់ចំនួន ៤៦៩៧នាក់ (គិតជាមធ្យមមាន អ្នកស្លាប់ច្រើនជាង ៥នាក់ និងរបួសធ្ងន់ជិត ១៣ នាក់ក្នុងមួយថ្ងៃ)។ ចំនួនអ្នកស្លាប់បានថយចុះ ១៧% និងអ្នករបួសធ្ងន់ថយចុះ ១៤% បើប្រៀបធៀបនឹងឆ្នាំ២០១៥។ ក្នុងចំណោមអ្នកស្លាប់គឺ មាន ៧៣% ជាអ្នក ប្រើប្រាស់ម៉ូតូ។[39]

ទិន្នន័យប្រហាក់ប្រហែលគ្នាផងដែលពីស្ថានភាពគ្រោះថ្នាក់ចរាចរណ៍ទូទាំងប្រទេស របស់ក្រសួងមហាផ្ទៃ (គិតចាប់ពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៥ រហូតដល់ថ្ងៃទី១០ ខែវិច្ឆិការ ឆ្នាំ២០១៦) មានចំនួន ៤,០២៩លើក[40] ជនរងគ្រោះ សរុប ចំនួន ៦,៩៦៧នាក់ ក្នុងនោះស្លាប់ ចំនួន ១,៩២៦នាក់។[41]

នៅក្នុងស្ថានភាពគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកនៅកម្ពុជា ក្រសួងសាធារណការ និងដឹកជញ្ជូន សហការជាមួយ សហភាពសហព័ន្ធយុវជនកម្ពុជា និងគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក បានបកស្រាយពីស្ថានភាពដូចខាងក្រោម៖

- គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកបានបណ្តាលឲ្យមនុស្សស្លាប់ ក្នុងមួយថ្ងៃពីប្រាំនាក់(៥នាក់) ទៅប្រាំមួយនាក់(៦នាក់) និងជាច្រើននាក់ផ្សេងទៀតរងរបួសធ្ងន់ និងស្រាល
- តម្លៃនៃការខាតបង់ប្រចាំឆ្នាំ ដោយគ្រោះថ្នាក់ចរាចរណ៍ត្រូវបានប៉ាន់ប្រមាណចំនួនរាប់រយលានដុល្លាក្នុងមួយឆ្នាំៗ
- ចំនួនអ្នកស្លាប់របួស ពិការ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក មានការកើនឡើងក្នុងអំឡុងពេលបុណ្យសំខាន់ៗពិសេសថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ

---

[39] ទិន្នន័យគ្រោះថ្នាក់ចរាចរណ៍របស់គណៈកម្មាធិការជាតិសុវត្ថិភាពគ្រោះថ្នាក់ចរាចរណ៍ នៅក្នុងឆ្នាំ២០១៦

[40] ប្រភពនាយកដ្ឋាននគរបាលចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ

[41] ដក់ស្រង់ទិន្នន័យរបាយការណ៍ស្តីពីលទ្ធផលការងារសម្រេចបានឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្តរបស់ក្រុមកាងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិក

- ភាគរយនៃអ្នកស្លាប់ភាគច្រើនជាអ្នកជិះ ម៉ូតូ ថ្មើរជើង និងជិះរថយន្តគ្រួសារ
- អ្នកស្លាប់ភាគច្រើនដែលជិះម៉ូតូមានប៉ះទង្គិចក្បាលពេលមានគ្រោះថ្នាក់
- គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក កើតឡើងដោយកត្តាចម្បងចំនួន បួនគឺ កត្តាមនុស្ស កត្តាយានយន្ត កត្តាផ្លូវថ្នល់ និងកត្តាបរិស្ថាន
- កត្តាមនុស្សត្រូវបានរកឃើញថាមានចំនួនច្រើនជាងគេ។[42]

## ២.២.២ ប្រភេទរបួស និងអ្នកស្លាប់

គ្រោះថ្នាក់ចរាចរណ៍សព្វថ្ងៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានកើតឡើងជាច្រើនករណីនៅក្នុងបណ្តារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍នេះផងដែលបានសង្កេតឃើញថា មានរងរបួសស្រាល របួសធ្ងន់ និងស្លាប់។ នៅក្នុងឆ្នាំ២០១៦ មានគ្រោះថ្នាក់ចរាចរណ៍ចំនួន ៣.៩១០[43] ករណី និងជនរងគ្រោះចំនួន១១.៨៩៩នាក់។ ក្នុងចំណោមជនរងគ្រោះមានអ្នកស្លាប់ចំនួន ១.៨៥២ (គិតជាមធ្យមមានអ្នកស្លាប់ច្រើនជាង៥នាក់ក្នុងមួយថ្ងៃ) និងរបួសធ្ងន់៤៦៩៧ នាក់ (គិតជាមធ្យមមានអ្នករបួសធ្ងន់ជិត១៣នាក់ក្នុងមួយថ្ងៃ)។ ចំនួនអ្នកស្លាប់បានថយចុះ ១៧% និងអ្នករងរបួសធ្ងន់ថយចុះ១៤% ធៀបនឹងឆ្នាំ ២០១៥។[44]

ករណីគ្រោះថ្នាក់ចរាចរណ៍នេះផងដែរបានជះឥទ្ធិពល ទៅលើស្នាមនៅ អវយវៈ។ ក្បាលនិងកជាចំណុចដែលងាយរងគ្រោះជាងគេនៅពេលដែលកើតមានគ្រោះថ្នាក់ចរាចរណ៍។ ជនរងគ្រោះទទួលរងក្បាលមាន ៤៩% បន្ទាប់មកបាក់អវយវៈ ២២%, រលាក ១៦% និងដាច់រលាត់អវយវៈ១៥% ។[45]ជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍បានបាត់បង់ជីវិតមាន ១៦% និងរងរបួសធ្ងន់៣៩% និងអ្នកស្លាប់នៅកន្លែងកើតហេតុមាន ៧០% បន្ទាប់មកស្លាប់នៅមន្ទីរពេទ្យ ២៤% និងស្លាប់នៅពេលបញ្ជូន ៦%។ ក្នុងចំណោមជនរងគ្រោះដែលមានរងរបួសធ្ងន់ទាំងអស់មាន ១៤%បានទទួលរងពិការភាព។ អ្នករងពិការភាពដោយការធ្វើចលនាមានភាគរយខ្ពស់ជាងគេ ៨៨% បន្ទាប់មក ពិការដោយមើលមាន ៦% និងពិការដោយការសិក្សានិងចងចាំមាន៣%។[46]

## ២.២.៣ ប្រភេទនៃការប៉ះទង្គិច និងទីតាំងជើងកប

---

[42] ខ្លឹមសារខិតប័ណ្ណផ្សព្វផ្សាយ គោរពច្បាប់ចរាចរណ៍គឺដើម្បីការពារជីវិតអ្នក គ្រួសារអ្នក និងអ្នកដទៃ (ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍)

[43] ចំនួនករណីនេះផ្អែកលើទិន្នន័យនគរបាលចរាចរណ៍តែប៉ុណ្ណោះ។ ១% នៃអ្នកស្លាប់ និង២៧%នៃអ្នករងរបួស ត្រូវបានរាយការណ៍ដោយក្រសួងសុខាភិបាល។

[44] របាយការណ៍ស្តីពីជនរងគ្រោះ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៦, ប្រភេទរបួសស្នាម និងអ្នកស្លាប់

[45] របាយការណ៍ស្តីពីជនរងគ្រោះ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៦, ប្រភេទរបួសស្នាម

[46] របាយការណ៍ស្តីពីជនរងគ្រោះ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៦, ប្រភេទរបួស និងអ្នកស្លាប់,ប្រភេទនៃរបួសស្នាម, ស្ថានភាពនៃរបួសស្នាម

នៅក្នុងការសង្កេតបានឃើញថាគ្រោះថ្នាក់ចរាចរណ៍បានកើតឡើងជាច្រើនប្រភេទ ដោយគ្មានការប្រុងប្រយ័ត្ន និងស្ថានភាពចរាចរណ៍នៅពេលបើកបរផងដែល។ ចំពោះគ្រោះថ្នាក់ចរាចរណ៍ បានដឹងឲ្យច្បាស់ថា មានករណីប៉ះទង្គិចជាច្រើនដូចជា ការប៉ះទង្គិចពីចំហៀង ពីក្រោយ និងពីមុខ។ តាមទិន្នន័យនៃការអង្កេតបានឃើញថា អ្នកស្លាប់ដោយការប៉ះទង្គិចចំពីមុខមាន ៣៥% បន្ទាប់មកការប៉ះទង្គិចពីក្រោយមាន១៨% ប៉ះទង្គិចជាមួយអ្នកថ្មើរជើង ១០% និងក្រឡាប់ ឬដួលខ្លួនឯង ៩%។[47]

បើនិយាយពីទីតាំងជើងកប សូមក្រឡេកមើលពាក្យថា**ជើងកប** តាមវចនានុក្រមរបស់**សម្តេចព្រះសង្ឃរាជ ជួន ណាត** បានផ្តល់និយមន័យថា សេចក្តីអន្តរាយដែលមានប្រចាំនៅទីកន្លែងណាមួយ[48]។ ពាក្យថា **ជើងកប** ដដែលនេះផងដែល បានផ្តល់និយមន័យថា ជាកំណាត់ផ្លូវមានប្រវែង៣០០ ម៉ែត្រ ដែលមានគ្រោះថ្នាក់យ៉ាងតិចចំនួន៣ករណី និងមានអ្នកស្លាប់ចាប់ពីមួយនាក់ក្នុងរយៈពេលមួយឆ្នាំ[49]។តំបន់ដែលមានគ្រោះថ្នាក់ជាញឹកញាប់ជាងគេ (តំបន់ជើងកប) មានចំនួន២២ ទីតាំងសំខាន់ៗ តាមបណ្តោយផ្លូវក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងនោះរួមមាន៖

ផ្លូវជាតិលេខ ១ ៖ឃុំព្រៃអង្គុញ ក្រុងបាវិតខេត្តស្វាយរៀង
ឃុំបាវិត ក្រុងបាវិត ខេត្តស្វាយរៀង
ផ្លូវជាតិលេខ ៧ ៖ឃុំ ស្នួល ស្រុកស្នួល ខេត្តក្រចេះ
ឃុំ សួង ស្រុកសួង ខេត្តត្បូងឃ្មុំ
ផ្លូវជាតិលេខ ៦ ៖ឃុំផ្អាវ ស្រុកបាធាយ ខេត្តកំពង់ចាម
ឃុំ បាធាយ ស្រុកបាធាយ ខេត្តកំពង់ចាម
ផ្លូវជាតិលេខ ៦១ ៖ឃុំ សំបូរ ស្រុកបាធាយ ខេត្តកំពង់ចាម
ឃុំ សំបូរ ស្រុកបាធាយ ខេត្តកំពង់ចាម
ផ្លូវជាតិលេខ ៥ ៖ឃុំប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
ឃុំប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
ផ្លូវជាតិលេខ ៦ ៖ឃុំជ្រុំ ស្រុកសន្ទុក ខេត្តកំពង់ធំ
ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តព្រះសីហនុ
ឃុំទ្រាល ស្រុកបារាយណ៍ ខេត្តកំពង់ធំ

[47] ទិន្នន័យនៃរបាយការណ៍ស្តីជនរងគ្រោះ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ២០១៦, ភាគរយនៃអ្នកស្លាប់តាមប្រភេទប៉ះទង្គិច

[48] វចានុក្រមសម្តេចសង្ឃរាជជួន ណាត ដែលបោះពុម្ពផ្សាយនៅក្នុងឆ្នាំ ១៩៦៧

[49] និយមន័យក្នុងចរាចរណ៍ផ្លូវគោករបស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក

ឃុំអណ្ដូងថ្ម ស្រុកព្រៃ ខេត្តកំពង់ធំ

ផ្លូវជាតិលេខ ៤ ៖ភូមិ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

ផ្លូវខេត្ត ៖ភូមិ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

ផ្លូវតូច ៖ភូមិ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

ផ្លូវខេត្ត ៖ភូមិ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

ផ្លូវជាតិលេខ ៤ ៖ឃុំវាលរិញ ព្រៃនុប ខេត្តព្រះសីហនុ

ផ្លូវជាតិលេខ ៣ ៖ឃុំអង្គតាសោម ក្រុងតាខ្មៅ ខេត្តតាកែវ

ផ្លូវជាតិលេខ ២ ៖ឃុំព្រៃស្លឹក ស្រុងទ្រាំង ខេត្តតាកែវ។[50]

អ្នកស្លាប់នៅលើផ្លូវជាតិមានភាគរយខ្ពស់ជាងគេ ៧០% បន្ទាប់មកផ្លូវលំ ១១% និងផ្លូវខេត្ត ១១%។[51]

## ២.២.៤ ពេលវេលានៃគ្រោះថ្នាក់

គ្រោះថ្នាក់ចរាចរណ៍ត្រូវបានសង្កេតឃើញថាមានការកើតឡើងច្រើន ជាពិសេសក្នុងពេលវេលាបុណ្យទាន ឈប់សម្រាក ដែលប្រជាពលរដ្ឋភាគច្រើនបានចេញទៅដំណើរស្រុកកំណើត ខ្លះទៅរមណីដ្ឋាន គ្រប់ទីជិត ទីឆ្ងាយ ជាហេតុធ្វើឲ្យចរាចរណ៍នៅលើដងផ្លូវមានភាពមមាញឹក។ មិនត្រឹមតែប៉ុណ្ណោះគ្រោះថ្នាក់ចរាចរណ៍ដែលកើតឡើងជារៀងរាល់ថ្ងៃនៅក្នុងប្រទេសកម្ពុជា បានសង្កេតឃើញថា ចំនួនអ្នកស្លាប់ដែលមានភាគរយខ្ពស់ជាងគេកើតឡើងនៅចន្លោះពីម៉ោង ៦ល្ងាចដល់ ១០យប់ ៣៣%, ថ្ងៃអាទិត្យគឺថ្ងៃដែលមានភាគរយអ្នកស្លាប់ច្រើនជាងគេ ១៧% បន្ទាប់មកថ្ងៃសៅរ៍ ១៦% និងថ្ងៃច័ន្ទ ១៤%, អ្នកស្លាប់មានភាគរយខ្ពស់ជាងគេគឺនៅខែមេសា ១១% ខែមករា ១១% បន្ទាប់មក ខែកុម្ភៈ១០%។[52]

## ២.៣ ផលប៉ះពាល់នៃគ្រោះថ្នាក់ចរាចរណ៍

### ២.៣.១ សង្គម

ចរាចរណ៍នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្នបានកំពុងជះឥទ្ធិពលទៅលើសង្គមជាតិខ្មែរ បច្ចុប្បន្នយ៉ាងខ្លាំង។ នៅពេលដែលចរាចរណ៍មានភាពមមាញឹកខ្លាំង វាបានបណ្ដាលឲ្យមានផលប៉ះពាល់ដល់សង្គមដូចជា គ្រោះថ្នាក់ចរាចរណ៍ កកស្ទះចរាចរណ៍ ការបើកបរគ្មានការគោរពសិទ្ធគ្នា ឬក៏អាចមានជម្លោះផ្សេងៗដែលកើតឡើងចេញពីការមិនចេះអធ្យាស្រ័យគ្នាផងដែល។ បើក្រឡេកមើល

[50] ទីតាំងជើងកបនៃព្រះរាជាណាចក្រកម្ពុជា របស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ក្នុងចុងឆ្នាំ២០១៦

[51] ទិន្នន័យជាភាគរយនៃ សូចនាករអនុវត្តន៍សកម្មភាពសុវត្ថិភាពចរាចរណ៍

[52] ទិន្នន័យពីគណៈកម្មាធិការជាតិស្តីពីគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកឆ្នាំ២០១៦, ពេលវេលានៃគ្រោះថ្នាក់

ទិដ្ឋភាពសព្វថ្ងៃនៃស្ថានភាពចរាចរណ៍បានកំពុងតែមានភាពមមាញឹកខ្លាំងដែលជាហេតុធ្វើឲ្យ អ្នកបើកបរជាច្រើនមានភាពធុញទ្រាន់ នៅពេលដែលពួកគេចង់ចេញពីកន្លែងមួយទៅកន្លែងមួយជាពិសេសគឺនៅក្នុងរាជធានីភ្នំពេញតែម្តង។ មានមតិជាច្រើនបានបង្កើតឡើងជាចម្ងល់ អំពីការកកស្ទះនៅលើដងផ្លូវចរាចរណ៍ ដូចមាននៅក្នុងគេហទំព័រមួយបានចោទជាសំណួរសួរ ថា ធ្លាប់ឆ្ងល់ទេហេតុអ្វីនៅភ្នំពេញចេះតែស្ទះខ្លាំងឡើងៗ ហើយកើតឡើងមកពីមូលហេតុអ្វី និងមានដំណោះស្រាយបែបណា?[53]

បញ្ហាចរាចរណ៍នេះបានជះឥទ្ធិពលដល់សង្គមយ៉ាងខ្លាំងនាពេលបច្ចុប្បន្នជាពិសេស នៅក្នុងរាជធានីភ្នំពេញ។ ការកកស្ទះបានកើតឡើងជារឿយនៅតាមដងផ្លូវមួយចំនួន។ វាបានធ្វើឲ្យទីក្រុងបាត់បង់សោភ័ណភាព ខូចខាតទ្រព្យសម្បត្តិសាធារណៈ ខាតពេលវេលារបស់អ្នកបើកបរ បាត់បង់សុជីវធម៌ និងសីលធម៌នៅពេលបើកបរ និងបានបង្ហាញឲ្យភ្ញៀវទេសចរណ៍ជាតិ អន្តរជាតិវាយតម្លៃសោភ័ណភាព សីលធម៌ ក្នុងការបើកបរមានកម្រិតទាប។ លើសពីនេះ នៅពេលដែលមានគ្រោះថ្នាក់ចរាចរណ៍កើតមានឡើង វាបានបង្កើតឲ្យមានភាពស្មុគស្មាញ ច្រើននៅលើដងផ្លូវ។ ការបាត់បង់ជីវិត របួសស្លាកស្នាមដែលកើតឡើងនៅលើដងផ្លូវបានជះឥទ្ធិពលអវិជ្ជមាន ដែលបណ្តាលឲ្យខាតបង់ ថវិកា ពេលវេលា សេដ្ឋកិច្ច និងកំណើនតួលេខគ្រោះថ្នាក់ចរាចរណ៍កើតឡើងជាហេតុធ្វើឲ្យមជ្ឈដ្ឋានជុំវិញពិភពលោកវាយតម្លៃប្រទេសកម្ពុជា ទន់ខ្សោយ។

### ២.៣.២ សេដ្ឋកិច្ច

សេដ្ឋកិច្ចនៅក្នុងប្រទេសនីមួយៗត្រូវបានពឹងផ្អែកយ៉ាងសំខាន់ទៅលើប្រជាពលរដ្ឋរបស់ ខ្លួនមិនត្រឹមតែប៉ុណ្ណោះការទទួលបានពន្ធនៃការនាំចូល និងលក់ផលិតផល ជាពិសេសយានយន្តផងដែល។ ចរន្តសេដ្ឋកិច្ចត្រូវបានរត់នៅពេលប្រជាពលរដ្ឋ ឬបុគ្គលម្នាក់ៗត្រូវបានប្រើប្រាស់ឬចំនាយបានរាប់ចូលជាចរន្តសេដ្ឋកិច្ចរបស់ប្រទេសនោះ។ ជាក់ស្តែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាប្រទេសកំពុងអភិវឌ្ឍត្រូវបាននាំចូលយានយន្តពីបរទេសជាច្រើននិងមានអត្រាកំណើននៃគ្រោះថ្នាក់ចរាចរណ៍ជាច្រើនផងដែល។ នៅពេលដែលគ្រោះថ្នាក់ចរាចរណ៍កើតឡើងគឺ បុគ្គលនោះត្រូវបានខាតបង់ជាច្រើន ជាពិសេស ថវិកា ពេលវេលា សុខភាព និងកត្តាជាច្រើនទៀត លើសពីនេះទៀតសោត រាជរដ្ឋាភិបាល ក៏ខាតបង់ដែលនៃថវិការដ្ឋក្នុងការចំណាយទៅលើការជួសជុលទ្រព្យសម្បត្តិ សាធារណៈ ដូចជា បង្គោលភ្លើង របងពុះចែកទ្រូងផ្លូវ។ល។ ដែលវាតែងតែខូចខាតនៅពេលដែលមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង។ ករណីគ្រោះថ្នាក់មួយចំនួនធំ បានធ្វើឲ្យ

---

[53] គេហទំព័ររបស់ khmerload, ធ្លាប់ឆ្ងល់ទេ ហេតុអ្វីនៅភ្នំពេញចេះតែស្ទះខ្លាំងឡើងៗ ហើយកើតឡើងមកពីមូលហេតុអ្វី និងមានដំណោះស្រាយបែបណា?, ថ្ងៃទី០៦ ខែវិច្ឆិការ ឆ្នាំ២០១៧

ខូចខាតដល់សម្បត្តិ សាធារណៈរបស់រដ្ឋក៏ដូចជាសម្បត្តិឯកជនផ្សេងៗទៀត ព្រមទាំងបានឆក់យកអាយុជីវិតមនុស្សជាច្រើនផងដែរ។ ជាពិសេសប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍបានកំពុងរងគ្រោះយ៉ាងខ្លាំងពីការខាតបង់ នៃគ្រោះថ្នាក់ចរាចរណ៍នេះ ដូចមានសិក្សាស្រាវជ្រាវរបស់ធនាគារពិភពលោកបានផ្ដល់ថា នេះជាវិធានការ ដើម្បីបញ្ចូលវិធានការការពារសុវត្ថិភាពចូលទៅក្នុងគម្រោងរបស់ពួកគេ ការធ្វើនៅពេលនេះ នឹងត្រូវចំណាយប្រាក់តិចជាង នៅពេលក្រោយនៅពេលផ្លូវទាំងអស់នេះនឹងត្រូវដាក់ ប្រើប្រាស់រាប់ទសវត្សរ៍។[54] ក្នុងន័យនេះប្រសិនបើគេមិនបញ្ចូលវិធានការណ៍ ការពារសុវត្ថិភាពនៅពេលនេះ គេនឹងមានហេដ្ឋារចនាសម្ព័ន្ធដែលមានគ្រោះថ្នាក់ក្នុងរយៈពេលវែង។ មិនត្រឹមតែប៉ុណ្ណោះទៀតសោតនៅក្នុងការខាតបង់ថវិការជាតិកម្ពុជាប្រមាណ ៣០០លានដុល្លាអាមេរិចក្នុងមួយឆ្នាំ ដោយមិនទាន់ទូទាត់គិតបញ្ចូលពីផលប៉ះពាល់រយៈពេលវែងនៅឡើយ។[55]

បើក្រឡេកមើលសេដ្ឋកិច្ចក្នុងក្រុមគ្រួសារវិញ សង្កេតឃើញថា បញ្ហាគ្រោះថ្នាក់ចរាចរណ៍ពិតជាប៉ះពាល់ខ្លាំងចំពោះក្រុមគ្រួសារនីមួយៗនៅពេលដែលបុគ្គលណាម្នាក់រងគ្រោះថ្នាក់ចរាចរណ៍។ នៅពេលដែលគ្រោះថ្នាក់ចរាចរណ៍កើតឡើងតែងតែមានរបួសស្នាម ឬអាចប៉ះពាល់អាយុជីវិតដែលទាមទារឲ្យមានការទទួលសេវាព្យាបាលពីមន្ទីរពេទ្យ។ ការព្យាបាល ការទទួលបានសេវា ត្រូវទទួលបន្ទុករាប់រងដោយក្រុមគ្រួសារនីមួយៗ ដែលជាហេតុធ្វើឲ្យការចំណាយរបស់ក្រុមគ្រួសារនីមួយៗត្រូវខាតបង់អស់ច្រើន។ មិនត្រឹមតែប៉ុណ្ណោះត្រូវទទួលរ៉ាប់រង ចំពោះមុខច្បាប់ ការផាកពិន័យ(ជនដែលប្រព្រឹត្តផ្ទុយនឹងច្បាប់) និងត្រូវបង់ការខូចខាតផ្សេងៗទៀតដែលប៉ះពាល់ដល់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ទ្រព្យសម្បត្តិសាធារណៈ និងជនរងគ្រោះ។ លើសពីនេះទៀតសោត ក្នុងករណីដែលគ្រោះថ្នាក់ចរាចរណ៍ធ្វើឲ្យបាត់បង់អាយុជីវិត សមាជិកណាម្នាក់ក្នុងក្រុមគ្រួសារ នោះពិតជាពិបាកខ្លាំងណាស់ចំពោះសេដ្ឋកិច្ចក្រុមគ្រួសារនោះ។

### ២.៣.៣ សុខភាព រូបរាងកាយ និងពេលវេលា

គ្រោះថ្នាក់ចរាចរណ៍នៅកម្ពុជាបានកើតឡើងជារៀងរាល់ថ្ងៃ នៅក្នុងព្រះរាជាណាចក្រកម្ពុជាការបើកបរនៅលើដងផ្លូវ ត្រូវបានប្រជាពលរដ្ឋខ្មែរមានការព្រួញបារម្ភយ៉ាងខ្លាំងនៅពេលដែលពួកគេ ធ្វើដំណើរ។ នៅពេលដែលគ្រោះថ្នាក់ចរាចរណ៍កើតឡើងគឺតែងតែសង្កេតឃើញថា មានរបួស

---

[54] ដកស្រង់ពីគេហទំព័រ វីអូអេ, របាយការណ៍ធនាគារពិភពលោកបង្ហាញថាគ្រោះថ្នាក់ចរាចរណ៍រារាំងដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍, អន្តរជាតិ ថ្ងៃ ១៣ ខែមករា ២០១៨ អាចរកបានhttps://khmer.voanews.com/a/report-says-traffic-accidents-hold-back-developing-economies/4206106.html

[55] ដកស្រង់ពីគេហទំព័រ Propertyarea, កម្ពុជាខាតបង់សេដ្ឋកិច្ច ៣០០លានដុល្លាដោយសារគ្រោះថ្នាក់ចរាចរណ៍, ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៧ អាចរកបាន http://www.propertyarea.asia

ស្នាម ដែលប៉ះពាល់ដល់រូបរាងកាយ និងសុខភាព។ វាបានបន្សល់ទុកនូវជនរងគ្រោះជាច្រើន ដែលប៉ះពាល់ដល់អវយវៈ ពិការភាព បាត់សមត្ថភាព និងបាត់បង់ពេលវេលា បន្ទាប់ពីគ្រោះថ្នាក់ចរាចរណ៍។ គ្រោះថ្នាក់ចរាចរណ៍នេះផងដែលបានគំរាមកំហែងអាយុជីវិត ប្រជាពលរដ្ឋនៅតាមដងផ្លូវសាធារណៈ និងបង្កើតឲ្យមានរបួសស្លាកស្នាម ដល់ថ្នាក់បាត់បង់ជីវិតដល់ប្រជាពលរដ្ឋខ្មែររាប់សែននាក់ក្នុងមួយឆ្នាំ ថែមទាំងធ្វើឲ្យស្ថានភាពក្នុងការខាតបង់សេដ្ឋកិច្ចជាតិ ជាពិសេសនៅក្នុងក្រុមគ្រួសារ។ ពេលវេលាក្នុងការប្រកបមុខរបរ រកស៊ីពិបាក នៅពេលមានការកក់ស្ទះ ដែលខាតបង់ពេលវេលាប្រាក់កាកជាច្រើនផង ដែរ។

# ជំពូកទី៣
# ដំណោះស្រាយ និងទិសដៅអនាគត

## ៣.១ វិធានការទប់ស្កាត់ និងដំណោះស្រាយ

ដើម្បីទប់ស្កាត់នូវបញ្ហាផ្សេងៗ និងគ្រោះថ្នាក់ចរាចរណ៍ នៅក្នុងសង្គមខ្មែរ ទាំងប្រជាជនខ្លួនឯង ទាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អង្គការសង្គមស៊ីវិលនានា បានកំពុងតែចូលរួមយ៉ាងសកម្មក្នុងការស្វែងរកដំណោះស្រាយវិធានការនានាដើម្បីទប់ស្កាត់ និងបង្កើតការអនុវត្តនូវច្បាប់ដែលជាប់ពាក់ព័ន្ធជាមួយនឹង ចរាចរណ៍នេះឲ្យច្បាស់លាស់ និងមានប្រសិទ្ធភាពខ្ពស់។ ដើម្បីចូលរួមទប់ស្កាត់នូវបញ្ហាផ្សេងៗ និងគ្រោះថ្នាក់ចរាចរណ៍ ខ្ញុំបានសូមលើកយកនូវកត្តាផ្សេងៗដូចខាងក្រោមនេះដែលជាកត្តាចាំបាច់ក្នុងការទប់ស្កាត់ និងកាត់បន្ថយនូវអត្រាគ្រោះថ្នាក់ចរាចរណ៍ និងអ្នកស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ ដែលក្នុងនោះរួមមាន៖

### ៣.១.១ គោលនយោបាយ

ដើម្បីធ្វើឲ្យសង្គមខ្មែរយើង មានសណ្តាប់ធ្នាប់ ប្រជាពលរដ្ឋរស់នៅក្នុងសុខសន្តិភាព ទាំងផ្លូវកាយ និងផ្លូវចិត្ត ប្រកបដោយភាពត្រឹមត្រូវ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានចេញនូវគោលនយោបាយសាធារណៈ ដើម្បីចូលរួមធ្វើឲ្យសង្គមនេះមានសណ្តាប់ធ្នាប់ល្អ និងសុវត្ថិភាព និងមានភាពងាយស្រួល។ ជាក់ស្តែងគោលនយោបាយជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដែលបានគាំទ្រយ៉ាងខ្លាំងក្លាពីថ្នាក់ដឹកនាំ គឺ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជា**។ ម្យ៉ាងវិញទៀត គោលនយោបាយជាតិនេះតម្រូវឲ្យមានការចូលរួម និងគាំទ្រពីគ្រប់ស្ថាប័នជាតិ និងអន្តរជាតិ ដែលជាកត្តាគន្លឹះក្នុងការកៀរគរធនធាន រួមមាន ធនធានមនុស្ស ហិរញ្ញវត្ថុ សម្ភារៈ បរិក្ខា និងបច្ចេកទេសតាមតម្រូវការចាំបាច់។ ទោះបីជាមានកត្តាខ្លះដែលនាំឲ្យមានការលំបាក និងការប្រឈមក្នុងការកាត់បន្ថយចំនួនអ្នកស្លាប់ និងរបួសដោយសារគ្រោះថ្នាក់ចរាចរណ៍នៅព្រះរាជាណាចក្រកម្ពុជា ឲ្យមកកម្រិតទាបបំផុតនាពេលខាងមុខតាមគោលដៅដែលបានកំណត់ក្នុងគោលនយោបាយជាតិស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកនេះ ក៏ដោយ ក៏នៅមានហេតុផល និងកត្តាអំណោយផលជាច្រើនដែលនាំឲ្យ ព្រះរាជាណាចក្រកម្ពុជាសម្រេចបានជោគជ័យតាមគោលនយោបាយជាតិដែលបានអនុម័ត។ បើយោងតាមប្រសាសន៍ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានចាត់ទុកថា គោលនយោបាយសុវត្ថិភាពចរាចរណ៍ផ្លូវគោកមាន គឺជាមធ្យោបាយដ៏មានសក្តានុពល និងជាកត្តាគន្លឹះធ្វើជាត្រីវិស័យសម្រាប់រក្សាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព ដល់អ្នក

ប្រើប្រាស់ផ្លូវថ្នល់នៅលើដងផ្លូវថ្នល់នៃប្រទេសកម្ពុជា[56]។ ពិតណាស់នៅក្នុងគោលនយោបាយដែលកំពុងអនុវត្តសព្វថ្ងៃបានកំពុងអនុវត្តស្របទៅតាម ការគ្រោងទុក ដែលស្ថិតក្នុងឆ្នាំ ២០១៤ ដល់ឆ្នាំ ២០២០។ ក្នុងយុទ្ធសាស្ត្រសកម្មភាពនៃគោលនយោបាយសុវត្ថិភាពចរាចរណ៍ផ្លូវគោកបាន កំពុងតែមានការកាត់បន្ថយនៃបញ្ហាផ្សេងៗនៅលើដងផ្លូវ ជាពិសេសកាត់បន្ថយអត្រាគ្រោះថ្នាក់ចរាចរណ៍។ នៅក្នុងយុទ្ធសាស្ត្រនៃគោលនយោបាយដដែលបានកំពុងតែអនុវត្តបានយ៉ាងសកម្មភាពជាពិសេសស្ថាប័នដែលជាប់ពាក់ព័ន្ធ មន្ត្រីរាជការ ប្រជាពលរដ្ឋ បានចូលរួម អនុវត្តយុទ្ធសាស្ត្រ ៨ចំណុច នៃគោលនយោបាយជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក។ លើសពីនេះទៀតសោត គោលនយោបាយសុវត្ថិភាពចរាចរណ៍ផ្លូវគោក បានរៀបចំផែនការសកម្មភាពបានយ៉ាងច្បាស់លាស់ ដែលមានផែនការយ៉ាងច្បាស់លាស់ចំនួន ៨ធំៗ ដែលរួមមាន៖

- សកម្មភាពទី១ ការគ្រប់គ្រងសុវត្ថិភាពចរាចរណ៍
- សកម្មភាពទី២ សុវត្ថិភាពហេដ្ឋារចនាសម្ពន្ធផ្លូវថ្នល់
- សកម្មភាពទី៣ សុវត្ថិភាពយានយន្ត
- សកម្មភាពទី៤ អាកប្បកិរិយាប្រកបដោយសុវត្ថិភាពរបស់អ្នកប្រើប្រាស់ផ្លូវថ្នល់
- សកម្មភាពទី៥ ប្រព័ន្ធសង្គ្រោះបន្ទាន់វេជ្ជសាស្ត្រ
- សកម្មភាពទី៦ វិសោធនកម្មច្បាប់ និងពង្រឹងការអនុវត្តច្បាប់
- សកម្មភាពទី៧ ប័ណ្ណបើកបរ
- សកម្មភាពទី៨ ការគ្រប់គ្រងនិងវាយតម្លៃទៅលើសុវត្ថិភាពដឹកជញ្ជូនអ្នកដំណើរនិងទំនិញ ។

លើសពីនេះទៀតសោតរាជរដ្ឋាភិបាល បានគ្រោង និងរៀបចំគោលនយោបាយទៅតាមវិស័យដើម្បីចូលរួមចំណែក ក្នុងការដោះស្រាយបញ្ហាផ្សេងៗទៅលើបញ្ហាចរាចរណ៍ផ្លូវគោក។ ជាក់ស្តែង ក្នុងក្រសួងកាងារបណ្តុះបណ្តាល វិជ្ជាជីវៈ បានគ្រោងនឹងចាប់ផ្តើមគោលនយោបាយមួយទាក់ទង និងគ្រោះថ្នាក់ចរាចរណ៍, យោងតាមប្រសាសន៍ ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រោងនឹងចាប់ផ្តើមគោលនយោបាយជាតិដើម្បីកាត់បន្ថយចំនួនគ្រោះថ្នាក់ចរាចរណ៍ដែលពាក់ព័ន្ធនឹងកម្មកររោងចក្រកាត់ដេរ ដែលត្រូវបានដឹកជញ្ជូនទៅមកពីរោងចក្រ។

[56] ដក់ស្រង់ចេញពីកិច្ចប្រជុំគណៈរដ្ឋមន្ត្រី ក្នុងការពិនិត្យនិងអនុម័ត គោលនោយបាយសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៅថ្ងៃទី២១ ខែកុម្ភះ ឆ្នាំ២០១៤

គោលនយោបាយនេះនឹងលើកទឹកចិត្តឲ្យនិយោជក និងអ្នកបើកបរផ្តល់អាទិភាពសុវត្ថិភាពចរាចរណ៍[57]។

គោលនយោបាយទាំងឡាយដែល ពាក់ព័ន្ធនឹង ចរាចរណ៍ផ្លូវក្នុងការចូលរួមដោះស្រាយបញ្ហាផ្សេងៗ ទាក់ទង និងចរាចរណ៍ផ្លូវគោកនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានគាំទ្រ និងចូលរួមដោះស្រាយបញ្ហាផ្សេងៗ ស្វែងរកដំណោះស្រាយ ដែលអាចជួយធ្វើឲ្យសង្គមខ្មែរយើង មានសណ្តាប់ធ្នាប់ល្អ កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងធ្វើឲ្យសង្គមមានភាពរីកចម្រើនស្របទៅតាមការអនុវត្តស្របទៅតាមគោលដៅ ដែលបានគ្រងទុកដោយជោគជ័យ និងមានប្រសិទ្ធភាព ថែមទាំងអាចចាក់ផុតនាពេលខាងមុខឆាប់ៗ តាមរយៈយន្តការនៃការចូលរួមពិភាក្សាពីគ្រប់ភាគីពាក់ព័ន្ធ។

### ៣.១.២ កត្តាច្បាប់

យើងដឹងហើយថាស្ថានភាពចរាចរណ៍ផ្លូវគោកនៅព្រះរាជាណាចក្រកម្ពុជា កំពុងមានស្ថានភាពមួយមិនសូវល្អប្រសើរ ដោយស្ថិតមើលទិដ្ឋភាពជាក់ស្តែងទៅតាមរបាយការណ៍ចំនួនគ្រោះថ្នាក់ចរាចរណ៍បានកើតឡើងជារៀងរាល់ថ្ងៃ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ប្រជាពលរដ្ឋខ្មែរមួយចំនួន ជាពិសេសនៅតាមទីជនបទស្រុកស្រែចម្ការ គឺការយល់ដឹងពីតថភាពច្បាប់គឺនៅមានកម្រិត ដែលជាហេតុធ្វើឲ្យពួកគាត់ខ្វះការយល់ដឹងពី ច្បាប់ចរាចរណ៍ ដែលជាហេតុឲ្យមានផលវិបាក។ បើនិយាយពីច្បាប់គឺ មានសារៈសំខាន់ណាស់សំរាប់ប្រជាពលរដ្ឋគ្រប់រូបគួរតែយល់ដឹងពីសិទ្ធិកាតព្វកិច្ច ឬវិធីសាស្ត្រផ្សេងៗ ដែលមានចែងក្នុងច្បាប់សម្រាប់ការពារ និងអនុវត្តតាមច្បាប់ដែលមានចែង។ វាដើរ តួនាទីយ៉ាងសំខាន់សម្រាប់រាជរដ្ឋាភិបាល ជាពិសេសប្រជាពលរដ្ឋគ្រប់រូបដែលត្រូវតែចូលរួមយ៉ាងសកម្មក្នុងការអនុវត្តច្បាប់ និងគោរពច្បាប់ ជាពិសេសច្បាប់ចរាចរណ៍ផ្លូវគោក។

ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកនៃព្រះរាជាណាចក្រកម្ពុជា គឺត្រូវបានរាជរដ្ឋាភិបាលបានធ្វើវិសោធកម្មដោយសិក្សាទៅលើទិដ្ឋភាពជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា។ ដើម្បីឈានទៅរកការដោះស្រាយបញ្ហា និងបំពេញចន្លោះខ្វះខាតផ្សេងៗ រាជរដ្ឋាភិបាលបានសម្រេចចិត្តលុប ឬកែសម្រួល បំពេញបន្ថែមនូវច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកដោយមានការធ្វើវិសោធកម្ម មាត្រា៨ មាត្រា៥០ មាត្រា៥១ មាត្រា៥៧ មាត្រា៥៨ មាត្រា៧៥ មាត្រា៧៧ មាត្រា៨២ និងមាត្រា៩០ និងពិនិត្យចប់

[57] ដកស្រង់ចេញពីគេហទំព័រ អង្គការទិន្នន័យអំពីការអភិវឌ្ឍ, គោលនយោបាយសុវត្ថិភាពចរាចរណ៍ត្រូវបានគ្រោងទុក, ចុះផ្សាយថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨, អាចរកបាន https://opendevelopmentcambodia.net/km/news/road-safety-policy-planned/

សព្វគ្រប់ទាំងស្រុងនៅ ថ្ងៃទី៤ ខែមករា ឆ្នាំ២០១៧ នាសម័យប្រជុំជាវិសាមញ្ញនីតិកាលទី៣។

ដើម្បីផ្សព្វផ្សាយបញ្ជៀបការយល់ដឹងដល់ប្រជាពលរដ្ឋ និងដើម្បីស្វែងរកដំណោះស្រាយផ្សេងៗ រាជរដ្ឋាភិបាលជាពិសេសក្រសួងស្ថាប័នពាក់ព័ន្ធបានរៀបចំឲ្យមានសកម្មភាពចុះតាមជនបទទីក្រុង ស្រុកស្រែចំការ ក្នុងគោលបំណងពន្យល់ផ្សព្វផ្សាយពីច្បាប់ចរាចរណ៍ផ្លូវគោក ដែលក្នុងរូមមាន សកម្មភាពផ្សព្វផ្សាយរបស់ក្រសួងសាធារណៈការ និងដឹងជញ្ជូន បានចុះផ្សព្វផ្សាយច្បាប់ស្តីចរាចរណ៍ផ្លូវគោក និងផ្សព្វផ្សាយផលប៉ះពាល់ការប្រើប្រាស់គ្រឿងញៀន នៅតាមវិទ្យាល័យ មួយចំនួននៅតាមបណ្តាខេត្ត ដូចជា ខេត្តកំពង់ធំ ខេត្តក្រចេះ ខេត្តបាត់ដំបង ខេត្តកំពតខេត្តតាកែវ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តប៉ៃលិន និងខេត្តកែប[58]។ មិនត្រឹមតែប៉ុណ្ណោះទៀតសោត នៅក្នុងបញ្ហា ផ្សេងៗដែលទាក់ទង និងជម្លោះដោយកើតឡើងដោយសារគ្រោះថ្នាក់ចរាចរណ៍ ក៏មានច្បាប់ផ្សេងៗទៀតដែលជាប់ពាក់ព័ន្ធ និងចរាចរណ៍ផ្លូវគោក ដើម្បីស្វែងរកដំណោះស្រាយ បញ្ហាផ្សេងៗ ឲ្យមានប្រសិទ្ធភាព។

ទោះជាយ៉ាងណាក៏ដោយច្បាប់តែមួយមុខ ពិតជាមិនគ្រប់គ្រាន់ឡើយ សម្រាប់ការចូលរួមទប់ស្កាត់ និងបង្ការទៅលើគ្រោះថ្នាក់ចរាចរណ៍ និងបញ្ហាផ្សេងៗ គឺត្រូវមានការចូលរួមពីសំណាក់គ្រប់ភាគីពាក់ព័ន្ធទាំងឡាយជាពិសេសប្រជាពលរដ្ឋ និងអាជ្ញាធរមានសមត្ថកិច្ច ទើបជាកត្តាដែលមានប្រសិទ្ធភាពបំផុត ក្នុងការចូលរួមការអនុវត្តច្បាប់ទាំងនេះឲ្យមានលក្ខណៈកាន់តែល្អប្រសើរឡើងថែមទៀត ។

### ៣.១.៣ រាជរដ្ឋាភិបាល

ប្រាកដណាស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងបញ្ហាផ្សេងៗដែលកើតមានឡើងនៅលើដងផ្លូវ។រាជរដ្ឋាភិបាលបានព្យាយាមគិតគូរយ៉ាងសកម្ម ទៅលើវិធានការផ្សេងៗ ការពិនិត្យទៅលើច្បាប់ គោលនយោបាយ និងអនុវត្តរបស់មន្ត្រីក្រោមឱវាទដើម្បី ពិនិត្យ និងស្វែងរកដំណោះស្រាយល្អ ស្របទៅតាមភាពជឿនលឿន និងបញ្ជៀសភាពគ្រោះថ្នាក់ ផ្សេងៗដែលកើតឡើងផ្សេងៗ។ សព្វថ្ងៃនេះ រាជរដ្ឋាភិបាលបានសហការជាមួយអង្គការជាតិ និងអន្តរជាតិ និងអង្គការមិនមែន រដ្ឋាភិបាល ក្រុមហ៊ុនអាជីវកម្មផ្សេងៗ ដើម្បីចូលរួមទប់ស្កាត់នូវបញ្ហាផ្សេងៗដែលប៉ះពាល់ដល់សង្គមជាតិ និងព្យាយាមទប់ស្កាត់ឬលុបបំបាត់ទៅតាមលទ្ធភាពដែលអាចធ្វើបាន។ យើងសង្កេតឃើញថា ការចេញបញ្ហា ឬវិធានការផ្សេងៗពីសំណាក់រាជរដ្ឋាភិបាល ឲ្យក្រសួង ស្ថាប័នពាក់ព័ន្ធ គឺជាសញ្ញាបង្ហាញថាកិច្ចការនេះ កំពុងលេចចេញ

[58] ដកស្រង់ចេញពីគេហទំព័រផ្លូវការក្រសួងសាធារណការ និងដឹកជញ្ជូន ដែលចុះផ្សាយនៅថ្ងៃទី ២២ ខែកុម្ភះ ឆ្នាំ២០១៨

ជារូបរាងឡើងបណ្តើរ ហើយ។ ដោយសារកំណើនសេដ្ឋកិច្ចជាតិពីមួយឆ្នាំៗទៅមួយឆ្នាំ បានធ្វើឲ្យរាជរដ្ឋាភិបាលមានលទ្ធភាព ពង្រីកសក្តានុពល ជាពិសេសទៅផ្នែកហេដ្ឋារចនាសម្ពន្ធផ្លូវ ស្ពាន និងមានរៀបចំឲ្យមានកាមេរ៉ានៅតាមដងផ្លូវសាធារណៈ មិនត្រឹមតែប៉ុណ្ណោះទៀតសោត បានកំពុងរៀបចំសាងសង់ផ្លូវជាច្រើនខ្សែ និងជួសជុលបន្ថែមដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋ និងបានចូលរួមជាច្រើនក្នុងការកាត់បន្ថយ គ្រោះថ្នាក់ចរាចរណ៍ និងបញ្ហាក៏ស្ទះ ជាពិសេសនៅទីក្រុង។

ជាក់ស្តែងនៅប្រទេសកម្ពុជារាជរដ្ឋាភិបាលបានបង្កើតឲ្យមានអង្គភាពជាច្រើន ជាពិសេសស្ថាប័នពាក់ព័ន្ធ ឲ្យមានការសិក្សាស្វែងរកពិធីសាស្ត្រផ្សេងៗ ដែលក្នុងនោះរួមមាន ក្រសួងសាធារណៈការនិងដឹកជញ្ជូន, ក្រសួងមហាផ្ទៃ, អគ្គស្នងការនគរបាលជាតិ, គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងមានក្រសួងស្ថាប័នជាច្រើនទៀតដែលមានវិធានការ ចូលរួម យ៉ាងសំខាន់ក្នុងចរាចរណ៍ផ្លូវគោកនេះ។ សព្វថ្ងៃរាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការរឹងបន្តឹងចរាចរណ៍ផ្លូវគោក ទៅជនណាដែលបានប្រព្រឹត្តល្មើសនិងច្បាប់ចរាចរណ៍ ជាពិសេសនៅពេលយប់ និងពិនិត្យជាតិ អាល់កុល និងឆែកគ្រឿងផ្ទុះអាវុធខុសច្បាប់។ លើសពីនេះទៀតសោត នៅពេលមានបុណ្យជាតិធំៗ ដែលមានប្រជាពលរដ្ឋធ្វើដំណើរច្រើន និងចូលរួមកម្មវិធីច្រើន កម្លាំងនគរបាលមានសមត្ថកិច្ចបានដាក់ ពង្រាយជាច្រើន ក្នុងវិធានការជួយសម្រួលចរាចរណ៍ និងជៀសវាង ករណីគ្រោះថ្នាក់ផ្សេងៗ ថែមទាំងរក្សាសន្តិសុខជូនប្រជាពលរដ្ឋទៀតផង។

ក្រោមការដឹកនាំរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាបានកំពុងឆ្ពោះជំហានទៅមុខ ដោយមានការបង្កើនចំណូរសេដ្ឋកិច្ចជាតិ ពីមួយឆ្នាំទៅមួយឆ្នាំ និងបានពង្រឹង និងប្រើប្រាស់ថវិការក្នុងការបង្កើតឲ្យមានហេដ្ឋារចនាសម្ពន្ធផ្លូវថ្នល់ល្អ ក្នុងការចូលរួមគិតគូរ ដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ ថែមទាំងបានគិតគូរយ៉ាងសំខាន់ទៅលើ បញ្ហាចរាចរណ៍ផ្លូវគោក ដើម្បីស្វែងរកដំណោះស្រាយ និងរៀបចំវិធានការផ្សេងៗ ក្នុងបុព្វហេតុ ដើម្បីប្រទេសជាតិទាំងមូល។

ជាលទ្ធផលដែលរាជរដ្ឋាភិបាលសម្រេចបានជាផ្លែផ្កា ពីមួយឆ្នាំទៅមួយឆ្នាំ កម្ពុជាបានកំពុងដំណើរការនៃការអនុវត្តដោយមាន ប្រសិទ្ធភាពដោយមានការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ដូចមានជាលទ្ធផល **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក** បានទទួលពានរង្វាន់អន្តរជាតិលើកាងារសុវត្ថិភាពចរាចរណ៍ លើកាងារសុវត្ថិភាពចរាចរណ៍ នៃ**ព្រះអង្គម្ចាស់ Michael នៃ ចក្រភពអង់គ្លេស នៅទីក្រុងឡុងនៃចក្រភពអង់គ្លេស។** នៅក្នុងការរឹតបន្តឹងការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក រយៈពេល១១ ខែ ឆ្នាំ២០១៦ បានធ្វើឲ្យអាត្រាគ្រោះថ្នាក់ចរាចរណ៍មាន

ត្រឹម ៣,៣៣៨ ករណី ថយចុះ ៥៥១ ករណី។ **សម្តេចក្រឡាហោម ស ខេង** បានធ្វើការកត់សម្គាល់ឃើញថា ពានរង្វាន់នេះគឺត្រូវបានខិតខំប្រឹងប្រែង រួមពីគ្រប់មជ្ឈដ្ឋាន ក្នុងនោះមានការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ការខិតខំរបស់មន្ត្រីអនុវត្តច្បាប់ និងការចូលរួមរបស់ប្រជាពលរដ្ឋ អង្គការជាតិ ទើបធ្វើឲ្យយើងសម្រេចបាននូវជោគជ័យ ក្នុងការកាត់បន្ថយចំនួនអ្នកស្លាប់ និងអ្នករបួសដោយគ្រោះថ្នាក់ចរាចរណ៍ក្នុងឆ្នាំ២០១៦នេះ។[59]

ក្នុងនាមរាជរដ្ឋាភិបាល និងគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្តេចបានអំពាវនាវដោយផ្ទាល់ដល់អ្នកប្រើប្រាស់ផ្លូវ និងអ្នកធ្វើដំណើរតាមផ្លូវថ្នល់ សូមចូលរួមអនុវត្តឲ្យបាននូវ អនុសាសន៍របស់**សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ថ្ងៃនេះ ថ្ងៃស្អែក កុំឲ្យមានគ្រោះថ្នាក់ចរាចរណ៍ ដោយសូមចូលរួមយកចិត្តទុកដាក់នូវវិធានការដូចខាងក្រោម៖

1. អ្នកបើកបរម៉ូតូ និងអ្នកធ្វើដំណើរទាំងអស់ ត្រូវពាក់មួកសុវត្ថិភាពឲ្យបានត្រឹមត្រូវគ្រប់គ្នាទោះជិតឆ្ងាយ។
2. មុនពេលបើកបរយានជំនិះ ត្រូវត្រួតពិនិត្យបច្ចេកទេសឲ្យបានម៉ត់ចត់ និងលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នជានិច្ច។
3. អ្នកបើកបររថយន្ត និងអ្នករួមដំណើរទាំងអស់ត្រូវពាក់ខ្សែក្រវ៉ាត់សុវត្ថិភាពឲ្យបានត្រឹមត្រូវបានគ្រប់ៗគ្នា
4. អ្នកបើកបរម៉ូតូ និងអ្នករួមដំណើរទាំងអស់ ត្រូវពាក់មួកសុវត្ថិភាពឲ្យបានល្អ មិនថាជិតឬឆ្ងាយ
5. សូមបន្ថយល្បឿនបើកបរទៅតាមស្ថានភាពផ្លូវ និងស្ថានភាពចរាចរណ៍ ដូចជាផ្លូវកោងជាដើម
6. មុននឹងវ៉ាជែងត្រូវដឹងច្បាស់ថាផ្លូវខាងមុខទំនេរអាចវ៉ាជែងដោយសុវត្ថិភាពកុំប្រថុយ ប្រថាន
7. ពេលបើកបរត្រូវប្រកាន់ស្តាំជានិច្ច និងគោរពសិទ្ធិអាទិភាព គឺត្រូវបន្ថយល្បឿន
8. បើពិសារគ្រឿងស្រវឹង កុំបើកបរ បើបើកបរ កុំពិសារគ្រឿងស្រវឹង ព្រោះបើស្រវឹងអ្នកបើកបរនឹងបាត់ភាពជាម្ចាស់ការណ៍លើខ្លួនឯង
9. ចំពោះរថយន្តដឹកអ្នកដំណើរ ឬដឹកទំនិញមិនត្រូវផ្ទុកមនុស្ស ឬទំនិញលើស ច្បាប់ កំណត់

[59] គេហទំព័ររបស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន, កម្ពុជាទទួលបានពានរង្វាន់លើកាងារសុវត្ថិភាពចរាចរណ៍, ថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០១៦, អាចរកបានhttps://www.mpwt.gov.kh/awardrsf.html

10. ក្នុងករណីមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង ស្នើប្រជាពលរដ្ឋគ្រប់រូបមេត្តាអត់ធ្មត់ ខន្តី អាធ្យាស្រ័យ ជៀសវាងការប្រើប្រាស់អំពើហិង្សា ត្រូវចូលរួមដោះស្រាយតាម នីតិវិធីច្បាប់។[60]

លើសពីនេះទៅទៀត ក្រសួងព័ត៌មានគ្រោងនឹងបើកសិក្ខាសាលាបណ្ដុះបណ្ដាលពីច្បាប់ចរាចរណ៍ថ្មីដល់អ្នកបើកបររថយន្តរបស់ថ្នាក់ដឹកនាំ ដូចមានក្នុងប្រសាសន៍របស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន នៅទីស្ដីការក្រសួងព័ត៌មាន បានឲ្យដឹងថា ក្រសួងគ្រោងនឹងអញ្ជើញអ្នកបើកបររថយន្តរបស់ថ្នាក់ដឹង មកបង្រៀនពីច្បាប់ចរាចរណ៍ផ្លូវគោក ព្រោះថាមានអ្នកបើកបរមួយចំនួន អត់ចេះច្បាប់ចរាចរណ៍ទេពិសេសច្បាប់ចរាចរណ៍ផ្លូវគោកថ្មីដែលកំពុងដាក់ឲ្យ ដំណើរការអនុវត្តនាពេលថ្មីៗនេះ។[61]

## ៣.១.៤ ការចូលរួមពីសង្គមស៊ីវិល

នៅក្នុងប្រទេសនីមួយៗនៅក្នុងពិភពលោកគឺមិនអាចខ្វះបានឡើយនៅការចូលរួមពី សង្គមស៊ីវិល ឬអង្គការ ទាំងក្នុងជួររាជរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ដើម្បីចូលរួមក្នុងការអភិវឌ្ឍប្រទេសជាតិ។ ពិតណាស់នៅក្នុងប្រទេសកម្ពុជាមានក្រុមកាងារ អង្គការសង្គមស៊ីវិលបានចូលរួមយ៉ាងសកម្មភាព ក្នុងគោលបំណងចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាផ្សេងៗទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន។

បច្ចុប្បន្នស្ថានភាពចរាចរណ៍ផ្លូវគោកនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅមានស្ថានភាពមួយមិនទាន់ អាចកាន់បន្ថយបានច្រើនខ្លាំងណាស់ណាទេ តែកម្ពុជាបានគិតគូរ និងខិតខំយ៉ាងសកម្មពីការចូលរួម របស់រាជរដ្ឋាភិបាល ប្រជាពលរដ្ឋ អង្គការ សមាគមន ផ្សេងៗបានចូលរួមចំណែកធ្វើឲ្យប្រទេសមានភាពកាន់តែល្អប្រសើរ។ ជាក់ស្ដែងយើងសង្កេតឃើញថាមានអង្គការសង្គមស៊ីវិលជាច្រើនដែលជាដៃគូរ ជាមួយរាជរដ្ឋាភិបាលកម្ពុជា បានចូលរួមចំណែកកាត់បន្ថយនូវអាត្រាគ្រោះថ្នាក់ចរាចរណ៍ និងបានចូលរួមផ្សព្វផ្សាយអំពីចរាចរណ៍ផ្លូវគោក គ្រប់ទីមជ្ឈដ្ឋាន យ៉ាងសកម្ម។ ដូចមាន ជាអាទ៍ សហភាពសហព័ន្ធយុវជនកម្ពុជា ដែលជាអង្គការមិនមែនរដ្ឋាភិបាល ដែលមាននៅតាមបណ្ដារាជធានី ខេត្ត ក្រុង បានចូលរួមយ៉ាងសកម្មក្នុងការធ្វើកិច្ចសហប្រតិបត្តិការណ៍ចូលរួមជាមួយ រាជរដ្ឋាភិបាល ទៅលើចរាចរណ៍ផ្លូវគោក ក្នុងការផ្សព្វផ្សាយពីវិធីសាស្ត្រការពារ បញ្ហាផ្សេងៗដែលកើតឡើងលើដងផ្លូវ គុណវិបត្តិនៃគ្រោះថ្នាក់ចរាចរណ៍ ផ្សព្វផ្សាយទិន្នភាពច្បាប់ ព្រម

---

[60] ដកស្រង់ចេញពីគេហទំព័រក្រសួងមហាផ្ទៃ ក្នុងពិធីទិវាសប្ដាហ៍ជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកលើកទី១១, ថ្ងៃទី ០៦, ខែមេសា ឆ្នាំ២០១៨, អាចរកបាន, https://www.interior.gov.kh/news/detail/410

[61] ដកស្រង់ចេញពីគេហទំព័រ ទីភ្នាក់ងារអ្នកសារព័ត៌មានកម្ពុជា, ក្រសួងព័ត៌មានគ្រោងនឹងបើកសិក្ខាសិលាបណ្ដុះបណ្ដាលពីច្បាប់ ចរាចរណ៍ថ្មីដល់អ្នកបើកបររថយន្តរបស់ថ្នាក់ដឹកនាំ, ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១៦, អាចរកបាន, https://www.akp.gov.kh/archives/138400

ទាំងចុះផ្ទាល់នៅតាមបណ្តាខេត្តក្រុង ចុះចែងជូននូវមួកសុវត្ថិភាព និងខិតប័ណ្ណផ្សេងៗអំពីសុវត្ថិភាពចរាចរណ៍ផ្លូវ គោក។ ជាពិសេសនៅក្នុងពិធីបុណ្យទានជាតិធំៗដែលមានចំនួនប្រជាពលរដ្ឋច្រើន បានសង្កេតឃើញថាមានក្រុមសង្គមស៊ីវិលជាច្រើនបានចុះសកម្មភាពផ្ទាល់ដល់ការផ្សព្វផ្សាយពីចរាចរណ៍ ផ្លូវគោក និងចុះចែកជូនមួកសុវត្ថិភាពជាដើម។ល។ ថ្មីៗនេះក្នុងពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ក្រសួងសាធារណការ និងដឹកជញ្ជូន សហភាពសហព័ន្ធយុវជនកម្ពុជាវិស័យសាធារណការ និងដឹកជញ្ជូន និងយុវជនមកពីមូលនិធិបង្ការរបួសអាស៊ី AIP Foundation បានចុះធ្វើយុទ្ធនាការសុវត្ថិភាពចរាចរណ៍ផ្លូវគោកពញ្ញាក់ស្មារតីដល់អ្នកប្រើប្រាស់ផ្លូវ ឲ្យមានការប្រុងប្រយ័ត្ន នៅក្នុងឱកាសពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ ឆ្នាំ២០១៨ នៅតាមទីតាំងផ្លូវជាតិ ចំនួន ៣ គឺផ្លូវជាតិលេខ១ ផ្លូវជាតិលេខ៥ និងផ្លូវជាតិលេខ៦។[62]

មិនត្រឹមតែប៉ុណ្ណោះទៀតសោត កាកបាទក្រហមដែលជាអង្គការមិនមែនរដ្ឋាភិបាលមួយដែលមានសាខាជាច្រើននៅលើសាកលលោក ក្នុងនោះព្រះរាជាណាចក្រកម្ពុជា ដែលមាន **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ជាប្រធានកាកបាទក្រហមកម្ពុជា។ ជាក់ស្តែងនៅក្នុងសង្គមខ្មែរបច្ចុប្បន្ន យើងសង្កេតឃើញមានសកម្មភាពយ៉ាងសកម្មពីក្រុមកាងារ កាកបាទក្រហមកម្ពុជា ដែលមាននៅតាមរាជធានី ខេត្ត ក្រុង ជុំវិញប្រទេសកម្ពុជា បានចូលរួមក្នុងការងារមនុស្សធម៌ ជាពិសេសក្នុងការចូលរួមទៅលើចរាចរណ៍ផងដែល។ នៅក្នុងសកម្មភាពចូលរួមរបស់កាកបាទកម្ពុជា គឺមានជាច្រើនសកម្មភាពដូចជា ការផ្សព្វផ្សាយពីចរាចរណ៍ផ្លូវគោក វេទិកាជជែកពិភាក្សាទៅលើចរាចរណ៍ ការចុះអនុវត្តលើដងផ្លូវ និងមានជាច្រើនទៀត។ល។ នៅថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៧ កាកបាទក្រហមកម្ពុជា និងអង្គការសម្ព័ន្ធអន្តរជាតិ ទប់ស្កាត់ផលប៉ះពាល់នៃគ្រឿងស្រវឹងបាន សហការចុះជួយអប់រំ បណ្តុះបណ្តាលចរាចរណ៍ផ្លូវគោក ជូនសិស្សនៅតាមវិទ្យាល័យ អនុវិទ្យាល័យ ដើម្បីឲ្យសិស្សានុសិស្សបានយល់ដឹងពីការបើកបរ ដោយសុវត្ថិភាព ដើម្បីបញ្ចៀសការគ្រោះថ្នាក់កើតឡើងដោយយថាហេតុ។[63]អង្គការសង្គមស៊ីវិលទាំងអស់នេះហើយ ដែលបានចូលរួមជួយទប់ស្កាត់ និងផ្សព្វផ្សាយពីផលប៉ះពាល់ និងបង្ការពីគ្រោះថ្នាក់ចរាចរណ៍ ទៅកាន់ប្រជាពលរដ្ឋកម្ពុជា។ ការចូលរួមពីសំណាក់សង្គមស៊ីវិល ពិតជាបានចូលរួមចំណែកយ៉ាងសំខាន់ផងដែរក្នុងដំណើរការកាត់បន្ថយនៃអាត្រាគ្រោះថ្នាក់ក្នុងសង្គម ព្រមទាំងការរៀបចំឲ្យមាននូវច្បាប់ទប់

---

[62] ដកស្រង់ចេញពីគេហទំព័រគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក, យុទ្ធនាការអប់រំផ្សព្វផ្សាយស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក មុនឱកាសពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ឆ្នាំ២០១៨, អាចរកបាន http://www.nrsc.gov.kh/?page=detail&ctype=article&id=1425&lg=kh

[63] ដកស្រង់គេហទំព័រទីភ្នាក់ងារសារព័ត៌មានកម្ពុជា, កាកបាទក្រហមកម្ពុជាជួយបណ្តុះបណ្តាលច្បាប់ចរាចរណ៍ដល់សិស្សវិទ្យាល័យជម្ពូវ័ន, ភ្នំពេញថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧, អាចរកបានhttp://www.akp.gov.kh/kh/archives/183562

ស្តាត់ និងត្រួតពិនិត្យលើលើបច្ចេកទេស និងឧត្តម្ភគ្រាំទ្រ ក្នុងគោលដៅកាត់បន្ថយ និងបង្កាទប់ស្កាត់ហានិភ័យ និងការពារសុខុមាលភាពជូនប្រជាពលរដ្ឋ។

### ៣.១.៥ ប្រជាជន

គ្រោះថ្នាក់ចរាចរណ៍គឺត្រូវបានកើតឡើង ផ្តើមចេញពីប្រជាពលរដ្ឋម្នាក់ៗដែលបានធ្វើដំណើរលើដងផ្លូវ ហើយកត្តាដែលរួមចំណែកក្នុងការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ក៏ត្រូវបានផ្តើមចេញពីប្រជាពលរដ្ឋផងដែល។ ក្នុងនាមជាប្រជាពលរដ្ឋគ្រប់ ត្រូវតែមានសណ្តានចិត្តចេះអាធ្យាស្រ័យគ្នាទៅវិញទៅមក ជាពិសេសនៅពេលបើកបរ នៅលើដងផ្លូវ។ ការចេះអធ្យាស្រ័យគ្នាជាកត្តាមួយដ៏សំខាន់ក្នុងការចូលរួមកាត់បន្ថយបញ្ហាគ្រោះថ្នាក់ផ្សេងៗ ក្នុងន័យនេះចង់មានបង្ហាញថា នៅពេលបើកបរ បុគ្គលគ្រប់រូបត្រូវចេះអត់ឱនគ្នាទៅវិញទៅមក មិនត្រូវតែជម្នះ ក្នុងការដែងគ្នាដោយល្បឿនជាពិសេសនៅពេលមានការប៉ះពារគ្នាបន្តិចបន្តួចគួរណាស់តែ មានការអត់ឱនគ្នាជៀសវាងជំលោះកើតឡើងវាយតប ដែលជាអំពើខុសច្បាប់ អាចឈានទៅលើការទទួលទោសព្រហ្មទណ្ឌ។ល។ ពិតណាស់ទៅលើ សីលធម៌នេះផងដែល គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក បានផ្តល់១០ចំណុចអំពីសីលធម៌១០ចំណុចសម្រាប់សុវត្ថិភាពចរាចរណ៍ផ្លូវគោក ក្នុងនោះរួមមាន៖

**ពេលបើកបរមិនត្រូវ៖**

- មិនត្រូវបើកបរលើសល្បឿនកំណត់
- មិនត្រូវបើកបរស្ថិតក្រោមឥទ្ធិពលគ្រឿងស្រវឹងដាច់ខាត
- មិនត្រូវបើកបរស្ថិតក្នុងក្រោមឥទ្ធិពលនៃគ្រឿងញៀនដាច់ខាត
- មិនត្រូវបើកបរស្ថិតក្រោមស្ថានភាពងងុយដេកដាច់ខាត

**ពេលបើកបរត្រូវ៖**

- ត្រូវពាក់មួកសុវត្ថិភាព
- ត្រូវពាក់ខ្សែក្រវ៉ាត់សុវត្ថិភាពជានិច្ច
- ត្រូវប្រកាន់ស្តាំជានិច្ច
- ត្រូវត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តជានិច្ច
- ត្រូវចេះបើកបរឲ្យបានត្រឹមត្រូវជាដាច់ខាត
- ត្រូវប្រុងប្រយ័ត្នជានិច្ច។[64]

[64] ដកស្រង់ចេញពី, សីលធម៌ទាំង១០សម្រាប់សុវត្ថិភាពចរាចរណ៍, គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក, អាចរកបានhttp://www.nrsc.gov.kh/?page=detail&ctype=article&id=1371&paginate=3&lg=kh

លើសពីនេះទៀតសោតប្រជាពលរដ្ឋគ្រប់រូបត្រូវតែព្យាយាមយល់ដឹងពីទិដ្ឋភាព ច្បាប់ចរាចរណ៍ផ្លូវគោកដើម្បីយល់ដឹងពីកាតព្វកិច្ច និងការការពារសិទ្ធផ្ទាល់ខ្លួនជៀសវាងការប្រព្រឹត្តសកម្មភាពណាមួយដែលផ្ទុយពីច្បាប់។ មិនត្រឹមតែប៉ុណ្ណោះប្រជាពលរដ្ឋគ្រប់រូបត្រូវចូលរួមឲ្យបានច្រើននូវសកម្មភាពផ្សេងៗដូចជា៖

• តាមដានព័ត៌មាន ឬកម្មវិធីអប់រំផ្សព្វផ្សាយពីចរាចរណ៍ផ្លូវគោក ដែលទាក់ទង និងកត្តានាំឲ្យគ្រោះថ្នាក់ វិធីសាស្ត្រការពារ និងការផ្សព្វផ្សាយផ្សេងៗដែលមានសារប្រយោជន៍។

• ចូលរួមសិក្ខាសិលា ព្រមទាំងកម្មវិធីមួយចំនួនផ្សេងៗដែលទាក់ទង និងចរាចរណ៍ផ្លូវគោកនៅតាមសហគមន៍ខ្លួនដើម្បីយល់ពីអត្ថប្រយោជន៍។

• តាមដាន និងយល់ដឹងពីច្បាប់ គោលនយោបាយ សរាចរ ផ្សេងៗដែលទាក់ទង និងចរាចរណ៍ផ្លូវគោក។

• ផ្សព្វផ្សាយណែនាំទៅកាន់អ្នកដទៃ និងធ្វើជាគំរូល្អ ដល់ក្រុមគ្រួសារ អ្នកជិតខាងមិត្តភក្តិ។

• ណែនាំ និងផ្សព្វផ្សាយបន្តទៅមនុស្សជុំវិញខ្លួនដែលកំពុងប្រព្រឹត្តខុស និងមិនទាន់យល់ដឹងច្បាស់ពីច្បាប់ ឬគុណវិបត្តផ្សេងៗ។

• ចូលរួមគាំទ្រឲ្យបានច្រើនទៅលើសកម្មភាព ណាមួយដែលជាប្រយោជន៍ដល់សង្គមជាតិទៅលើការផ្សព្វផ្សាយអប់រំផ្សេងៗពីចរាចរណ៍ផ្លូវគោក។

មិនត្រឹមតែប៉ុណ្ណោះប្រជាពលរដ្ឋផ្ទាល់ខ្លួនបានចូលរួម និងបានបេជ្ញាចិត្តចូលរួមយ៉ាងសកម្ម និងគោរពច្បាប់ចរាចរណ៍ផ្លូវគោក ដូចមានប្រជាពលរដ្ឋនៅឯខាងខេត្តព្រះវិហារបានបេជ្ញាចូលរួមគោរពច្បាប់ចរាចរណ៍គ្រប់គ្នាៗ ក្រោយពីទទួលបានមួកសុវត្ថិភាព ច្បាប់ចរាចរណ៍ និងឯកសារពាក់ព័ន្ធ ផ្សេងៗទាក់ទង និងចរាចរណ៍។[65]

ប្រសិនបើប្រជាពលរដ្ឋកម្ពុជាគ្រប់រូបពិតជា អាចអនុវត្តតាមចំណុចដូចដែលបានរៀបរាប់ខាងលើនេះបាន នោះសង្គមខ្មែរទាំងមូលពិតជាអាចកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍បានមួយភាគធំ និងធ្វើឲ្យមានសណ្តាប់ធ្នាប់ល្អក្នុងការបើកបរផងដែល។ សង្គមខ្មែរទាំងមូល និងមានភាពរីកចម្រើនថែមទាំងធ្វើឲ្យប្រទេសទទួលបានការកោតសរសើរទៀតផង។

អ្វីដែលពិសេសបំផុត ដែលប្រជាពលរដ្ឋគ្រប់រូបត្រូវតែយកគំរូពីកាតព្វកិច្ចក្នុងការទទួលខុសត្រូវ ដូចមានជាក់ស្តែង នៅក្នុងប្រសាសន៍របស់ **ឧត្តមសេនីយ៍ឯក រុន រ័ត្នវាសនា** ប្រធាន

---

[65] ដកស្រង់ពីគេហទំព័រ CEN, ពលរដ្ឋប្តេជ្ញាចូលរួមគោរពច្បាប់ចរាចរណ៍គ្រប់ៗគ្នា ក្រោយពីទទួលបានមួកសុវត្ថិភាព និងឯកសារពាក់ព័ន្ធនិងច្បាប់ចរាចរណ៍,ថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០១៧, អាចរកបាន http://www.cen.com.kh/archives/4273.html

នាយកដ្ឋាននគរបាលចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ គឺថា ថ្ងៃនេះគឺជាថ្ងៃព្រឹត្តិការណ៍ប្រវត្តិមួយរបស់ កម្ពុជា ដែល **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា** បានទៅបង់ប្រាក់ផាកពិន័យចំពោះការល្មើសច្បាប់ចរាចរណ៍ ករណីបើកបរម៉ូតូមិនពាក់មួកសុវត្ថិភាព នៅស្រុកស្រែអំបិល ខេត្តកោះកុង នាពេលកន្លងទៅថ្មីៗនេះ។ ឧត្តមសេនីយ៍ឯក បានថ្លែងយ៉ាងដូច្នេះថា “ នេះជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសម្រាប់កម្ពុជា គឺជាប្រទេសនិតិរដ្ឋ ដែលសម្តេចជាតំណាងរាស្ត្រ មានអភ័យឯកសិទ្ធិសភា និងជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទទួលខុសត្រូវចំពោះអ្វី ដែលសម្តេចបានធ្វើខុស ក្នុងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ពោលគឺ នគរបាលចរាចរណ៍ បានអនុវត្តច្បាប់យ៉ាងម៉ឺងម៉ាត់ដោយបានពិន័យសម្តេច ក្នុងករណីមិនពាក់មួកសុវត្ថិភាពដែលល្មើសនឹងមាត្រា៨ ចំណុចទី៨ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។នេះជាទង្វើដែលប្រជាពលរដ្ឋគ្រប់រូប និងថ្នាក់ដឹកនាំដទៃទៀត គួរយកគំរូតាមសម្តេច ព្រោះគ្មាននរណាម្នាក់ នៅពីលើច្បាប់បានទេ ហើយក៏គ្មានមាត្រាណាមួយ ចែងឲ្យលើកលែងពីការពិន័យ ឡើយ។ ”[66]

## ៣.២ អនុវត្តន្តវសកម្មភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោក

### ៣.២.១ ការជួញសង្គ្រោះជនរងគ្រោះ

ក្នុងមួយឆ្នាំៗចំនួនគ្រោះថ្នាក់ចរាចរណ៍បានធ្វើឲ្យមនុស្សបាត់បង់ជីវិត អាយុជីវិត និងរងរបួសមិនតិចនោះទេ។ អ្វីដែលគេចាប់អារម្មណ៍នោះនៅពេលដែលមានគ្រោះថ្នាក់ចរាចរណ៍ ជនរងគ្រោះមួយចំនួនមិនត្រូវបាន ជួយដឹកបញ្ជូនទៅកាន់មន្ទីរពេទ្យភ្លាមៗនោះទេ ស្របពេលដែលកំពុងមានមនុស្សឈរមើលយ៉ាងព្រោងព្រៀត។ នៅក្នុងការជួយសង្គ្រោះមានមតិជាច្រើនបានលើកឡើងពីទិដ្ឋភាពមួយនេះ ជាក់ស្តែង មានការយល់ឃើញមតិមួយចំនួនបានលើកឡើងថា គ្រប់គ្រោះថ្នាក់ចរាចរណ៍ទាំងអស់គួរតែជួយទៅតាមលទ្ធភាពដែលអាចជួយទៅបាន ដោយមិនចាំបាច់គិតថាខ្លួនចេះឬមិនចេះពីវិធីសាស្ត្រ នៃការជួយសង្គ្រោះនោះទេ។ រីឯមតិមួយទៀតបានលើកឡើងថា ក្នុងការជួយ សង្គ្រោះទៅលើអ្នកដែលគ្រោះថ្នាក់ ចរាចរណ៍គឺតែមានគ្នាពីរទៅបីនាក់ ទើបអាចជួយបាន។ ចំពោះការឆ្លើយតបទៅនឹងមតិខាងលើ លោក នាក់ សារឿន អនុប្រធានមន្ទីរពេទ្យបង្អែកខេត្តកំពតបានមានប្រសាសន៍ថា ការជួយសង្គ្រោះគឺមានបែងចែកជាពីរ បើគ្រោះថ្នាក់ដែលមានអ្នករងរបួសមិនធ្ងន់ធ្ងរ គឺយុវវ័យ អាចជួយទៅតាមលទ្ធភាពដែលអាចជួយទៅបាន ប៉ុន្តែបើគ្រោះថ្នាក់ដែលធ្ងន់ធ្ងរគឺមានតែអ្នកជំនាញទើបអាចជួយបាន។

---

[66] ដកស្រង់ពីគេហទំព័រ Freshnews, ឧត្តមសេនីយ៍ឯក រុន រ័ត្នវេសនា៖ ការបង់ប្រាក់ពិន័យចរាចរណ៍របស់សម្តេចតេជោ ហ៊ុន សែន ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ និងគំរូដ៏ល្អសម្រាប់ប្រជាពលរដ្ឋ និងថ្នាក់ដឹកនាំដទៃទៀត, អាចរកបាន m.freshnewasia.com/index.php/en/localnews

យ៉ាងណាមិញនៅពេលដែលឃើញមានគ្រោះថ្នាក់ចរាចរណ៍ យើងទាំងអស់គ្នាគួរជួយជនរងគ្រោះចេញពីកន្លែងដែលធ្វើឲ្យប៉ះពាល់ដល់អាយុជីវិតរបស់គាត់ ហើយត្រូវដឹកជញ្ជូនទៅកាន់មន្ទីរពេទ្យភ្លាមៗ ឬត្រូវទំនាក់ទំនងទៅកាន់ក្រុមអ្នកជួយសង្គ្រោះ ឬអាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតកន្លែងកើតហេតុបំផុត។ ជាក់ស្តែងនៅតាមក្នុងរបាយការស្តីជនរងគ្រោះនៃគ្រោះថ្នាក់ចរាចរណ៍ការសង្គ្រោះបឋមគឺជារឿងសំខាន់ក្នុងការជួយសង្គ្រោះជីវិតជនរងគ្រោះ។ ប៉ុន្តែមានត្រឹមតែ៥៦% នៃជនរងគ្រោះទទួលបានការសង្គ្រោះបឋម។ ការសង្គ្រោះបឋមមានការថយចុះ ១៦% បើធៀបនឹងឆ្នាំ២០១៥។ ក្នុងការសង្គ្រោះបឋមទាំងនេះ នគរបាលចរាចរណ៍អនុវត្តបាន ៥២% និងរថយន្តគិលានសង្គ្រោះ ២០%។ ជនរងគ្រោះដែលបានទទួលជួយសង្គ្រោះបឋម ត្រូវបានជួយសង្គ្រោះផ្នែកការហូរឈាមមាន ៥១% បន្ទាប់មកការបំលាស់ទីជនរងគ្រោះ ១៩% របួស ១៥%។[67]

### ៣.២.២ ការប្រើប្រាស់វិធានការការពារ

នៅក្នុងការបើកបរនៅលើចរាចរណ៍ផ្លូវគោកសព្វថ្ងៃប្រជាពលរដ្ឋគ្រប់រូបគួរយល់ដឹង និងគួរដឹងច្បាស់ពីវិធីការពារ ចងចាំចំពោះការប្រើប្រាស់ផ្លូវ។ នៅក្នុងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក

**អ្នកជិះកង់ និងថ្មើរជើង**

- អ្នកជិះកង់ ត្រូវជិះអែបកៀកខាងស្តាំបំផុត និងត្រូវធ្វើការបត់ឆ្វេង ដោយប្រុងប្រយ័ត្ន ឬបើចាំបាច់ត្រូវចុះបណ្តើរកង់ដូចថ្មើរជើងដែរ (បើពាក់មួកសុវត្ថិភាពរឹតតែជាការប្រសើរ)
- ថ្មើរជើង ត្រូវដើរលើចិញ្ចើម ឬជាយផ្លូវ។ បើពុំមានចិញ្ចើម ឬជាយផ្លូវត្រូវដើរអែបកៀកខាងស្តាំបំផុត និងត្រូវឆ្លងកាត់នៅលើគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់ បើពុំមានគំនូសសញ្ញាទេ ត្រូវឆ្លងកាត់តាមកែងទទឹងថ្នល់ដោយប្រុងប្រយ័ត្ន។

**អ្នកជិះម៉ូតូ,ម៉ូតូកង់បី, ម៉ូតូសណ្តោងរ៉ឺម៉ក**

**អ្នកបើកបរម៉ូតូត្រូវមានៈ**

- អ្នកបើកបរម៉ូតូ ដែលមានទំហំស៊ីឡាំងមិនលើសពី១២៥សេសេ ត្រូវមានអាយុចាប់ពី ១៥ឆ្នាំឡើង និងត្រូវយកភ្ជាប់តាមខ្លួននូវអត្តសញ្ញាណបណ្ណសម្គាល់ខ្លួន ឬ លិខិតបញ្ជាក់អត្តសញ្ញាណដែលមានតំលៃស្មើ
- អ្នកបើកបរម៉ូតូ ដែលមានទំហំស៊ីឡាំងចាប់ពី ១២៦សេសេឡើងទៅត្រូវយកភ្ជាប់តាមខ្លួននូវបណ្ណបើកបរប្រភេទ **ក**
- អ្នកបើកបរម៉ូតូលកង់បី និងម៉ូតូសណ្តោងរ៉ឺម៉ក ត្រូវយកភ្ជាប់តាមខ្លួននូវបណ្ណបើកបរប្រភេទ **ក**

[67] ដកស្រង់ចេញពី របាយការណ៍ស្តីពីជនរងគ្រោះ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៦, ការជួយសង្គ្រោះបឋម

**ម៉ូតូត្រូវមាន៖**

- បណ្ណសម្គាល់ម៉ូតូត្រូវភ្ជាប់តាមខ្លួន និងពាក់ស្លាកលេខត្រឹមត្រូវ
- មានកញ្ចក់មើលក្រោយ កង់ល្អ ហ្វ្រាំងស៊ី ភ្លើង និងកញ្ចក់ចាំងពន្លឺត្រូវដំណើរការច្បាស់ល្អ

**ពេលបើកបរ៖**

- ត្រូវពាក់មួកសុវត្ថិភាពទាំងអ្នកបើកបរ និងអ្នករួមដំណើរព្រមទាំងកុមារដែលមានអាយុពី៣ឆ្នាំឡើង
- ពេលចេញដំណើរត្រូវមើលឆ្វេងស្តាំ និងត្រូវប្រកាន់ស្តាំជានិច្ច
- គោរពសញ្ញាចរាចរណ៍ (គំនូស ស្លាក ភ្លើង និងសញ្ញាបញ្ជារបស់ ភ្នាក់ងារទេសចរណ៍)
- ល្បឿនអតិបរមា ក្នុងទីប្រជុំជន៣០ គ.ម/ម៉
- ល្បឿនអតិបរមាក្រៅទីប្រជុំជន៤០គ.ម/ម៉ សម្រាប់ម៉ូតូកង់៣ និងម៉ូតូសណ្តោងរ៉ឺម៉ក ៦០គ.ម/ម៉សម្រាប់ ម៉ូតូត្រឹម១២៥សេសេ និង៧០គ.ម/ម៉ សម្រាប់ម៉ូតូលើស១២៥សេសេ
- បើកបរមិនស្ថិតក្រោមឥទ្ធិពលគ្រឿងស្រវឹង ឬគ្រឿងញៀន
- ត្រូវបន្ថយល្បឿន និងគោរពសិទ្ធិអាទិភាពនៅផ្លូវប្រសព្វ
- មុនពេលបត់ឆ្វេង ឬស្តាំត្រូវមើលកញ្ចក់មើលក្រោយ មើលទិសឆ្វេង ស្តាំពីមុខ និងឲ្យ ភ្លើងសញ្ញាប្តូរទិស ឬលើកដៃជាសញ្ញាក្នុងចម្ងាយយ៉ាងតិច ២០ម៉ែត
- កុំជែង (វ៉ា) ក្នុងស្ថានភាពគ្រោះថ្នាក់ និងត្រូវផ្តល់ភ្លើងសញ្ញា ឬស៊ីផ្លេដល់យានយន្តខាងមុខបានដឹង
- ហាមផ្ទុកមនុស្ស ឬទំនិញលើសចំណុះ សំពីងសំពោង និងហាមប្រើទូរស័ព្ទដោយគ្មានឧបករណ៍ភ្ជាប់សំឡេង
- ត្រូវមានស្មារតីប្រុងប្រយ័ត្ន ចេះយោគយល់អធ្យាស្រ័យ

**អ្នកជិះរថយន្ត**

**អ្នកបើកបររថយន្តត្រូវ៖**

- យកជាប់តាមខ្លួននូវបណ្ណបើកបរត្រឹមត្រូវតាមប្រភេទយានយន្ត

**រថយន្ត ត្រូវ៖**

- មានបណ្ណសម្គាល់រថយន្ត និងពាក់ផ្លាកលេខត្រឹមត្រូវ
- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណ:បច្ចេកទេស

- លិខិតអនុញ្ញាតផ្ទុំអាជីវកម្មរថយន្ត
- មានកញ្ចក់មើលក្រោយ មានកង់ល្អ ហ្វ្រាំងស៊ី ចង្កូត ផ្លិតទឹកជូតកញ្ចក់មុខ-ក្រោយ និងកញ្ចក់ចាំងពន្លឺត្រូវដំណើរការច្បាស់-ល្អ

**ពេលបើកបរៈ**

- ត្រូវពាក់ខ្សែក្រវាត់សុវត្ថិភាព ប្រុងប្រយ័ត្ន និងប្រកាន់ស្តាំជានិច្ច
- គោរពសញ្ញាចរាចរណ៍ (គំនូសសញ្ញា ស្លាកសញ្ញា ភ្លើងសញ្ញា និងសញ្ញាបញ្ជារបស់ភ្នាក់ងារចរាចរណ៍)
- ល្បឿនអតិបរមា ក្នុងទីប្រជុំជន៤០គ.ម/ម៉
- ល្បឿនអតិបរមា ក្រៅទីប្រជុំជន៦០គ.ម/ម៉ សម្រាប់រថយន្តសណ្តោងរ៉ឺម៉ក, ៧០គ.ម/ម៉ សម្រាប់រថយន្តដឹកទំនិញ ធុនធ្ងន់, ៨០គ.ម/ម៉ សម្រាប់រថយន្តគ្រួសារ និងរថយន្តដឹកសម្រាប់ផ្លូវដែលមានគន្លងផ្លូវចាប់ពី៤ឡើង និងមានខឿនបែងចែកទ្រូងផ្លូវ
- បើកបរមិនស្ថិតក្រោមឥទ្ធិពលគ្រឿងស្រវឹង ឬគ្រឿងញៀន
- ត្រូវបន្ថយល្បឿន និងគោរពសិទ្ធអទិភាពនៅផ្លូវប្រសព្វ
- មុនពេលបត់ឆ្វេង ឬស្តាំត្រូវមើលកញ្ចក់មើលក្រោយ មើលទិសឆ្វេង ស្តាំពីមុខ និងឲ្យ ភ្លើងសញ្ញាប្តូរទិស ឬលើកដៃជាសញ្ញាក្នុងចម្ងាយយ៉ាងតិច២០ម៉ែត្រ
- កុំជែង(វ៉ា) ក្នុងស្ថានភាពគ្រោះថ្នាក់ និងត្រូវផ្តល់ភ្លើងសញ្ញា ឬស៊ីផ្លេដល់យានយន្តខាងមុខបានដឹង
- មុនពេលឈប់ត្រូវផ្តល់ភ្លើងសញ្ញាប្តូរទិសដៅក្នុងចម្ងាយយ៉ាងតិច២០ម៉ែត្រ ឬលើកដៃផ្តល់សញ្ញាជាមុន មិនឈប់កន្លែងហាមឃាត់ ឬកន្លែងមានការកកស្ទះ
- មិនចតនៅកន្លែងហាមឃាត់ នៅលើទ្រូងផ្លូវចង្អៀត និងត្រូវប្រើភ្លើងសញ្ញាអាសន្នជាដំណឹងក្នុងករណីមិនអាចបើកបរចេញពីទ្រូងផ្លូវបាន
- ហាមផ្ទុកមនុស្សឬទំនិញលើសចំណុះ សំពីងសំពោង និងហាមប្រើទូរស័ព្ទដោយគ្មានឧបករណ៍ភ្ជាប់សម្លេង
- ត្រូវមានស្មារតីប្រុងប្រយ័ត្ន ចេះយោគយល់អធ្យាស្រ័យ

**សញ្ញាចរាចរណ៍**

**ភ្លើងសញ្ញាចរាចរណ៍**

- ភ្លើងពណ៌ក្រហម គឺជាសញ្ញាឃាត់ឲ្យឈប់ អ្នកបើកបរម៉ូតូឬអ្នកបើកបរម៉ូតូកង់បី ឬអ្នកបើកបរម៉ូតូសណ្តោង រ៉ឺម៉កឬរថយន្តត្រូវឈប់នៅមុខខ្សែបន្ទាត់គំនូសជាប់ពណ៌សកាត់ទទឹងទ្រូងផ្លូវឬមុខគំនូសសម្រាប់ថ្មើរជើងឆ្លងកាត់
- ភ្លើងពណ៌លឿង គឺជាសញ្ញាឲ្យប្រុងប្រយ័ត្ន ត្រៀមឈប់
- ពន្លឺពណ៌បៃតង ជាសញ្ញាអនុញ្ញាតឲ្យយានជំនិះចេញដំណើរ។

## ៣.៣ ទិសដៅអនាគត

ដូចដែលបានឃើញហើយនៅពេលធ្វើចរាចរណ៍សព្វថ្ងៃ និងមានលឺព័ត៌មានអំពីគ្រោះថ្នាក់ចរាចរណ៍ដែលកើតឡើងជារៀងរាល់ថ្ងៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា វាជាបញ្ហាមួយដែលសង្គមទាំងមូល មានការព្រួញបារម្ភទៅស្ថានភាពនេះ។ នៅក្នុងទិសដៅសម្រាប់ថ្ងៃអនាគត ដែលចង់ឃើញព្រះរាជាណាចក្រកម្ពុជា មានការកាត់បន្ថយនៃអាត្រាគ្រោះថ្នាក់ចរាចរណ៍ និងមានសណ្តាប់ធ្នាប់ល្អទៅលើការបើកបរ លើដងផ្លូវ។ ក្នុងនាមជាអ្នកសិក្សា ទៅលើស្ថានភាពចរាចរណ៍ផ្លូវគោក និងការស្រង់គំនិតពីអ្នកបើកបរលើដងផ្លូវ ជារៀងរាល់ថ្ងៃ ក្នុងទិសដៅនៅថ្ងៃអនាគត គឺចង់ចូលរួមចំណែកបញ្ចេញនូវគំនិតយោបល់ និងសំណូមពរ ដែលក្នុងនោះមានដូចជា សូមឲ្យប្រជាពលរដ្ឋគ្រប់រូបមានការតាំងចិត្ត និងចូលរួមខ្ពស់ពីការគិតគូរសុខទុក្ខ និងចេះយោគយល់អធ្យាស្រ័យខ្លាំងបំផុតទៅលើការបើកបរ លើសពីនេះសូមសិក្សាស្វែងយល់ពីទិដ្ឋភាពច្បាប់ ព្រមទាំងតាមដាននូវសេចក្តីប្រកាស ឬ ព័ត៌មានផ្សេងៗដែលទាក់ទិន នឹងស្ថានភាពចរាចរណ៍ផ្លូវគោកជាពិសេសសូមឲ្យមានសីលធមិខ្ពស់ទៅលើការចុះចតយានជំនិះឲ្យបានត្រឹមត្រូវ។ លើសពីនេះទៀតសោតជាពិសេសនៅក្នុងទីក្រុង សូមប្រជាពលរដ្ឋគ្រប់រូបមេត្តាគោរពនូវ គំនូសសញ្ញាលើដងផ្លូវ និងមានសីលធមិខ្ពស់ក្នុងការទទួលខុស ត្រូវ។ ចំពោះមន្ត្រីរាជការដែលមានសមត្ថកិច្ចក្នុងការអនុវត្ត សូមមេត្តាសិក្សាស្វែងយល់ឲ្យច្បាស់ពីច្បាប់ដែលខ្លួនកំពុងអនុវត្តឲ្យបានច្បាស់លាស់ត្រឹមត្រូវ និងមានសីលធម៌ស្របទៅតាមវិជ្ជាជីវៈមន្ត្រីរាជការ។ មិនត្រឹមតែប៉ុណ្ណោះក្នុងនាមរាជរដ្ឋាភិបាល ដែលកំពុងព្យាយាមអនុវត្ត និងដោះស្រាយបញ្ហាផ្សេងៗនៅក្នុងប្រទេស ប្រជាពលរដ្ឋ ជឿជាក់ថា និងមានការរៀបចំឲ្យមានហេដ្ឋារចនាសម្ពន្ធ ជាពិសេសទៅលើផ្លូវថ្នល់ ចំណតសាធារណៈ បំពាក់ឧបករណ៍បច្ចេកវិទ្យា បន្ថែមស្លាក់សញ្ញាចរាចរណ៍ ផ្សព្វផ្សាយឲ្យបាន ទំលំទូលាយបំផុតទៅលើវិធានការ ផ្សព្វផ្សាយច្បាប់ និងខ្លឹមសារអប់រំផ្សេងៗដែលមានសារៈប្រយោជន៍ ងាយយល់ និងមានប្រសិទ្ធភាពជូនប្រជាពលរដ្ឋទូទាំងប្រទេស ព្រមទាំងមានការគិតគូរឲ្យកាន់តែខ្លាំងខ្លាជាងនេះទៀតសម្រាប់ ដោះស្រាយ និងគិតគូរពីសុខទុក្ខប្រជាពលរដ្ឋក្នុងការប្រើប្រាស់ដងផ្លូវ។ មិនត្រឹមតែប៉ុណ្ណោះ រាជរដ្ឋាភិបាលក៏បានចូលរួមគិតគូរ សម្រាប់ដោះស្រាយទៅលើកត្តាដែលនាំឲ្យមានបញ្ហា

គ្រោះថ្នាក់ដូចជាគ្រឿងស្រវឹង គ្រឿងញៀន និងការកែច្នៃយានយន្តខុសស្តង់ដារបច្ចេកទេសផ្សេងៗ។ រាជរដ្ឋាភិបាលគួរតែព្យាយាមដំឡើងកម្រិតពន្ធនាំចូលនិងផលិតខ្ពស់ទៅលើ គ្រឿងស្រវឹង និងប្រឆាំងឲ្យបានខ្លាំងខ្លាទៅលើគ្រឿងញៀន ព្រោះវាមិនត្រឹមតែបង្កឲ្យមានគ្រោះថ្នាក់ចរាចរណ៍ទេ វាថែមទាំងបង្កឲ្យមានបញ្ហាធ្ងន់ធ្ងរផ្សេងៗ ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សង្គមជាតិទាំងមូល។ ចំពោះសង្គមស៊ីវិល សូមមេត្តាចូលរួមឲ្យបានច្រើន និងបំផុសបំផុលឲ្យបានកាន់តែខ្លាំងជាងនេះទៅទៀតក្នុងការ គាំទ្រ និងអនុវត្តបន្តទៅលើចរាចរណ៍ ដើម្បីចូលរួមទាំងអស់គ្នា។

សរុបមកក្នុងចំនុចខាងលើអាចនិយាយបានថា កត្តាដែលរៀបរាប់ទាំងអស់ខាងលើជាគំនិតយោបល់ពីការសាកសួរ របស់ប្រជាពលរដ្ឋ និងខ្ញុំដែលជាអ្នកសិក្សាស្រាវជ្រាវនេះ ក្នុងអត្តន័យចូលរួម និងគាំទ្រទៅលើ រាជរដ្ឋាភិបាលក្នុងការគិតគូរពីសុខទុក្ខប្រជាពលរដ្ឋ។ លើសពីនេះទាំងរាជរដ្ឋាភិបាល ទាំងសង្គមស៊ីវិល បាននិងកំពុងតែខិតខំប្រឹងប្រែងយ៉ាងសកម្ម ក្នុងការទប់ស្កាត់ និងស្វែងរកដំណោះស្រាយជាច្រើន ដើម្បីកាត់បន្ថយបញ្ហាផ្សេងៗ នៅលើដងផ្លូវ ដែលកំពុងមានការព្រួយបារម្ភ។ មិនត្រឹមតែមានការចូលរួមពីសំណាក់រាជរដ្ឋាភិបាល និងអង្គការ សង្គមស៊ីវិលប៉ុណ្ណោះទេ ក៏ទាមទារឲ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋខ្លួនឯងផង ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហា ផ្សេងៗ។ ប្រជាពលរដ្ឋគ្រប់រូប ត្រូវយល់ដឹងពីបញ្ហាដែលបង្កឡើងឲ្យមានគ្រោះថ្នាក់ចរាចរណ៍ និងចូលរួមផ្សព្វផ្សាយបន្តទៅកាន់អ្នកនៅជុំវិញឲ្យបានយល់ដឹង និងវិធីសាស្ត្រក្នុងការការពារផ្សេងៗ។ ដើម្បីកាត់បន្ថយអាត្រាគ្រោះថ្នាក់ចរាចរណ៍ប្រជាពលរដ្ឋក៏ដូចជាអង្គការនានាមួយចំនួន បានសំណូមពរឲ្យរាជរដ្ឋាភិបាលកម្ពុជា គិតគូរបន្ថែមទៀតទៅលើចរាចរណ៍ផ្លូវគោក និងក្នុងនាមប្រជាពលរដ្ឋសន្យា នឹងខិតខំព្យាយាមអនុវត្តទៅតាមការដឹកនាំរបស់រាជរដ្ឋាភិបាល ក្នុងគោលបំណងដើម្បីសង្គមជាតិទាំងមូលកាត់បន្ថយគ្រោះថ្នាក់ និងគ្មានគ្រោះថ្នាក់ចរាចរណ៍ ដោយស្របទៅតាមប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** " ថ្ងៃនេះ ថ្ងៃស្អែក គ្មានគ្រោះថ្នាក់ចរាចរណ៍ " ។

# សេចក្តីសន្និដ្ឋាន

យោងទៅតាមការបកស្រាយខាងលើនេះ អាចសន្និដ្ឋានបានថា ចរាចរណ៍ផ្លូវគោកនៅក្នុងព្រះរាជាណាចក្រកម្ពុជា សព្វថ្ងៃគឺមានភាពល្អប្រសើរជាងមុនបើធៀបរយៈពេល ប៉ុន្មានឆ្នាំកន្លងមកនេះ។ ក៏ប៉ុន្តែចរាចរណ៍ផ្លូវគោកនេះនៅតែជាកត្តាមួយដែលប្រជាពលរដ្ឋកម្ពុជាមានការព្រួញបារម្ភនៅឡើយ ដោយហេតុថា គ្រោះថ្នាក់ចរាចរណ៍នៅទូទាំងប្រទេសគឺកើតឡើងជារៀងរាល់ថ្ងៃ នៅក្នុងទីក្រុងមានការកកស្ទះ និងមិនមានសណ្តាប់ធ្នាប់ល្អ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ មិនទាន់មានភាពល្អឥតខ្ចោះនៅឡើយ ជាពិសេសការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិត ព្រមទាំងមិនទាន់សមស្របទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋកម្ពុជា។

កត្តាផ្សេងៗដែលបានចូលរួមចំណែកដែលបង្កើតឲ្យមានបញ្ហា ឬគ្រោះថ្នាក់ផ្សេងៗលើដងផ្លូវត្រូវបានកត់សម្គាល់ឃើញថាត្រូវបានកើតឡើងចេញពី កត្តាបុគ្គលខ្លួនឯង កត្តាផ្លូវថ្នល់ កត្តាអាកាសធាតុ និងយានយន្ត ជាដើម។ល។ គ្រោះថ្នាក់ចរាចរណ៍នេះផងដែលបានធ្វើឲ្យប៉ះពាល់ជាច្រើនដល់ ខាតបង់ថវិកាជាតិ ព្រមទាំងក្រុមគ្រួសារ ក្រុមគ្រួសារ, បន្សល់ទុកជនពិការ, ស្នាមរបួស និងបាត់បង់ជីវិត, និងបទល្មើសផ្សេងៗជាច្រើនទៀត។ យ៉ាងណាមិញទោះបីជាមានលក្ខណៈបែបនេះមែនពិតមែន ប៉ុន្តែយើងសង្កេតឃើញថា ការចូលរួមពីសំណាក់គ្រប់ភាគីដែលពាក់ព័ន្ធ ដែលបានធ្វើការទាក់ទងនឹងចរាចរណ៍ផ្លូវគោក គឺជាកត្តាយ៉ាងសំខាន់បំផុតនៅក្នុងការកាត់បន្ថយ ក៏ដូចជាស្វែងរកនូវវិធានការក្នុងការទប់ស្កាត់នៃការកើនឡើងចំពោះគ្រោះថ្នាក់ចរាចរណ៍ និងបញ្ហាផ្សេងៗនៅលើដង ផ្លូវ។ ការពន្លឿនការអនុវត្តច្បាប់ ក៏ដូចជាតាក់តែងសេចក្តីព្រាងគោលនយោបាយស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក ពិតជាចាំបាច់បំផុតសម្រាប់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ព្រោះបច្ចុប្បន្នការកើតឡើងនូវគ្រោះថ្នាក់ចរាចរណ៍នៅទូទាំងប្រទេសត្រូវបានកើតឡើងរាល់ថ្ងៃ ការនាំចូលនូវធាតុផ្សំផ្សេងៗដូចជា គ្រឿង ស្រវឹង គ្រឿងញៀន ឧបករណ៍ខុសបច្ចេកទេស មាននៅក្នុងប្រទេសនៅឡើយ ជាពិសេសអនុវត្តទៅតាមផែនការសកម្មភាពក្នុងគោលនយោបាយឲ្យបានកាន់តែខ្លាំងក្លាជាងនេះ ទៅទៀត ឲ្យស្របទៅតាមស្ថានភាពចរាចរណ៍នាពេលបច្ចុប្បន្ន។

តាមរយៈការសិក្សាស្រាវជ្រាវនេះដែល ក៏បានបង្ហាញឲ្យឃើញផងដែរថាបញ្ហានៃការប្រើប្រាស់នៅលើដងផ្លូវ នៅក្នុងសង្គមខ្មែរមានភាពល្អប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃនៅតាមទីជនបទ ក៏ប៉ុន្តែមិនសូវមានភាពល្អប្រសើរខ្លាំងណាស់ណាទេនៅក្នុងរាជធានីភ្នំពេញ ដោយសារមានកំណើនប្រជាជនមករស់នៅទីក្រុងពីមួយឆ្នាំទៅមួយឆ្នាំ។ នៅក្នុងស្ថានភាពសព្វថ្ងៃទៅលើចរាចរណ៍ផ្លូវគោក គឺនៅមានភាពព្រួញបារម្ភនៅឡើយនៅពេលធ្វើដំណើរជាពិសេស ការធ្វើដំណើរផ្លូវឆ្ងាញ

ផ្តោតទៅលើផ្លូវ ជាតិ។ ការធ្វើដំណើរសព្វថ្ងៃនៅក្នុងទីក្រុង ក៏ជាបញ្ហាមួយដែលមានការពិបាក នៅពេលដែលមានការកកស្ទះខ្លាំងដែលបណ្តាលឲ្យខាតបង់ពេលវេលា និងមានការព្រួញបារម្ភផង ដែលទៅលើការធ្វើដំណើរពេលយប់ ដែលមានសភាពស្ងប់ស្ងាត់។ ការព្រួញបារម្ភយ៉ាងខ្លាំងពីសុវត្ថិភាពក្នុងការបើកបរ ទៅលើអ្នកដែលពិសារគ្រឿងស្រវឹង ដែលជារឿងមួយប្រជាពលរដ្ឋគ្រប់រូបគួរគិតគូរ និងរាជរដ្ឋាភិបាលដាក់វិធានការទៅលើបញ្ហានេះឲ្យបានតឹងរឹង។

សរុបសេចក្តីមកការចូលរួមទាំងអស់គ្នា ទាំងរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋគួរគប្បីធ្វើការសិក្សាអំពីចរាចរណ៍ និងកត្តាមួយចំនួនដែលបង្កឲ្យមានគ្រោះថ្នាក់ចរាចរណ៍នេះដើម្បីបញ្ចៀសបញ្ហា និងដើម្បីយន្តការដំណោះស្រាយ និងឆ្លើយតបភ្លាមៗទៅនឹងការកើនឡើងនៃ អត្រានៃអ្នកគ្រោះថ្នាក់ចរាចរណ៍។

តាមរយៈការសិក្សាស្រាវជ្រាវជុំវិញប្រធានបទដែលស្តីអំពី "**ចរាចរណ៍ផ្លូវគោក និងបញ្ហាប្រឈមនៅកម្ពុជាបច្ចុប្បន្ន**" ពិតជាបានទទួលនូវលទ្ធផលមួយចំនួន ដែលបានយល់ច្បាស់ពីកត្តាគួបផ្សំឲ្យមានបញ្ហាផ្សេងៗដែលកើតមានឡើងទាក់ទងទៅនឹងចរាចរណ៍ផ្លូវគោក និងវិធីសាស្ត្រ ផ្សេងៗក្នុងការយល់ដឹងពីវិធីការការពារទប់ស្កាត់បញ្ហាទាំងអស់នេះ ព្រមទាំងការយល់ដឹងអំពីច្បាប់ និងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងការគិតគូរសុខទុក្ខរបស់ប្រជាពលរដ្ឋ ទៅលើផ្នែកចរាចរណ៍ផ្លូវគោកនេះ។

ក្នុងនាមខ្ញុំជាអ្នកសិក្សាស្រាវជ្រាវ ទៅលើប្រធានបទនេះ ខ្ញុំជឿជាក់ថាលទ្ធផល ដែលទទួលបានពីកិច្ចការស្រាវជ្រាវខាងលើព្រមជាមួយនឹងដំណោះស្រាយបន្តបន្ទាប់នេះ ពិតជាបានបន្ថែមអត្ថន័យកាន់តែច្បាស់ថែមទៀតទៅលើប្រធានបទដែលរៀបរាប់ខាងលើ។ តាមរយៈលទ្ធផលនេះផងដែរ ទោះបីជាមានបញ្ហាផ្សេងៗដែលទាក់ទង និងចរាចរណ៍នៅតែមានកើតឡើងជារៀងរាល់ថ្ងៃក៏ដោយ ប៉ុន្តែយើងអាចធ្វើការ ដោះស្រាយវាបានដោយផ្អែកទៅលើឆន្ទៈនៃការចូលរួមពីរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋដែលជាដំណោះស្រាយមួយដ៏ល្អពិតប្រាកដ។

# អនុសាសន៍

ដើម្បីរួមចំណែកជួយដល់សង្គមខ្មែរ ក្នុងការទប់ស្កាត់ និងកាត់បន្ថយភាពតានតឹង និងគ្រោះថ្នាក់ចរាចរណ៍ ក្នុងនាមជានិស្សិត សូមផ្តល់នូវអនុសាសន៍មួយចំនួនដូចតទៅ៖

១. អាជ្ញាធរមន្ត្រី មានសមត្ថកិច្ច ត្រូវអនុវត្តច្បាប់ និងដាក់ទោសដល់ជនទាំងឡាយណាដែល មិនអនុវត្តតាមច្បាប់ចរាចរណ៍ផ្លូវគោកនិងជាពិសេសជនទាំងឡាយណាដែលបង្កហិង្សានៅលើដង ផ្លូវ។

២. រាជរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធ និងសង្គមស៊ីវិលនានា គួរតែដាក់បញ្ចូលនូវកម្មវិធីអប់រំផ្សេងៗស្តីពីវិធីសាស្ត្រការពារ ទប់ស្កាត់នៃគ្រោះថ្នាក់ចរាចរណ៍។

៣. រាជរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធ និងសង្គមស៊ីវិលនានា គួរផ្សំផ្សាយអំពីវិធីសាស្ត្រការការពារ ច្បាប់ចរាចរណ៍ និងផលប៉ះពាល់នៃគ្រោះថ្នាក់ចរាចរណ៍ឲ្យបានកាន់តែទូលំទូលាយ ជាពិសេសនៅតាមជនបទស្រុកស្រែចម្ការ។

៤. ស្ថានីយ៍ទូរទស្សន៍ វិទ្យុ និងសារព័ត៌មាននានាគួរតែចូលរួមកាត់បន្ថយការផ្សព្វផ្សាយអំពីគ្រឿងស្រវឹង នៅតាមបណ្តាយផ្សព្វផ្សាយផ្សេងៗ ព្រោះអ្នកគ្រោះថ្នាក់ចរាចរណ៍ភាគច្រើនកើតឡើងក្នុងការស្ថានភាពស្រវឹង

៥. រាជរដ្ឋាភិបាលគួរយកចិត្តទុកដាក់បន្ថែមទៀតទៅលើហេដ្ឋារចនាសម្ពន្ធផ្លូវថ្នល់ ស្លាកសញ្ញាចរាចរណ៍ និងបំពាក់បច្ចេកវិទ្យាទំនើបៗបន្ថែមទៀតនៅតាមដងផ្លូវសាធារណៈ ជាពិសេសពេលយប់ នៅតាមបណ្តោយផ្លូវជាតិ

៦. រឹតបន្តឹងច្បាប់ជាពិសេសទៅលើការផាកពិន័យ ចំពោះអ្នកបើកបរហួសល្បឿនកំណត់ និងបើកបរក្នុងស្ថានភាពស្រវឹង

៧. រាជរដ្ឋាភិបាល ឬស្ថាប័នមានសមត្ថកិច្ច រៀបចំទីកន្លែងសាធារណៈឲ្យបានច្រើនសម្រាប់ចត រថយន្ត និងវិធានការ ផ្សេងៗ ជាពិសេសអាជីវករ រកស៊ីដែលរំលោភដីសាធារណៈ

៨. រាជរដ្ឋាភិបាលគួររឹតបន្តឹងទៅលើការនាំចូល ឬផលិតរបស់របរដែលគ្មានគុណភាព និងខុសស្តង់ដារបច្ចេកទេស ដូចជាមួកសុវត្ថិភាព គ្រឿងតុបតែងយានយន្តជាដើម។ល។

៩. សូមមន្ត្រីមានសមត្ថកិច្ចព្យាយាមស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ជៀសវាងការកើតឡើងប្រការណាមួយដែលធ្វើឲ្យជនរងគ្រោះ ទទួលបានភាគអយុត្តិធម៌។

១០. សូមសំណូមពរប្រជាពលរដ្ឋគ្រប់រូបមេត្តាព្យាយាមកុំប្រើអំពើហិង្សាទៅលើជនរងគ្រោះ ឬជនបង្កហេតុនៅពេលមានគ្រោះថ្នាក់ចរាចរណ៍ដែលបណ្តាលឲ្យកើតឡើងអំពើអសន្តិសុខ និងគ្រោះថ្នាក់ ផ្សេងៗដែលអាចបណ្តាលឲ្យបាត់បង់ជីវិត។

១១. សូមប្រជាពលរដ្ឋកុំព្យាយាម កាត់ក្តីដោយឯងៗ ឬខ្វះការពិចារណា ដែលអាចបណ្តាលឲ្យមានការយល់ច្រលំ និងគ្រោះថ្នាក់ផ្សេងៗដែលប៉ះពាល់ដល់ជនរងគ្រោះ។

ខ្ញុំបាទសង្ឃឹមថាអនុសាសន៍ដែលផ្តល់នៅខាងលើនេះត្រូវបានរាជរដ្ឋាភិបាល ក៏ដូចជាប្រជាពលរដ្ឋអាចអនុវត្តបាននោះបញ្ហាផ្សេងៗ ឬគ្រោះថ្នាក់ចរាចរណ៍នឹងកាត់បន្ថយធ្វើឲ្យសង្គមខ្មែរមានសេចក្តីសុខ និងមានសណ្តាប់ធ្នាប់ល្អ ព្រមទាំងមានការរីកលូតលាស់ឡើងនូវកំណើនសេដ្ឋកិច្ចជាតិផងដែល។

# ឯកសារយោង

## ក. ឯកសារច្បាប់

១. ច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក ប្រកាសឲ្យប្រើនាថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧

## ខ. ឯកសារលិខិតបទដ្ឋាន

១. អនុក្រឹត្យលេខ ២៩, អនក្រ, បក,ស្តីពីការកែប្រែឧបសម្ពន្ធអនុក្រឹត្យលេខ១០៩ អនក្រ,បក ចុះថ្ងៃទី ១៨ មីនា ឆ្នាំ២០១៣ ស្តីពីបែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវ និងលេខផ្លូវនិងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦

២. សេចក្តីប្រកាសស្តីពី ការរឹតបន្តឹងច្បាប់ចរាចរណ៍ផ្លូវគោក

៣. អនុក្រឹតស្តីពី ការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក លេខ ៨៥ អនក្រ.បក ធ្វើនៅថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៦។

៤. សេចក្តីជូនដំណឹង លេខ ០២៨ នៅថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៦ អំពី ស្មារតីទទួលខុសត្រូវរួមគ្នាអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

៥.សេចក្តីជូនដំណឹង លេខ ០២៦ គ.ស.ច.ត ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៦ អំពី ដើម្បីអនុវត្តឲ្យបាន លទ្ធផលល្អប្រសើរតាមផែនការ សំដៅកាត់បន្ថយហានិភ័យដែលបណ្តាលពីការមិនពាក់មួកសុវត្ថិភាព ហើយឈានទៅការផ្លាស់ប្តូរ ឥរិយាបទ អ្នកអ្នកជិះទោចក្រយាន ត្រូវយកចិត្តទុកដាក់ចំពោះសុវត្ថិភាពផ្ទាល់ខ្លួន។

## គ. ឯកសារទ្រឹស្តី

១. ប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** អំពី ថ្ងៃនេះ ថ្ងៃស្អែក គ្មានគ្រោះថ្នាក់ចរាចរណ៍ ផ្ញើសារទៅពលរដ្ឋនៅទូទាំងប្រទេស ព្រមទាំងទៅសមត្ថកិច្ចផង អោយចងចាំទុកក្នុងចិត្ត។

២. ប្រសាសន៍របស់ ឯកឧត្តម រដ្ឋមន្ត្រីក្រសួងព័ត៌មាន អំពីក្រសួងព័ត៌មានគ្រោងនឹងបើកសិក្ខាសិលាបណ្តុះបណ្តាលពីច្បាប់ ចរាចរណ៍ថ្មីដល់អ្នកបើកបររថយន្តរបស់ថ្នាក់ដឹកនាំ។

៣. ប្រសាសន៍របស់ **ឧត្តមសេនីយ៍ឯក រុន រ័ត្នវីរៈ** ការបង់ប្រាក់ពិន័យចរាចរណ៍របស់ **សម្តេចតេជោ ហ៊ុន សែន** ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ និងគំរូដ៏ល្អសម្រាប់ប្រជាពលរដ្ឋនិងថ្នាក់ដឹកនាំដទៃទៀត។

៤. ប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក អំពីការ ទទួលបានពានរង្វាន់អន្តរជាតិលើកាងារសុវត្ថិភាពចរាចរណ៍ លើកាងារសុវត្ថិភាពចរាចរណ៍ នៃ**ព្រះអង្គម្ចាស់** Michael នៃ ចក្រភពអង់គ្លេស នៅទីក្រុងឡុងនៃចក្រភពអង់គ្លេស។

៥. សៀវភៅឯកសារ អ្វីដែលអ្នកបើកបរត្រូវយល់ដឹង របស់ លោក ព្រាប ច័ន្ទវិបុល ប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក

៦. សៀវភៅ ការសេពគ្រឿងស្រវឹង និងការបើកបរ (សៀវភៅណែនាំពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកសំរាប់អ្នកដឹកនាំ និងអ្នកអនុវត្ត)

៧. សៀវភៅ មួកសុវត្ថិភាព (សៀវភៅណែនាំពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកសំរាប់អ្នកធ្វើសេចក្តី សម្រេច និងអ្នកអនុវត្ត)

## ឃ ឯកសារគោលសំខាន់ៗ

**បញ្ជាក់** របាយការណ៍មួយចំនួនត្រូវបានប្រើប្រាស់ក្នុងឆ្នាំ២០១៦ ដោយសាររបាយការណ៍ឆ្នាំ២០១៧ តាមស្ថាប័នមួយចំនួនមិនទាន់បានចេញផ្សាយ។

១. គោលនយោបាយជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ផែនការឆ្នាំ២០១៤-២០២០ដែលអនុម័តដោយគណៈរដ្ឋមន្ត្រី

២. គេហទំព័រ គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក

៣. សៀវភៅ របាយការណ៍ស្តីពីជនរងគ្រោះ និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកឆ្នាំ២០១៦

៤. គេហទំព័រ ក្រសួងមហាផ្ទៃ

៥.គេហទំព័រ អគ្គសងការនគរបាលជាតិ

៦. គេហទំព័រ ក្រសួងសាធារណៈការ និងដឹកជញ្ជូន

៧. គេហទំព័រ www.Samdechhunsen.gov.kh

## ខ. ឯកសារផ្សេងៗ

១. ទស្សនាវដ្តីថ្មីៗ “សន្ទុះកំណើនម៉ូតូចំនួន ៣០ ម៉ឺនគ្រឿងក្នុងមួយឆ្នាំ ដែលចុះផ្សាយន ថ្ងៃទី ០២ ខែមករា ឆ្នាំ២០១៧”

២. ទស្សនវដ្តីកោះសន្តិភាព “ថ្ងៃនេះ ថ្ងៃស្អែកគ្មានគ្រោះថ្នាក់ចរាចរណ៍ អនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាលបិទនៅគ្រប់ទីតាំងនៅក្នុងក្រុងប៉ោយប៉ែត” ចុះផ្សាយនៅថ្ងៃទី ០៩ ខែមេសា ឆ្នាំ ២០១៧

៣. ទស្សនាវដ្ដី Freshnews "យុទ្ធនាការរឹតបន្តឹងច្បាប់ចរាចរណ៍ទូទាំងប្រទេស" ចុះថ្ងៃទី ២១ ខែមេសា ឆ្នាំ២០១៨

៤. ទស្សនាវដ្ដី CEN, ពលរដ្ឋប្ដេជ្ញាចូលរួមគោរពច្បាប់ចរាចរណ៍គ្រប់ៗគ្នា ក្រោយពីទទួលបានមួកសុវត្ថិភាព និងឯកសារពាក់ព័ន្ធនិងច្បាប់ចរាចរណ៍, ចុះផ្សាយ ថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០១៧

៥. គេហទំព័រទីភ្នាក់ងារសារព័ត៌មានកម្ពុជា, កាកបាទក្រហមកម្ពុជាជួយបណ្ដុះបណ្ដាលច្បាប់ចរាចរណ៍ដល់សិស្សវិទ្យាល័យជម្ពូវ័ន, ភ្នំពេញថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧

៦. គេហទំព័រ អង្គការទិន្នន័យអំពីការអភិវឌ្ឍ, គោលនយោបាយសុវត្ថិភាពចរាចរណ៍ត្រូវបានគ្រោងទុក, ចុះផ្សាយថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨

៧. គេហទំព័រ Propertyarea, កម្ពុជាខាតបង់សេដ្ឋកិច្ច ៣០០លានដុល្លាដោយសារគ្រោះថ្នាក់ចរាចរណ៍, ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧

៨. គេហទំព័រ វីអូអេ, របាយការណ៍ធនាគារពិភពលោកបង្ហាញថាគ្រោះថ្នាក់ចរាចរណ៍រារាំងដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍ អន្តរជាតិ ថ្ងៃ ១៣ ខែមករា ២០១៨

៩. គេហទំព័ររបស់ khmerload, ធ្លាប់ឆ្ងល់ទេ ហេតុអ្វីនៅភ្នំពេញចេះតែស្ទះខ្លាំងឡើងៗ ហើយកើតឡើងមកពីមូលហេតុអ្វី និងមានដំណោះស្រាយបែបណា?, ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៧

១០. ខិតប័ណ្ណមានចំណងជើង គោរពច្បាប់ចរាចរណ៍គឺដើម្បីការពារជីវិតអ្នកគ្រួសារអ្នក និងអ្នកដទៃ, ការពារជីវិតអ្នកពាក់មួកសុវត្ថិភាពឲ្យបានត្រឹមត្រូវ

១១. ដកស្រង់ចេញពីខ្លឹមសារខិតប័ណ្ណរបស់ផ្សព្វផ្សាយ ចំនុចការពារជីវិតអ្នកកុំបើកបរក្រោមឥទ្ធិពលគ្រឿងស្រវឹង

# ឧបសម្ព័ន្ធ

## រូបភាព នឹងខ្លឹមសារ



# ផ្លាកសញ្ញាបញ្ជា (Mandatory Signs)



តំរូវបត់ស្តាំ



តំរូវបត់ឆ្វេង



តំរូវងាកឆ្វេង



តំរូវងាកស្តាំ



តំរូវទៅមុខត្រង់



តំរូវបត់ឆ្វេង ឬបត់ស្តាំ



តំរូវបត់ស្តាំ នៅខាងមុខ



តំរូវបត់ឆ្វេង នៅខាងមុខ



តំរូវទៅមុខត្រង់ ឬបត់ឆ្វេង



តំរូវទៅមុខត្រង់ ឬបត់ស្តាំ



តំរូវងាកឆ្វេង ឬងាកស្តាំ



ផ្លូវសំរាប់យានយន្តនៅផ្លូវយន្តបថ



ចប់ផ្លូវសំរាប់យានយន្ត
នៅផ្លូវយន្តបថ



ផ្លូវសំរាប់ថ្មើរជើង



ចប់ផ្លូវសំរាប់ថ្មើរជើង




កំណត់ល្បឿនអប្បរមា
30Km/h




ចប់កំណត់ល្បឿនអប្បរមា
30Km/h



ផ្លូវសំរាប់ទោចក្រយាន



ចប់ផ្លូវសំរាប់ទោចក្រយាន



ផ្លូវសំរាប់ថ្មើរជើង
និងទោចក្រយាន



ផ្លូវសំរាប់រថយន្តដឹក
អ្នកដំណើរ



ចប់ផ្លូវសំរាប់រថយន្ត
ដឹកអ្នកដំណើរ




ប្រកាន់ស្តាំ




បន្ថយល្បឿន



ផ្លូវសំរាប់រទេះអូសទាញដោយសត្វ

## បង្គោលសញ្ញាចរាចរណ៍ (Posts Signs)


សញ្ញាលើរបាំងផ្លូវកោងទៅស្តាំ


សញ្ញាបង្ហាញឧបសគ្គ
នៅខាងស្តាំ


សញ្ញាបង្ហាញឧបសគ្គ
នៅលើទ្រូងផ្លូវ



បង្គោលគីឡូម៉ែត្រ
(សំរាប់ចន្លោះ ១០គ.ម)



បង្គោលគីឡូម៉ែត្រ
(សំរាប់ចន្លោះ ១គ.ម)

## ផ្លាកសញ្ញាបង្ហាញទិសដៅ (Direction Signs)


គំនូសសញ្ញាព្រួញបត់ឆ្វេង


គំនូសសញ្ញាព្រួញទៅមុខត្រង់
និងបត់ឆ្វេង


គំនូសសញ្ញាព្រួញទៅមុខត្រង់


គំនូសសញ្ញាព្រួញទៅមុខត្រង់
និងបត់ស្តាំ


គំនូសសញ្ញាព្រួញបត់ស្តាំ

## ផ្លាកសញ្ញាសិទ្ធិអាទិភាព (Priority Signs)


ផ្លូវធំមានសិទ្ធិ


ផ្លូវសំខាន់មានសិទ្ធិ


ចប់ ផ្លូវសំខាន់មានសិទ្ធិ


ផ្តល់សិទ្ធិអាទិភាពអោយ
យានមកពីទិសផ្ទុយ


ផ្តល់សិទ្ធិអាទិភាពអោយគេ


ផ្តល់សិទ្ធិអាទិភាពអោយគេ
(នៅរង្វង់មូល)



ត្រូវឈប់សិន (ទោះមានឬគ្មាន
យានឆ្លងកាត់ក៏ដោយ)


មានសិទ្ធិអាទិភាពលើយាន
មកពីទិសផ្ទុយ


មានផ្លូវរថភ្លើងឆ្លងកាត់
(មួយខ្សែ)


មានផ្លូវរថភ្លើងឆ្លងកាត់
(ពីរខ្សែ ឬច្រើនខ្សែ)

## ភ្លើងសញ្ញាចរាចរណ៍ (Traffic Light)



ភ្លើងក្រហម: ហាមឆ្លងកាត់ ឬ ត្រូវឈប់

ភ្លើងលឿង: ប្រុងប្រយ័ត ភ្លើងក្រហម ជិតមកដល់

ភ្លើងបៃតង: អនុញ្ញាតអោយធ្វើដំណើរ

ភ្លើងព្រួញបៃតង: អនុញ្ញាតអោយបត់ស្តាំដោយប្រុងប្រយ័ត្ន

ភ្លើងសញ្ញាចរាចរណ៍ ៣ពណ៌



ភ្លើងសញ្ញាចរាចរណ៍ ៣ពណ៌ជាព្រួញៈត្រូវអនុវត្តិតាមទិសព្រួញ។ ឯពណ៌ទាំង៣មានអត្ថន័យដូចភ្លើងសញ្ញាចរាចរណ៍ ៣ពណ៌ដែល



ក្រហម: ហាមឆ្លងកាត់ ឬត្រូវឈប់

បៃតង: អនុញ្ញាតឱ្យបន្តដំណើរ



ក្រហម: ត្រូវឈប់

លឿង: ត្រូវប្រុងប្រយ័ត្ន




- ក្រហម: ហាមឆ្លងកាត់ ឬត្រូវឈប់
- បៃតង: អនុញ្ញាតឱ្យបន្តដំណើរ
- លេខ សម្រាប់កំណត់ចំនួនវិនាទី

## ផ្លាកសញ្ញាប្រាប់ ទីប្រជុំជន និងព្រំប្រទល់តំបន់ (Build up Area and Boundary signs)




ចូលទីប្រជុំជន ភ្នំពេញ




ចេញពីទីប្រជុំជន ភ្នំពេញ




ព្រំប្រទល់ខេត្តកំពង់ចាម




ចប់ព្រំប្រទល់ខេត្តកំពង់ចាម

### សញ្ញាប្រាប់ឈ្មោះផ្លូវ (Street Name Signs)




មហាវិថី ព្រះនរោត្តម




វិថី ព្រះត្រសក់ផ្អែម




រុក្ខវិថី ក្រមួនសរ




ផ្លូវលេខ ១១៣

## ផ្លាកសញ្ញាបណ្ដោះអាសន្ន (Temporary Signs)



ការដ្ឋានចាប់ផ្ដើម
ពីផ្លាកសញ្ញានេះតទៅ




ផ្លូវវាង




ចប់ ការដ្ឋាន




សញ្ញានេះ ប្រើសំរាប់
ឱ្យអ្នកបើកបរ
ឈប់នៅមុខ
ភ្នាក់ងារការដ្ឋាន




សញ្ញានេះ ប្រើសំរាប់
ឱ្យអ្នកបើកបរ
បន្តដំណើរទៅមុខបាន



មានការដ្ឋាននៅខាងមុខ



បង្គោលរាងសាជី



សញ្ញាព្រួញបង្វែរទិស




សញ្ញាឈប់



បន្ថយល្បឿន

## ផ្លាកសញ្ញាដាក់បន្ថែមពីក្រោម (Supplementary Signs)



ហាមចតចំពោះរថយន្ត
ដឹកទំនិញធុនធំ




ហាមចតពីម៉ោង ៥ដល់
ម៉ោង ២០



ហាមចតចាប់ពីត្រឹមនេះ
ទៅមុខ



ហាមចតចាប់ពីត្រឹមនេះ
មកក្រោយ



ហាមឈប់ទាំងនៅ
ខាងឆ្វេង និងខាងស្ដាំ




ប្រយ័ត្នគ្រោះថ្នាក់មាន
ច្រកចេញចូលរោងចក្រ

# សញ្ញាបញ្ជារបស់ភ្នាក់ងារនគរបាលចរាចរណ៍
# (Traffic Police Signals)



សញ្ញាមានន័យដូចភ្លើងស្តុបពណ៌បៃតង



សញ្ញាមានន័យដូចភ្លើងស្តុបពណ៌លឿង



សញ្ញាមានន័យដូចភ្លើងស្តុបពណ៌ក្រហម



១

អែបស្តាំ



២

បន្ថយល្បឿន



៣

ឈប់



បន្ថែមល្បឿនទៅមុខ



ធ្វើដំណើរទៅមុខ



យានជំនិះមកពីខាងស្តាំដៃនគរបាល( ដើម្បីឱ្យយានមកឆ្វេងដៃធ្វើការបត់ឆ្វេង ឬ ទៅមុខត្រង់)

# គំនូសសញ្ញានៅលើផ្លូវ (Road Markings)



គំនូសសញ្ញាទោលជាប់ បែងចែកទិសចរាចរណ៍ ( ហាមបើកបរជាន់)



គំនូសសញ្ញាទោលដាច់ៗ បែងចែកទិសចរាចរណ៍ ( អាចឆ្លងកាត់ រឺជែងបាន)



គំនូសសញ្ញាភ្លោះ បែងចែកទិសចរាចរណ៍ ( យានទៅខាងគំនូសដាច់ៗ អាចឆ្លងកាត់ជែងបាន)



គំនូសសញ្ញាភ្លោះជាប់ បែងចែកទិសចរាចរណ៍ ( ហាមបើកបរជាន់ )



គំនូសសញ្ញាបែងចែកទ្រូងផ្លូវ ជាគន្លង ( អាចឆ្លងកាត់ រឺជែងបាន )



គំនូសសញ្ញាសំគាល់ជាយផ្លូវ ( ត្រូវបើកបរក្នុងជាយផ្លូវដែលកំណត់ )



គំនូសសញ្ញាព្រួញបង្ហាញទិសដៅ ( ត្រូវបើកបរតាមសញ្ញាព្រួញ )



គំនូសសញ្ញាសំរាប់ថ្មើរជើងឆ្លងកាត់ ( ត្រូវដើរលើគំនូសសញ្ញា )



គំនូសសញ្ញាទោលលឿង-សលើគែមចិញ្ចើមផ្លូវ ( គំនូសនេះ ប្រើសំរាប់ការហាមចត)



គំនូសសញ្ញាទោលក្រហម-ស លើគែមចិញ្ចើមផ្លូវ ( គំនូសនេះ ប្រើសំរាប់ការហាមឈប់)



គំនូសញ្ញាដាច់ៗពណ៌សរាងចតុកោណកែងដែលមានជ្រុងវែងស្របនិងគែមចិញ្ចើមផ្លូវប្រើដើម្បីកំណត់ទីកន្លែងឱ្យរថយន្តបចត។



គំនូសសញ្ញាខ្មៅលឿង លើខឿនទ្រូងផ្លូវសំរាប់ឱ្យអ្នកបើកបរប្រុងប្រយ័ត្នមាន ខឿនលើទ្រូងផ្លូវ។

# ព្រះរាជក្រម

នស/រកម/០១១៧/០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា៨ មាត្រា៤០ មាត្រា៤១ មាត្រា៤៧ មាត្រា៤៨ មាត្រា៧៥ មាត្រា៧៧ មាត្រា៨២ និងមាត្រា៩០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០១៥ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៤ ខែមករា ឆ្នាំ២០១៧ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# វិសោធនកម្មមាត្រា ៨ មាត្រា ៤០ មាត្រា ៤១ មាត្រា ៤៧ មាត្រា ៤៨ មាត្រា ៧៥ មាត្រា ៧៧ មាត្រា ៨២ និងមាត្រា ៩០ នៃច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក

ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រម

លេខ នស/រកម/០១១៥/០០១

ចុះថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០១៥

**មាត្រាមួយ.-**

មាត្រា ៨ មាត្រា ៤០ មាត្រា ៤១ មាត្រា ៤៧ មាត្រា ៤៨ មាត្រា ៧៥ មាត្រា ៧៧ មាត្រា ៨២ និងមាត្រា ៩០ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី ៩ ខែ មករា ឆ្នាំ២០១៥ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

**មាត្រា ៨.-ថ្មី**

គ្រប់អ្នកបើកបរយានយន្តគ្រប់ប្រភេទ ត្រូវអនុវត្តនូវវិធានការដូចតទៅ៖

១- ត្រូវមានបណ្ណបើកបរចំពោះអ្នកបើកបរយានយន្តដូចខាងក្រោម៖

-រថយន្តគ្រប់ប្រភេទ

-ទោចក្រយានយន្តសណ្ដោងរ៉ឺម៉ក និងត្រីចក្រយានយន្ត

-យានយន្តដែលមានទំហំស៊ីឡាំងលើសពី ១២៥ (មួយរយម្ភៃប្រាំ) សង់ទីម៉ែត្រគូបឡើងទៅ ឬមានថាមពលអគ្គិសនីលើសពី ១១ (ដប់មួយ) គីឡូវ៉ាត់ ។ ចំពោះយានយន្តដែលមានទំហំស៊ីឡាំងចាប់ពី ១២៥ (មួយរយម្ភៃប្រាំ) សង់ទីម៉ែត្រគូបចុះក្រោម ឬមានថាមពលអគ្គិសនីចាប់ពី ១១ (ដប់មួយ) គីឡូវ៉ាត់ចុះក្រោម អ្នកបើកបរមិនតម្រូវឲ្យមានបណ្ណបើកបរឡើយ ប៉ុន្តែត្រូវមានអាយុយ៉ាងតិច ១៥ (ដប់ប្រាំ) ឆ្នាំឡើងទៅ ដោយមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណណាមួយ ។

២- នៅពេលបើកបរយានជំនិះ អ្នកបើកបរត្រូវមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ចហើយស្ថិតក្នុងស្ថានភាពដែលអាចធ្វើសកម្មភាពបើកបរបានយ៉ាងស្រួល និងឆាប់រហ័ស ជាពិសេសលទ្ធភាពនៃការធ្វើចលនាមិនត្រូវឲ្យមានការរំខានឡើយ ។

៣- ហាមធ្វើឲ្យរំខានដល់អ្នករស់នៅជាប់តាមដងផ្លូវ និងអ្នកប្រើប្រាស់ផ្លូវ ។

៤- ហាមពិសាគ្រឿងស្រវឹងដែលបណ្ដាលឲ្យមានអត្រាជាតិអាល់កុលចាប់ពី ០,២៥ (សូន្យក្បៀសម្ភៃប្រាំ) មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៥០ (សូន្យក្បៀសហាសិប) ក្រាមក្នុងមួយលីត្រឈាមឡើងទៅ ។

៥- ហាមបើកបរយានជំនិះដែលមានកង់ច្រវាក់ដែកផ្ទាល់លើទ្រូងផ្លូវ ។ យានជំនិះប្រភេទនេះ ត្រូវដឹកតាមយានជំនិះដែលមានប្រភេទកង់កៅស៊ូ ។

៦- ហាមប្រើទូរស័ព្ទនៅពេលកំពុងបើកបរយានជំនិះដោយគ្មានឧបករណ៍សំឡេងភ្ជាប់ទំនាក់ទំនង ។

៧- ហាមផ្ទុកអ្នកដំណើរ ទំនិញ ឬវត្ថុផ្សេងៗដែលនាំឲ្យបាំងភ្នែកអ្នកបើកបរ ។

៨- ទោចក្រយានយន្តអាចផ្ទុកមនុស្សពីរនាក់និងអាចបន្ថែមបានកុមារមួយនាក់ ។ អ្នកបើកបរទោចក្រយានយន្តនិងអ្នករួមដំណើរ ព្រមទាំងកុមារដែលមានអាយុចាប់ពី ៣(បី)ឆ្នាំ ឡើងទៅ

ត្រូវពាក់មួកសុវត្ថិភាពឲ្យបានត្រឹមត្រូវ ។ អ្នកបើកបរត្រីចក្រយានយន្ត និងអ្នកបើកបរទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ត្រូវពាក់មួកសុវត្ថិភាពឲ្យបានត្រឹមត្រូវ ។

៩- នៅក្នុងទីប្រជុំជនអ្នកបើកបរ និងអ្នករួមដំណើរជិះកៅអីមុខនៃរថយន្ត ត្រូវពាក់ខ្សែក្រវ៉ាត់សុវត្ថិភាព ។

១០-នៅក្រៅទីប្រជុំជនអ្នកបើកបរ និងអ្នករួមដំណើរទាំងអស់តាមរថយន្ត ត្រូវពាក់ខ្សែក្រវ៉ាត់សុវត្ថិភាព ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៩០ ថ្មី នៃច្បាប់នេះ ។

១១-កុមារអាយុតិចជាង ១០(ដប់) ខែ ត្រូវដាក់ក្នុងកៅអីសម្រាប់កុមារដេក និងមានខ្សែក្រវ៉ាត់សុវត្ថិភាពចងផ្អែកកៅអីនេះឲ្យជាប់ទៅនឹងកៅអីក្រោយនៃរថយន្ត ។

១២-កុមារមានអាយុចាប់ពី ១០ (ដប់ )ខែ ទៅក្រោម ៥(ប្រាំ) ឆ្នាំ ត្រូវអង្គុយក្នុងកៅអីសម្រាប់កុមារដែលមានខ្សែក្រវ៉ាត់សុវត្ថិភាពចងផ្អែកកៅអីនេះឲ្យជាប់ទៅនឹងកៅអីក្រោយនៃរថយន្ត ។

១៣- ហាមកុមារអាយុក្រោម ១០ (ដប់) ឆ្នាំ អង្គុយនៅកៅអីមុខនៃរថយន្ត ។

**មាត្រា ៤០._ថ្មី**

បណ្ណបើកបរជាតិសម្រាប់បើកបរយានយន្តក្នុងព្រះរាជាណាចក្រកម្ពុជា មាន ៥ (ប្រាំ) ប្រភេទដូចខាងក្រោម៖

**ប្រភេទក** : ទោចក្រយានយន្ត ដែលមានទំហំស៊ីឡាំងលើសពី ១២៥ (មួយរយម្ភៃប្រាំ) សង់ទីម៉ែត្រគូប ឬមានថាមពលអគ្គិសនីលើសពី ១១ (ដប់មួយ) គីឡូវ៉ាត់ ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក និងត្រីចក្រយានយន្ត ។

**ប្រភេទខ** : រថយន្តដឹកអ្នកដំណើរមិនលើសពី ៩ (ប្រាំបួន) នាក់ ដោយគិតទាំងអ្នកបើកបរ

- រថយន្តដឹកទំនិញដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ៣,៥ (បីក្បៀសប្រាំ) តោន
- រថយន្តក្នុងប្រភេទ **ខ** នេះ អាចសណ្តោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ០,៧៥ (សូន្យក្បៀសចិតសិបប្រាំ) តោន ។

**ប្រភេទគ** : រថយន្តដឹកទំនិញដែលមានទម្ងន់សរុបអតិបរមាលើសពី ៣,៥ (បីក្បៀសប្រាំ) តោន និងអាចសណ្តោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ០,៧៥ (សូន្យក្បៀសចិតសិបប្រាំ) តោន ។

**ប្រភេទឃ** : រថយន្តដឹកអ្នកដំណើរ៖

**ឃ១**: រថយន្តដឹកអ្នកដំណើរចាប់ពី ១០ (ដប់) នាក់ ដល់ ២០(ម្ភៃ) នាក់ ដោយគិតទាំងអ្នកបើកបរ និងអាចមានសណ្តោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ០,៧៥ (សូន្យក្បៀសចិតសិបប្រាំ) តោន ។

**ឃ២**: រថយន្តដឹកអ្នកដំណើរលើសពី ២០ (ម្ភៃ) នាក់ ដោយគិតទាំងអ្នកបើកបរ និងអាចមានសណ្តោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ០,៧៥ (សូន្យក្បៀសចិតសិបប្រាំ) តោន ។

ប្រភេទខ : រថយន្តប្រភេទ **ខ ត** និង **ឃ** មានសណ្តោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមាលើសពី ០.៧៥ (សូន្យក្បៀសចិតសិបប្រាំ) តោន ត្រូវចែកជាបីប្រភេទ គឺប្រភេទ **ខ(ខ)** ប្រភេទ **ខ(គ)** និងប្រភេទ **ខ(ឃ)**។

**មាត្រា ៤១_ថ្មី**

លក្ខខណ្ឌផ្សេងៗទាក់ទងនឹងបណ្ណបើកបរ ត្រូវកំណត់ដូចខាងក្រោម ៖

១-អ្នកបើកបរម្នាក់មានសិទ្ធិកាន់បណ្ណបើកបរតែមួយគត់ ។ បែបបទ នីតិវិធី សិទ្ធិ នៃការចេញបណ្ណបើកបរ និងបណ្ណពិន្ទុ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

២-ជនពិការមានសិទ្ធិបើកបរយានយន្តពិសេសសម្រាប់តែជនពិការ និងលក្ខខណ្ឌនៃការចេញបណ្ណបើកបរសម្រាប់ជនពិការ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងពាក់ព័ន្ធ ។

៣-អាយុអ្នកបើកបរត្រូវកំណត់តាមប្រភេទបណ្ណបើកបរ ដូចខាងក្រោម ៖

-អាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ យ៉ាងតិច ចំពោះប្រភេទ **ក** និង **ខ**

-អាយុ ២២ (ម្ភៃពីរ) ឆ្នាំ យ៉ាងតិច ចំពោះប្រភេទ **គ** និង **ឃ១**

-អាយុ ២៤ (ម្ភៃបួន) ឆ្នាំ យ៉ាងតិច ចំពោះប្រភេទ **ឃ២** និង **ខ** ។

៤-អ្នកមានបណ្ណបើកបរប្រភេទ **ខ** អាចបើកបរយានយន្តកសិកម្ម ឬយានយន្តបករណ៍ដែលមានល្បឿនអតិបរមាមិនលើសពី ៤០ (សែសិប) គីឡូម៉ែត្រក្នុងមួយម៉ោងតែមិនអាចបើកបរយានយន្តប្រភេទផ្សេងទៀតបានទេ ។

៥-ចំពោះអ្នកបើកបរយានយន្តបករណ៍ ដែលមានល្បឿនអតិបរមាលើសពី ៤០ (សែសិប) គីឡូម៉ែត្រក្នុងមួយម៉ោង ត្រូវមានបណ្ណបើកបរប្រភេទ **គ** ។

៦-ដើម្បីមានសិទ្ធិប្រឡងយកបណ្ណបើកបរប្រភេទ **គ** ត្រូវមានបណ្ណបើកបរប្រភេទ **ខ** ឬ **ឃ១** សិន ។

៧- អ្នកបើកបរយានយន្តប្រភេទ **គ** ឬ **ឃ** អាចបើកបរយានយន្តប្រភេទ **ខ** បាន ។

៨- អ្នកមានបណ្ណបើកបរប្រភេទ **គ** អាចបើកបរយានយន្តប្រភេទ **ឃ១** បាន ក្នុងករណីបានឆ្លងកាត់ការប្រឡងយកបណ្ណបើកបរយានយន្តប្រភេទ **គ** តាមរយៈបណ្ណបើកបរយានយន្តប្រភេទ **ឃ១** ប៉ុន្តែអ្នកមានបណ្ណបើកបរប្រភេទ **ឃ២** អាចបើកបរយានយន្តប្រភេទ **ខ** ឬ **គ** ឬ **ឃ១** បាន។

៩-ដើម្បីមានសិទ្ធិប្រឡងយកបណ្ណបើកបរប្រភេទ **ឃ១** ត្រូវមានបណ្ណបើកបរប្រភេទ **ខ** សិន ។

១០-ដើម្បីមានសិទ្ធិប្រឡងយកបណ្ណបើកបរប្រភេទ **ឃ២** ត្រូវមានបណ្ណបើកបរប្រភេទ **ខ** ឬ **គ** ឬ **ឃ១** សិន។

១១-ដើម្បីមានសិទ្ធិប្រឡងយកបណ្ណបើកបរប្រភេទ **ខ** ត្រូវមានបណ្ណបើកបរប្រភេទ **ខ** ឬ **គ** ឬ **ឃ** សិន ។

១២-អ្នកមានបណ្ណបើកបរប្រភេទ ខ អាចមានសិទ្ធិបើកបររថយន្តសណ្តោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមា លើសពី ០,៧៥ (សូន្យក្បៀសចិតសិបប្រាំ)តោន បានទៅតាមប្រភេទបណ្ណបើកបរដូចជា ខ(ខ) ឬ ខ(គ) ឬ ខ(ឃ) ។

## មាត្រា ៤៧.-ថ្មី

គ្រប់យានយន្តនៅពេលដាក់ឲ្យធ្វើចរាចរណ៍នៅលើផ្លូវថ្នល់ ត្រូវមានបណ្ណសម្គាល់យានយន្តនិងមានពាក់ផ្លាកលេខសម្គាល់យានយន្ត ។

គ្រប់យានយន្តត្រូវចុះបញ្ជីផ្តល់បណ្ណសម្គាល់យានយន្ត និងបំពាក់ផ្លាកលេខសម្គាល់យានយន្ត ។ ចំពោះរ៉ឺម៉ក ឬសឺមីរ៉ឺម៉កមានទម្ងន់សរុបលើសពី ៧៥០ (ប្រាំពីររយហាសិប) គីឡូក្រាម ត្រូវចុះបញ្ជីផ្តល់បណ្ណសម្គាល់ និងបំពាក់ផ្លាកលេខដូចយានយន្តដែរ ។

ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវផ្តល់បញ្ជីស្ថិតិយានយន្តគ្រប់ប្រភេទដែលបានចុះបញ្ជីរួចជូនក្រសួងមហាផ្ទៃមួយខែម្តង ។

ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវផ្តល់ព័ត៌មានអំពីចំនួនរថយន្ត ទោចក្រយានយន្ត ត្រីចក្រយានយន្ត ឬគ្រឿងចក្រដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួនជូនក្រសួងសាធារណការ និងដឹកជញ្ជូន ៣ (បី) ខែម្តង លើកលែងព័ត៌មានសម្ងាត់ដែលពាក់ព័ន្ធនឹងសន្តិសុខជាតិ ។

ការចុះបញ្ជីផ្តល់បណ្ណសម្គាល់យានជំនិះ និងបំពាក់ផ្លាកលេខសម្គាល់យានជំនិះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ៤៨.-ថ្មី

គ្រប់ម្ចាស់ហាងលក់យានយន្តគ្រប់ប្រភេទ មានកាតព្វកិច្ចបំពេញបែបបទចុះបញ្ជីយានយន្ត សុំបណ្ណសម្គាល់យានយន្ត និងសុំផ្លាកលេខសម្គាល់យានយន្តឲ្យបានចប់សព្វគ្រប់មុននិងប្រគល់ឲ្យអ្នកទិញ ។

ការលក់ទិញ ការធ្វើអំណោយ និងរាល់ទម្រង់ផ្សេងៗទៀត ដែលនាំឲ្យមានការផ្លាស់ប្តូរកម្មសិទ្ធិករនៃយានយន្តត្រូវបំពេញសំណុំបែបបទដើម្បីផ្ទេរកម្មសិទ្ធិយានយន្ត ។ បែបបទនិងនីតិវិធីនៃការផ្ទេរកម្មសិទ្ធិយានយន្ត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ម្ចាស់យានយន្តគ្រប់ប្រភេទ មានកាតព្វកិច្ចបំពេញបែបបទលុបចេញពីបញ្ជីយានយន្តនូវយានយន្តទាំងឡាយដែលឈប់ប្រើប្រាស់ ។

បែបបទ និងនីតិវិធីនៃការចុះបញ្ជីយានយន្ត ការផ្តល់ផ្លាកលេខសម្គាល់យានយន្ត និងការលុបចេញពីបញ្ជីយានយន្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

ROYAUME DU CAMBODGE — LE MINISTRE DU PALAIS ROYAL

**មាត្រា ៧៥.-ថ្មី**

ជនណាបើកបរយានយន្តដោយគ្មានបណ្ណបើកបរ ឬក្នុងរយៈពេលដែលបណ្ណបើកបរត្រូវបានដកហូត ព្យួរទុក ឬទុកជាមោឃៈ ត្រូវពិន័យអន្តរការណ៍តាមការកំណត់នៃអនុក្រឹត្យ ។

អំពើល្មើសខាងលើត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ៨០០ ០០០ (ប្រាំបីសែន)រៀល ទៅ ៤ ០០០ ០០០ (បួនលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀត ក្នុងកំលុងពេល ៦ (ប្រាំមួយ) ខែ ចាប់គិតពីការពិន័យអន្តរការណ៍លើកមុន ។

បទប្បញ្ញត្តិកថាខណ្ឌទី ២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះអ្នកបើកបររទោចក្រយានយន្ត ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្ត ។

**មាត្រា ៧៧.-ថ្មី**

ជនណាបើកបរយានយន្តនៅពេលដែលខ្លួន ស្ថិតនៅក្នុងភាពស្រវឹង ដោយមានជាតិអាល់កុលចាប់ពី ០,៤០ (សូន្យក្បៀសសែសិប) មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៨០ (សូន្យក្បៀសប៉ែតសិប)ក្រាមក្នុងមួយលីត្រឈាមឡើងទៅ ត្រូវពិន័យអន្តរការណ៍តាមការកំណត់នៃអនុក្រឹត្យ ។

អំពើល្មើសខាងលើត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ៨០០ ០០០ (ប្រាំបីសែន)រៀល ទៅ ៤ ០០០ ០០០ (បួនលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀត ក្នុងកំលុងពេល ៦ (ប្រាំមួយ) ខែ ចាប់គិតពីការពិន័យអន្តរការណ៍លើកមុន ។

**មាត្រា ៨២.-ថ្មី**

ជនណាប្រើប្រាស់យានយន្តដោយគ្មានបណ្ណសម្គាល់រថយន្ត ឬគ្មានផ្លាកលេខសម្គាល់រថយន្ត ត្រូវពិន័យអន្តរការណ៍តាមការកំណត់នៃអនុក្រឹត្យ ។

អំពើល្មើសខាងលើត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ១ (មួយ)ខែ និងពិន័យជាប្រាក់ពី ៤០០ ០០០ (បួនសែន)រៀល ទៅ ១ ០០០ ០០០(មួយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀត ក្នុងកំលុងពេល ៦ (ប្រាំមួយ)ខែ ចាប់គិតពីការពិន័យអន្តរការណ៍លើកមុន ។

បទប្បញ្ញត្តិកថាខណ្ឌទី ២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះអ្នកបើកបររទោចក្រយានយន្ត ទោចក្រយានយន្តសណ្តោងរ៉ឺម៉កឬត្រីចក្រយានយន្ត ។

**មាត្រា ៩០.-ថ្មី**

កាតព្វកិច្ចពាក់ខ្សែក្រវាត់សុវត្ថិភាព សម្រាប់អ្នករួមដំណើរទាំងអស់ជិះកៅអីខាងក្រោយនៃរថយន្តនៅក្រៅទីប្រជុំជននិងបទប្បញ្ញត្តិ ដែលមានចែងក្នុងកថាខណ្ឌទី ២ មាត្រា ៧ ព្រមទាំងចំណុចទី ១១

និងទី ១២ មាត្រា ៨ ថ្មី នៃច្បាប់នេះ ត្រូវចាប់អនុវត្តក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីច្បាប់នេះចូលជាធរមាននៅទូទាំងប្រទេស ។

**មាត្រាពីរ.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម.០១១៧.០០៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ហត្ថលេខា**

**ស៊ុន ចាន់ថុល**

លេខៈ ៧៥ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**